ស៊ុង ស៊ីម

# ចលនា

# អក្សរសិល្ប៍

ភាគ

CAMBODIAN EDUCATION EXCELLENCE
មូលនិធិឧត្តមភាពសម្រាប់ការសិក្សា
FOUNDATION
www.elibraryofcambodia.org

# ចលនាអារ្យធម៌

និពន្ធដោយលោក

## សុខ ស៊ីវ

និពន្ធទី ៣៩

បោះពុម្ពផ្សាយជាថ្មីដោយ

លោក ស្រី ប៊ុនដន

រក្សាសិទ្ធិ

ព.ស ២៥៤៨ គ.ស ២០០៥

www.elibraryofcambodia.org

# អារម្ភបទ

មិត្រអ្នកអានទាំងឡាយ! ហេតុដែលសៀវភៅនេះមិនបានចេញឆាប់ ដូចបានផ្សាយដំណឹងនោះគឺ ៖

ក- សៀវភៅនេះ ខ្ញុំសរសេររួចតាំងពីឆ្នាំ ១៩៦៩ បម្រុងបោះពុម្ពតបន្ទាប់ពីសៀវភៅ «ពុទ្ធសាសនានិងវិទ្យាសាស្ត្រ»។ ប៉ុន្តែមានពុទ្ធសាសនិកជាច្រើននាក់ ត្រូវការអានសៀវភៅ «ប្រជុំនិទានជាតក ភាគ ៦» ខ្ញុំក៏រៀបបោះសៀវភៅនោះសិន និងបោះពុម្ពសៀវភៅផ្សេងៗទៀតដែលត្រូវការជាបន្ទាន់។

ខ- ក្នុងដើមឆ្នាំ ១៩៧០ ខ្ញុំរៀបនឹងបោះពុម្ពហើយ ស្រាប់តែព្រឹត្តិការណ៍ ថ្ងៃ ១៨ មីនា បានមកដល់ កែប្រែប្រវត្តិសាស្ត្រខ្មែរជាថ្មី កំចាត់បង់នូវឧបសគ្គចុងប៉ាក្ការបស់អ្នកនិពន្ធចេញអស់។ នាំឲ្យខ្ញុំមាន កម្លាំងប្រាជ្ញាផ្លាគំនិត ពើរុះសរសេរសៀវភៅនេះជាថ្មីម្តងទៀត តាមសច្ចៈភាវៈនាបច្ចុប្បន្ន ដែលបានដឹងឮ បានពិសោធរាវរកឃើញ លុះសរសេររួចហើយ ក៏រៀបបោះពុម្ពជាបន្ទាន់។

ដូច្នេះ សៀវភៅ «ចលនាអារ្យធម៌» នេះទុកជាស្នាដៃដំបូងបំផុតរបស់ខ្ញុំ ក្នុងសម័យសាធារណរដ្ឋខ្មែរ ដែលទើបនឹងមានអាយុ ១ ឆ្នាំ និងជាអនុស្សាវរីយ៍ ចំពោះបុណ្យខួបទី១ នៃថ្ងៃ ១៨ មីនា ផង។

ភ្នំពេញ ថ្ងៃ ទី ១៨ មីនា ១៩៧១

សុង ស៊ីវ

មូលនិធិខ្មែរសម្រាប់ការសិក្សា
FOUNDATION

www.elibraryofcambodia.org

# បញ្ជីអត្ថបទ


| | | |
|---|---|---|
| ទំព័រវែកញែក | ទំព័រ | ៣ |
| ទំព័រចលនាអារ្យធម៌ | .. | ១៥ |
| សង្កាត់ទី ១ ផ្នែកអត្ថបទ | .. | ១៦ |
| ប្រភេទនៃអារ្យធម៌ | .. | ១៦ |
| មូលធម៌មាន ៥ | .. | ១៧ |
| អង្គនិងប្រភេទនៃមូលធម៌ | .. | ១៨ |
| វិភាគនៃមូលធម៌និងអារ្យធម៌ | .. | ២០ |
| នាទីនៃអារ្យធម៌ | .. | ២១ |
| អាយុជីវិតនៃអារ្យធម៌ | .. | ២១ |
| អារ្យធម៌ផ្នែកពុទ្ធសាសនា | .. | ២៣ |
| សង្កាត់ទី ២ ផ្នែកអត្ថាធិប្បាយ | .. | ២៤ |
| អារ្យធម៌សាកល | .. | ២៤ |
| អារ្យធម៌ខ្មែរ | .. | ៤២ |
| សម័យនៃអារ្យធម៌ខ្មែរ | .. | ៤២ |
| ប្រភព អនុប្រភពនៃអារ្យធម៌ខ្មែរ | .. | ៤២ |
| និយមនៃអារ្យធម៌ខ្មែរ | .. | ៤៣ |
| អារ្យធម៌ខ្មែរសម័យបុរេប្រវត្តិ | .. | ៤៤ |
| លក្ខណៈវប្បធម៌ | .. | ៥២ |
| ភាសាខ្មែរក្នុងសម័យទាំងបី | .. | ៥៦ |
| លក្ខណៈសង្គមធម៌ | .. | ៦៦ |
| កម្រងអារ្យធម៌ | .. | ៧១ |
| អារ្យធម៌ខ្មែរសម័យបុរេអង្គរ | .. | ៧៦ |
| ភាសាល្បាយខ្មែរ-សំស្ក្រឹត | .. | --- |
| អារ្យធម៌ខ្មែរសម័យអង្គរ | .. | ៨៩ |
| ជនជាតិបញ្ញើក្អែកនៃអាស៊ីអាគ្នេយ៍ | .. | ៩៥ |
| អារ្យធម៌ខ្មែរសម័យបច្ចាអង្គរ | .. | ៩៧ |


www.elibraryofcambodia.org

| | | |
|---|---|---|
| ភាសាល្បាយខ្មែរ-បាលី | .. | --- |
| កំណើតខ្មែរយួននៅដីក្រែង (សៀមរាប) | .. | --- |
| អារ្យធម៌ខ្មែរសម័យអាណានិគមបារាំង | .. | --- |
| អំពីភាសាល្បាយនិងភាសាបន្ថោកជាតិ | .. | --- |
| ភាសាល្បាយខ្មែរ-ចិន | .. | --- |
| ភាសាល្បាយខ្មែរ-បារាំង-យួន | .. | --- |
| គំរូភាសាខ្មែរធុនអេបចាយ | .. | --- |


www.elibraryofcambodia.org

# ចលនាអារ្យធម៌

តាមទម្លាប់ជាសាកល អ្នកសរសេរ អ្នកនិយាយនិងអ្នកស្តាប់នូវពាក្យថា «អារ្យធម៌» នេះបានយល់ន័យផ្សេងៗគ្នា ៖

- ខ្លះយល់ថា មហាអំណាច, យសសក្តិ, ចំណេះវិជ្ជា និងទ្រព្យសម្បត្តិ, អ្នកមានមហាអំណាចជាដើមនេះ ជាអារ្យជនមានអារ្យធម៌។ អារ្យជនបែបនេះច្រើននៅប្រទេសណា ប្រទេសនោះជាអារ្យប្រទេស។

ខ្លះយល់ថា ភាពសង្ហា ការហើហាហឹកហ៊ាក់ដោយគ្រឿងឧបភោគបរិភោគ គឺអ្នកណាដែលមានចំណីអាហារឆ្ងាញ់មានសម្លៀកបំពាក់ល្អ មានផ្ទះល្អនៅ មានរថយន្តជិះ និងចេះកាច់រាងយកតម្រាប់តាមជនបរទេស យកជនបរទេសធ្វើស្វាមី ភរិយាជាដើម អ្នកនោះជាមនុស្សស៊ីវិល័យមានអារ្យធម៌។

- ខ្លះយល់ថា ភាពទំនើបថ្មី គឺអ្នកណានិយមប្រើ ឬធ្វើនូវអ្វីៗដែលទើបនឹងកើតមានថ្មី ដោយបង្កើតខ្លួនឯងផ្ទាល់ឬធ្វើតាមជនបរទេស ដែលបានឃើញផ្ទាល់ ឬឃើញរូបភាពតាមទស្សនាវដ្តី តាមភាពយន្តជាដើម ដូចជាឃើញគេស្លៀកពាក់សំពត់អាវខ្លី ក៏ស្លៀកពាក់តាមគេ ឃើញគេកាត់សក់អ៊ុតសក់វែងខ្លីក៏ធ្វើតាមគេ អ្នកនោះជាមនុស្សស៊ីវិល័យមានអារ្យធម៌។

ខ្លះយល់យ៉ាងចម្លែកហើយប្រកាន់ថា អារ្យធម៌ប្រែន័យទៅតាមអក្សរ គឺបើសរសេរខ្មែរជា «អារ្យធម៌» បែបនេះ មានន័យទៅលើរបៀបរស់នៅ របស់ពួកអារ្យាង (Araens) ដែលចូលលុកលុយប្រទេសឥណ្ឌាពីសតវត្សរ៍ទី ១៧-១៨ មុន គ.ស. ជាពួកជនប្រកាន់វណ្ណៈ ត្រូវសរសេរអក្សរខ្មែរជា «អរិយធម៌» ដូចនេះវិញ ទើបមានន័យស្របតាមពាក្យបារាំងថា "Civilisation" ដោយសំគាល់ឃើញថាសំណេរ «អារ្យ» នេះចេញមកពី "Arya" នេះឯង។

ខ្លះយល់ថា អារ្យធម៌គឺការចម្រើនសូតលាស់ឿនលឿន យកការចម្រើនលូតលាស់នេះទៅភ្ជាប់នឹងអារ្យធម៌របស់ជនជាតិមួយៗ ហើយបែងចែកតម្លៃអារ្យធម៌របស់មនុស្សជាបីផ្នែក គឺអារ្យធម៌ខ្ពង់ខ្ពស់មួយ អារ្យធម៌អន់ថយមួយ និងនត្ថិភាពដែលហៅថា អនារ្យធម៌នោះមួយ។ ឯសត្វតិរច្ឆានខ្លះដែលមានសណ្តាប់ធ្នាប់ល្អ ដូចកណ្តៀរ ស្រមោច ឃ្មុំ និងដំរីដែលបានហ្វឹកហាត់ល្អហើយជាដើម ក៏មានអារ្យធម៌ដែរ។

- ខ្លះយល់ថា មិនត្រូវភ្ជាប់អារ្យធម៌ទៅនឹងតម្លៃទៅនឹងការវិនិច្ឆ័យរកតម្លៃនោះទេ ព្រោះអារ្យធម៌ជាសភាពពិតនៃការរស់នៅ នៃទម្លាប់ទំនៀមចិត្តគំនិតអង្គការច្បាប់ផ្សេងៗ ព្រមទាំងគ្រឿងប្រដាប់ប្រើប្រាស់របស់ជនជាតិនីមួយៗ គ្រាន់ប្លែកគ្នាទៅតាមពេលវេលា ទីកន្លែង និងតាមសង្គមនៃជនជាតិមួយៗប៉ុណ្ណោះ។


www.elibraryofcambodia.org

ឯមតិរបស់ជនបរទេសខ្លះ មានមតិលោក Gol deuveiser (ហ្គុលដឺវ៉ៃហ៊្សែរ) ជាដើម ក៏មានន័យដូចមតិនេះដែរ ។ល។

មុននឹងចូលទៅដល់ទំព័រចលនាអារ្យធម៌ សូមនាំយកមតិខាងលើនេះ ត្រង់ដែលមានចំណុចសំខាន់ៗមកធ្វើការវែកញែករកហេតុផលសិន ដើម្បីឲ្យទូលាយគំនិត ក្នុងការគិតពីអារ្យធម៌។

CAMBODIAN • EDUCATION • EXCELLENCE
មូលនិធិខ្មែរសម្រាប់ការសិក្សា
FOUNDATION

# ទំព័រវែកញែក

ក- ចំណុចមួយ ដែលមតិខ្លះយល់ថា អារ្យធម៌មានន័យ ទៅតាមអក្សរ គឺដែលយល់ថា បើសរសេរ «អារ្យធម៌» ដូចនេះ មានន័យទៅលើពាក្យ (Aryens) នោះទៅវិញត្រូវសរសេរ «អរិយធម៌» នេះវិញ ទើបត្រូវន័យតាមពាក្យបារាំងថា (Civilisation) ។

តើក្នុងមតិនេះ មានហេតុផលយ៉ាងណាខ្លះ?

ពាក្យថា (Aryens មកពី Arya) នេះ បើសរសេរមកជាអក្សរខ្មែរ គួរសរសេរ «អរិយាង-អរិយៈ» ឬសរសេរតាមលំនាំសំស្ក្រឹត «អាយ៉ាង-អាយ៌ៈ» ដូចនេះវិញទេទើបត្រូវ ព្រោះ (y) នេះមិនមែន «្យ» ខ្មែរ មិនមែនជា «អារ្យ» របស់ខ្មែរនេះឡើយ។

សំណេរ «អារ្យ» បែបនេះ មិនមែនជាសំស្ក្រឹតមិនមែនជាបាលី ដូចធ្លាប់យល់ច្រឡំនោះទេ គឺជាសំណេរខ្មែរសុទ្ធ ដែលកើតឡើងដោយស្នាដៃបុព្វបុរសខ្មែរ។

បុព្វបុរសខ្មែរសរសេរបែបនេះ ដើម្បីតម្រូវន័យឲ្យស្របនឹងសំស្ក្រឹតថា «អាយ៌ៈ» បាលីថា «អរិយៈ» នោះឯង ព្រោះភាសា-អក្សរសំស្ក្រឹតនិងបាលី ដែលចូលខ្លួនមកបម្រើភាសាអក្សរ-ខ្មែរយ៉ាងច្រើននោះ បុព្វបុរសខ្មែរមិនទទួលយកទាំងកម្រោលមកប្រើឡើយ សុទ្ធតែយកមកឈូស កោសលុបជ្រុង កែទម្រង់តាមសិល្បៈខ្មែរសិន គឺកែខាងសំណេរក៏មានខាងសូរស័ព្ទក៏មានកែទាំងអស់ក៏មាន។ វៀរតែពាក្យខាងធម៌វិន័យសាសនាចេញ ដែលមិនត្រូវកែឲ្យខុសពីគម្ពីរដើកា ដូចពាក្យសំស្ក្រឹតសរសេរ «អាយ៌» នេះ បុព្វបុរសខ្មែរយករបាទ «៌» ដែលនៅពីលើតួ «យ» នោះមករចនាជាតួ «រ» មានភស្តុតាងក្នុងសិលាចារឹកស្រាប់ យកតួ «យ» មករចនាជាជើង «្យ» ទៅវិញ គឺបំភ្លែយកជើងជាតួ «រ» ទៅសៀតបង្កប់ក្នុងទម្លាក់ជើង «្យ» បង្កើតជា «អារ្យ» មានចម្លែកដូច «អាយ៌ > អារ្យ» នេះឯង។

ឯសូរស័ព្ទពាក្យនេះវិញក៏អានមិនឲ្យញ័រចុងអណ្ដាតតគាត់ដូចសូរស័ព្ទសំស្ក្រឹតដែរ។

រចនាបថ (Styles) បែបនេះមានច្រើន ដូចពាក្យខ្មែរថា «អាចារ្យ អស្ចារ្យ បាដិហារ្យ ពិទូរ្យ និងសូរ្យ» ជាដើម។ ពាក្យទាំងនេះ សំស្ក្រឹតសរសេរជា «អាចាយ៌ អាស្ចាយ៌ ប្រាតិហាយ៌ វៃទូយ៌ និងសូយ៌»។ បាលីសរសេរជា «អាចរិយ អច្ឆរិយ បាដិហារិយ វេឡុរិយ និងសុរិយ»។

ដូច្នេះសំណេ «អារ្យ គឺអារ្យធម៌» នោះ រកកំណើតឃើញហើយ មិនមែនជាសំស្ក្រឹត មិនមែនជាបាលី និងមិនមែនជា ពាក្យសម្ដី ជាសំណេររបស់ពួកអារ្យាង (Aryens)


www.elibraryofcambodia.org

នៅប្រទេសឥណ្ឌាក្នុងសតវត្សរ៍ទី ១៧-១៨ មុន គ.ស. នោះឡើយ គឺពិតជាសំណេររបស់ខ្មែរកើតក្នុងទឹកដីខ្មែរតែម្តង។

តើខ្មែរយើងគួរប្រគល់សំណេរ «អារ្យធម៌» របស់ខ្លួននេះ ឲ្យទៅពួកខ្មោច Aryens ដែលស្លាប់បាត់យូរយារណាស់ទៅហើយនោះ យកទៅកាត់កន្ទុយលាបកំបោរចំណាំថាជាឈ្មោះលទ្ធិគេដាច់មុខហើយ យើងបែរជាទៅខ្ចីសំណេរបាលីទាំងកម្រោលគឺ «អរិយ» នេះមកប្រើជំនួសវិញឬ?

ម្យ៉ាងទៀតថា ខ្លាចមានទំនាស់ចំពោះពាក្យសម្តីគឺបើប្រើសំណេរ «អារ្យធម៌» នេះទៅនាំឲ្យយល់ន័យខុស ព្រោះសំណេរ «អារ្យធម៌» បែបនេះ សម្រាប់សំគាល់របៀបរស់នៅរបស់ជនជាតិឥណ្ឌា Aryens។ បើយកអក្សរនេះទៅសរសេរថា «អារ្យធម៌ខ្មែរ អារ្យធម៌ចិន អារ្យធម៌បារាំង» ទៅជាមានន័យថា «ការរស់នៅរបស់ខ្មែរអារ្យាង ចិនអារ្យាង បារាំងអារ្យាង» ទៅវិញ គឺមានន័យថា «ខ្មែរ-ចិន-បារាំងអារ្យាង» នេះ នៅក្រោមអំណាចត្រួតត្រារបស់ពួក Aryens ឬមានរបៀបរស់នៅតាមរបៀប Aryens។

ចំណុចនេះ រឹតតែផ្ទុយហេតុផល កាន់តែឆ្ងាយទៅទៀត មុខជាមានគេឆ្ងល់ថាជាតិសាសន៍ណាខ្លះក្នុងលោកនេះ ដែលចេះសរសេរ ចេះអាននូវសំណេរ «អារ្យធម៌» របស់ខ្មែរនេះ ហើយដឹងស្គាល់ថា ជាយីហោរបស់ពួក Aryens?។ បើសំណេរបែបនេះកើតនៅទឹកដីខ្មែរ ជារបស់ខ្មែរ សូម្បីតែជនជាតិឥណ្ឌា Aryens នោះ ក៏មិនដែលឃើញសំណេររបស់ខ្មែរនេះផង? ជាពិសេសជនជាតិឥណ្ឌាទាំងអស់ធ្លាប់ចេះធ្លាប់ស្គាល់តែអក្សរបែប សំស្ក្រឹត-បាលី គឺ «អាយ៌-អរិយ» នេះតែប៉ុណ្ណោះ។ តើជនជាតិ Aryens ណា ដែលបានមកសុំសំណេ «អារ្យធម៌» បែបនេះ ពីខ្មែរណាទៅធ្វើយីហោចំណាំរបៀបរស់នៅរបស់ខ្លួនមកយកទៅពីសតវត្សរ៍ទីប៉ុន្មានបានជាសំណេរនេះបានជាដាច់មុខទៅពួក Aryens ពួកខ្មែរដែលជាម្ចាស់សំណេរ ត្រឡប់ជាប្រើមិនបាន នាំឲ្យច្រឡំន័យទៅវិញ?។

ម្យ៉ាងទៀត បើថាមកពីមានរាងអក្សរស្រដៀងគ្នាព្រោះ «អារ្យ និង Arya » មានជើងក្ងក់ពីក្រោមដូចគ្នាត្រូវប្រគល់ឲ្យទៅគេទៅ យើងត្រូវរាវរកអក្សរផ្សេងមកសរសេរទៀតកុំឲ្យដូចគេ ការធ្វើព្រះវេស្សន្តរដូច្នេះក៏មិនសមដែរ។ ប៉ុន្តែដល់រាវរកទៅបាន «អរិយ» នេះមកជំនួសវិញ គឺបានចំទៅលើរបៀបរស់នៅរបស់ពួកឥណ្ឌាអរិយៈនោះ កាន់តែធ្ងន់ទៅទៀត ព្រោះឥណ្ឌា អរិយៈ នេះ ជាពួកមិច្ឆាទិដ្ឋិ យល់ផ្ទុយពីពុទ្ធសាសនាទាំងស្រុងដែលខ្មែរធ្លាប់ហៅថា និគ្រន្ថ គឺពួកអចេលក៍ អាជីវក ដែលជាពួកប្រកាន់លទ្ធិអរិយថា


www.elibraryofcambodia.org

ខ្លួនជាអ្នកកំចាត់កិលេសអស់ហើយ សូម្បីតែសំពត់ក៏មិនស្លៀកដែរ ដូចមានដំណាលក្នុងគម្ពីធម្មបទស្រាប់។

ត្រង់ចំណុចនេះ ក៏មិនខ្លាចច្រឡំន័យ មិនខ្លាចមានទំនាស់ខាងពាក្យសម្ដីថា «ខ្មែរអរិយាយ ចិនអរិយាង និងបារាំងអរិយាង» ដែលមានន័យថា អ្នករស់នៅតាមរបៀបនិគ្រន្ថអរិយៈផង។

ម្យ៉ាងទៀត បើប្រកាន់ត្រឹមតែវណ្ណៈស្នាមគំនូសអក្សរនិងសូរស័ព្ទសំឡេងដូច្នេះដល់យូរៗទៅ មុខជាខ្មែររកពាក្យប្រើមិនបានឡើយ ព្រោះបើមានពាក្យណាសរសេររាងដូចគេ ដូចឈ្មោះលទ្ធិជាតិគេ ត្រូវឈប់ប្រើ ត្រូវប្រគល់ឲ្យទៅគេ ព្រោះតែខ្លាចច្រឡំន័យនឹងគេយ៉ាងនេះ។

ឥឡូវរកឃើញទៀតហើយថា សំណេរ «អរិយធម៌» បែបនេះ ក៏មានន័យសម្រាប់សំគាល់របៀបរស់នៅរបស់ឥណ្ឌាអរិយៈដែរ តើយើងគួររើសយកពាក្យណាមកប្រើជំនួសទៀត? ឬក៏ស៊ូគ្រចិត្តស្រឡាញ់អរិយាង ខាងពួក និគ្រន្ថអរិយៈ ដែលស្រាតនននលគកមិនស្លៀកសំពត់នេះហើយ?។

ម្យ៉ាងវិញទៀត បើថាមិនមែនយកអក្សរ «អរិយ» នេះ តាមពួកនិគ្រន្ថអរិយៈទេ គឺយកតាម «អរិយ» ខាងព្រះអរហន្តពុទ្ធសាសនាទេតើ!។ បើថាយ៉ាងនេះ ក៏នៅច្រឡំន័យដដែល ក្នុងពេលដែលសរសេរថា «អរិយធម៌ខ្មែរ អរិយធម៌ចិន អរិយធម៌បារាំង» ជាដើមនោះ ទៅជាមានន័យថា «ខ្មែរ ចិន បារាំង អរិយាង» ដដែល គឺខ្មែរ ចិន បារាំងនោះ មានរបៀបរស់នៅដូចព្រះអរិយៈខាងពុទ្ធសាសនាត្រូវតែលះបង់កូនប្រពន្ធទ្រព្យសម្បត្តិ កោរសក់ កោរពុកមាត់ ទៅបួសទាំងអស់គ្នាកុំឲ្យសល់ម្នាក់ព្រោះសុទ្ធតែពួកអរិយាងទៅហើយ គឺសុទ្ធតែព្រះអរហន្ត។

ការប្រកាន់យកតាមតួអក្សរ តាមសូរសព្ទភាសាហួសហេតុដូចនេះ ពិតជាមានអ្នកអានខ្លះយល់ថា ចូលទៅក្នុងក្បួនឆោត ព្រោះពាក្យថា «អាយ៌» របស់សំស្ក្រឹតក្ដី «អរិយ» របស់បាលីក្ដី «អារ្យ» របស់ខ្មែរក្ដី គ្រាន់តែប្លែកគ្នាតាមជាតិសាសន៍ ភាសាអក្សរប៉ុណ្ណោះឯន័យ សំដៅត្រង់គុណភាពថ្លៃថ្នូរ ប្រសើរខ្ពង់ខ្ពស់តែមួយដូចគ្នា គឺមួយដំបនិងបួនមិនគួរយល់ថា បួនច្រើនជាងមួយដំប ឬក៏យល់ថា មួយដំបច្រើនជាងបួនយ៉ាងនេះសោះឡើយ។


www.elibraryofcambodia.org

ជាពិសេស គណៈកម្មការវប្បធម៌ខ្មែរយើង បានប្រដូចពាក្យ «អារ្យធម៌» របស់ខ្មែរនេះទៅនឹងពាក្យបារាំងថា (Civilisation) មិនបានប្រដូចពាក្យ «អារ្យធម៌» នេះទៅនឹងពាក្យ "Arya Aryens" នោះឡើយ។

ការវែកញែកផ្ដិះគូនចំណុចតូចមួយខាងលើនេះ គ្រាន់តែបង្ហាញហេតុផល ចំពោះអ្នកអានប៉ុណ្ណោះ ស្រេចលើអ្នកអានវិនិច្ឆ័យតាមយថាហេតុចុះ។

ខ- ចំណុចមួយទៀត ដែលមតិខ្លះយល់ថា អារ្យធម៌គឺការចម្រើនលូតលាស់ឿនលឿនខ្ពង់ខ្ពស់ បានយកតម្លៃមួយ គឺការចម្រើនលូតលាស់ ឿនលឿនខ្ពង់ខ្ពស់នោះទៅភ្ជាប់នឹងអារ្យធម៌របស់ជនជាតិមួយៗ ហើយចែកអារ្យធម៌របស់មនុស្សជាបីផ្នែក គឺអារ្យធម៌ខ្ពង់ខ្ពស់មួយ អារ្យធម៌អន់ថយមួយ និងនត្ថិភាពដែលហៅថា អានារ្យធម៌នោះមួយ។ ឯសត្វតិរច្ឆាន ក៏មានអារ្យធម៌ដែរ។

គ- ចំណុចមួយទៀត ដែលយល់ផ្ទុយពីមតិខាងលើនេះ គឺយល់ថា មិនត្រូវភ្ជាប់អារ្យធម៌ទៅនឹងតម្លៃ ទៅនឹងការវិនិច្ឆ័យរកតម្លៃនោះទេ ព្រោះអារ្យធម៌ ជាសភាពពិតនៃការរស់នៅ និងទម្លាប់ទំនៀមចិត្តគំនិត អង្គការច្បាប់ផ្សេងៗ ព្រមទាំងគ្រឿងប្រដាប់ប្រើប្រាស់របស់ជនជាតិមួយៗ គ្រាន់តែប្លែកគ្នាទៅតាមពេលវេលា ទីកន្លែង និងតាមសង្គមនៃជនជាតិមួយៗប៉ុណ្ណោះ។

មតិ ខ និង គ ដែលផ្ទុយគ្នាខាងលើនេះ បើពិនិត្យទៅតាមហេតុផលដើម្បីឲ្យយោបល់ថា ខាងណាខុស ខាងណាត្រូវនោះ ឃើញថា ត្រូវផង ទាំងអស់គ្នា ព្រោះមតិទាំងពីរនេះ គ្រាន់តែនិយាយថា អារ្យធម៌ៗប៉ុណ្ណោះ មិនដឹងជានិយាយសំដៅ អារ្យធម៌ប្រភេទណា? ព្រោះមានអារ្យធម៌ប្រភេទខ្លះ គ្រាន់តែជាសភាពពិតនៃការរស់នៅជាដើមប៉ុណ្ណោះ គ្មានតម្លៃ គ្មានការវិនិច្ឆ័យថាខ្ពង់ខ្ពស់ ឬថោកទាបឡើយ ប្រភេទខ្លះប្រកបដោយតម្លៃ និងការវិនិច្ឆ័យពីធម្មជាតិស្រាប់។ ដូច្នេះមតិទាំង ២ នេះ ឃើញសុទ្ធតែជាមតិមិនច្បាស់លាស់។ ប្រសិនបើមិនបានដឹងថា អារ្យធម៌ មានចែកជាប្រភេទទេ គឺយល់ថាមានតែមួយនោះ រឹតតែខុសឆ្ងាយទៅទៀត។

អាស្រ័យហេតុនេះហើយ ទើបបុព្វបុរសខ្មែរ លោកចែកអារ្យធម៌នេះជា ៤ ប្រភេទ ទៅតាមហេតុផលតាមសភាវៈពិតនៃចលនាមនុស្សលោក គឺអារ្យធម៌ប្រភេទទី១ ចែកទៅតាមធម្មតាលោក ដែលមានសភាពផ្ទុយគ្នាជានិច្ចមានល្អត្រូវមានអាក្រក់មានខ្ពស់ត្រូវមានទាបជាដើមនោះ ដើម្បីវិនិច្ឆ័យបង្ហាយ តម្លៃខ្ពស់ទាបនៃសភាពរស់នៅរបស់មនុស្សសត្វ។


www.elibraryofcambodia.org

អារ្យធម៌ប្រភេទទី ១ នេះ ស្របតាមមតិ ខ ប៉ុន្តែមិនមែនមាននាទីបង្កើតសេចក្តីចម្រើនលូតលាស់ ដូចក្នុងមតិ ខ នោះទេ គឺមាននាទីបង្កើតសុខសន្តិភាពទៅវិញ។

ឯអារ្យធម៌ប្រភេទទី ២ ទី ៣ និងទី ៤ នោះ ស្របតាមមតិ គ មាននាទីបង្កើតសេចក្តីចម្រើនលូតលាស់ទៅតាមពេលវេលា តាមទីកន្លែង និងតាមសង្គមនៃជនជាតិនីមួយៗ គឺគ្រាន់តែជាសភាពពិតនៃទង្វើរបស់មនុស្សប៉ុណ្ណោះ មិនទាន់មានវិនិច្ឆ័យតម្លៃថាខ្ពង់ខ្ពស់ឬថោកទាបបានឡើយ។ លុះតែមានអារ្យធម៌ប្រភេទទី ១ ឬគ្មាននៅក្នុងទង្វើនោះផងទើបអាចវិនិច្ឆ័យចាត់ថ្នាក់តម្លៃបាន។

ព្រោះហេតុនេះហើយ ទើបគេមិនអាចចាត់ប្រទេសជាតិ ដែលនៅទន់ខ្សោយខាងសម្ភារៈ និងមហាប្រទេសដែលល្បីថា ចម្រើនលូតលាស់ខាងសម្ភារៈយ៉ាងសម្បើមនោះថា មានអារ្យធម៌ខ្ពង់ខ្ពស់ ឬគ្មានអារ្យធម៌នោះបានឡើយ។

ព្រោះថា បើមហាប្រទេសដែលចម្រើនលូតលាស់សម្បើមនោះ បានបង្កើតគ្រឿងឧបភោគបរិភោគ និងបង្កើតអង្គការច្បាប់គ្រប់យ៉ាងបានល្អប្រសើរហើយ ប៉ុន្តែគ្មានអារ្យធម៌ប្រភេទទី១ គឺមិនបានប្រតិបត្តិតាមច្បាប់ដែលខ្លួនបង្កើតនោះ ឲ្យបានជិតដល់ និងមិនបានយកគ្រឿងឧបភោគបរិភោគទៅសង្គ្រោះមនុស្សជាពិសេសពលរដ្ឋខ្លួន បណ្តោយឲ្យពលរដ្ឋក្រខ្សត់ អត់ឃ្លាន មានការបះបោរ មានចោរប្លន់ មានពួកអ្នកលេងបាតផ្សារ លួចឆក់ មានការប្រកាន់បក្សពួក សម្បូរវិស្សុត បែកសាមគ្គីគ្នា មានភេរវកម្មដោយគ្រាប់បែកគ្រាប់កាំភ្លើង មានអំពើពុករលួយក្នុងអង្គការរដ្ឋយ៉ាងនេះ ចាត់ជាអារ្យប្រទេស មានអារ្យធម៌ខ្ពង់ខ្ពស់មិនបានឡើយ ព្រោះគ្មានអារ្យធម៌ប្រភេទទី ១ ដែលនាំឲ្យកើតសុខសន្តិភាព។ មិនយូរប៉ុន្មានមហាប្រទេសនោះ នឹងសាបសូន្យចាកសេចក្តីចម្រើនលូតលាស់មិនខាន។

ចំណែកប្រទេសតូចតាច ដែលនៅទន់ខ្សោយវិញ បើក្នុងផ្ទៃប្រទេសនោះមានសុខសន្តិភាព ពលរដ្ឋមានជីវភាពសុខស្រួល មានសាមគ្គីធម៌ មិនមានការបះបោរ មិនមានចោរប្លន់ មិនមានពួកអ្នកលេងបាតផ្សារលួចឆក់ មិនមានភេរវកម្មដោយគ្រាប់បែកគ្រាប់កាំភ្លើង និងមិនមានអំពើពុករលួយក្នុងអង្គការរដ្ឋជាដើមនោះ ចាត់ជាមហាប្រទេសមានអារ្យធម៌ខ្ពង់ខ្ពស់បាន ព្រោះមានអារ្យធម៌ប្រភេទទី ១ ដែលនាំឲ្យកើតសុខសន្តិភាព មិនយូរប៉ុន្មាន ប្រទេសតូចៗនោះនឹងចម្រើនលូតលាស់ធាត់ធំមិនខាន ព្រោះសុខសន្តិភាពនេះឯង ដែលនាំឲ្យកើតសេចក្តីចម្រើនលូតលាស់។

ដូចនេះ មហាប្រទេសដែលល្បីថា ចម្រើនលូតលាស់សម្បើមនោះ ចាត់ជាអារ្យប្រទេសខ្ពង់ខ្ពស់មិនទាន់បានឡើយ។ ឯប្រទេសតូចៗ ដែលល្បីថា គ្មានការចម្រើន


www.elibraryofcambodia.org

លួតលាស់នោះបដិសេធថាមិនមែនជាអារ្យប្រទេសខ្ពង់ខ្ពស់ ថ្លៃថ្នូរ ក៏មិនបានដែរ។ ព្រោះថា ជនជាតិក្នុងប្រទេសដែលចម្រើនលួតលាស់សម្បើម ធំសម្បើម ចេះដឹងសម្បើម ឆ្លាតសម្បើមនោះ ដល់ពេលថ្ងៃឬយប់ មិនហ៊ានចេញឆ្ងាយពីទ្វារផ្ទះ ខ្លាចអ្នកលេងបាតផ្សារ លួចឆក់ ខ្លាចភេរវកម្មដោយគ្រាប់បែកគ្រាប់កាំភ្លើង ពលរដ្ឋភាគច្រើនទុក្ខព្រួយរាល់ថ្ងៃ ខ្លាចដាច់ពោះស្លាប់ ។ល។ បើមានការចម្រើនលួតលាស់សម្បើម ធំសម្បើម ចេះសម្បើម ឆ្លាតសម្បើម ហើយម៉េចក៏ទៅជាខ្លាចកំសាក ចោលម្សៀត ជាងសត្វឆ្កែឆ្មា ដែលវាហ៊ានដើរលេងគ្រប់ច្រកល្ហកយ៉ាងនេះម៉េចក៏គ្មានជីវភាពសុខស្រួលសោះ។

ត្រង់ចំណុចនេះហើយ ដែលបញ្ជាក់ឲ្យឃើញច្បាស់ថា ការចម្រើនលួតលាស់ដែលកើតពីអារ្យធម៌ប្រភេទ ទី ២ ទី ៣ ទី ៤ នោះ ទោះបីចម្រើនលួតលាស់ដល់ថ្នាក់ណាក៏ដោយ អាចទៅដល់ឋានព្រះច័ន្ទទី ២ ក្នុងចក្កវាឡដទៃទៀតក៏ដោយមិនទាន់មានតម្លៃ មានការវិនិច្ឆ័យថាយ៉ាងណាៗបានឡើយ។ លុះតែមានអារ្យធម៌ប្រភេទទី ១ នៅក្នុងសេចក្ដីចម្រើនលួតលាស់នោះផង ទើបវិនិច្ឆ័យថា មានតម្លៃខ្ពង់ខ្ពស់បាន។ បើគ្មានទេ មានតែការប្រព្រឹត្តធ្វើផ្ដេសផ្ដាសតាមចំណង់នោះត្រឡប់ជាថោកទាបអន់កំសាកជាងសត្វ គ្មានខ្លឹមសារដូចជាផ្លែឃ្លោកធំតែខ្លួនដូច្នោះដែរ នឹងក្លាយជាមហាសត្រូវរបស់មនុស្សជាតិថែមទៀត។

ចំណុចមួយទៀត ក្នុងមតិ ខ ដែលយល់ថា សត្វតិរច្ឆានក៏មានអារ្យធម៌ដែរនោះ ប្រហែលអ្នកអានយល់ថា គ្មានស្រេចទៅហើយ។

មែន! បើមិនបានឃើញសេចក្ដីពន្យល់ច្បាស់លាស់ក្នុងក្បួនច្បាប់ ដែលធ្លាប់មានមកយូរហើយនោះទេ រកកលជឿមិនកើត។ សម្ដេចព្រះសង្ឃរាជ ព្រះនាម ជួន ណាត ព្រះអង្គបានដកស្រង់ពីក្បួនច្បាប់មួយ មកសរសេរក្នុងវចនានុក្រមខ្មែរដែរ អំពីសត្វតិរច្ឆានមានអារ្យធម៌នេះ ត្រង់ទំព័រ ១៦៧៩ ផ្នែកអក្សរ អ។

អារ្យធម៌នេះ បានជាសត្វតិរច្ឆានក៏មានដែរ ព្រោះមិនមែនជាធម៌ថ្នាក់ខ្ពស់ដូចអរិយមគ្គ អរិយផល ក្នុងទ្រឹស្ដីពុទ្ធសាសនា ដែលជាធម៌របស់ព្រះអរហន្តនោះឡើយ គឺជាធម៌របស់មនុស្សសត្វបុថុជ្ជន អ្នកបម្រើកាម គ្រាន់តែជាធម៌ប្រសើរមួយ ក្នុងចំណោមធម៌អាក្រក់ប៉ុណ្ណោះ។ បានដល់អ្វីៗដែលទាក់ទងនឹងជីវិត ឬជីវភាពពលរដ្ឋ ដែលមានសភាពត្រឹមត្រូវ សភាពល្អ ចេះច្បាប់ទម្លាប់ ចេះរបៀបរស់នៅ ចេះធ្វើខ្លួនឲ្យបានស្របតាមច្បាប់ទម្លាប់សង្គម មានទំហំប៉ុនគ្នានឹងពាក្យបារាំងថា Civile, civiliser, se civiliser, civilité ដែលរួមមកថា Civilisation យើងប្រែថា អារ្យធម៌នោះឯង។


www.elibraryofcambodia.org

ឯមនុស្សនិងសត្វនេះ ជាអ្នកបម្រើកាមដូចគ្នា មានញី មានឈ្មោល មានស្នេហា មានការសេពមេថុនដូចគ្នា។ ចំពោះការសេពមេថុននេះ ពួកសត្វមានពេលវេលាគ្រាន់បើជាងមនុស្ស ឯពួកមនុស្សញៀនសេពណាស់ គ្មានពេលវេលា ខែ រដូវ ឈប់សម្រាកសោះ ឃើញថា ឥតរបបជាងសត្វទៅទៀត។

បើសម្គាល់ថា សត្វតិរច្ឆានមានឋានៈ ពូជ ជាតិ ថោកទាប មានបញ្ញាទន់ខ្សោយជាងមនុស្សនោះ ក៏ពិតមែនហើយ។ ប៉ុន្តែពួកសត្វតិរច្ឆាន មានវិញ្ញាណប្រសើរជាងពួកមនុស្សឆ្ងាយណាស់ និងមានលក្ខណៈវិសេសខ្លះទៀត ដែលគ្រាន់បើជាងមនុស្ស ដូចសត្វឆ្កែនិងស្ពាជាដើម ដែលមានភក្តី សេចក្តីស្មោះត្រង់និងស្វាមីភក្តិ សេចក្តីស្រឡាញ់ស្មោះចំពោះម្ចាស់អ្នកមានគុណដែលបានចិញ្ចឹមរក្សាវា យ៉ាងប្តូរផ្តាច់ស្មើជីវិត ឃើញថា គ្រាន់បើជាងពួកមនុស្សខ្លះឆ្ងាយណាស់។ សូម្បីតែព្រះអរហន្តសម្មុទ្ធ ក៏ព្រះអង្គត្រាស់សរសើរថា «សត្វតិរច្ឆាន មានចិត្តត្រង់ជាងចិត្តមនុស្ស» ដែរ។ ខាងការចំណាំចាំបានវិញ ក៏គ្រាន់បើជាងពួកមនុស្សខ្លះឆ្ងាយណាស់ដែរ ដូចសត្វព្រាបជាដើម ទោះយកវាទៅចោលក្នុងទីណា ក៏មករកកន្លែងដើមដែលដែលវាធ្លាប់នៅឃើញដែរ វាមិនញៀនឈ្លក់ដោយអារ្យធម៌បរទេស ភ្លេចទីកន្លែង ស្រុកទេសខ្លួន មើលងាយជនជាតិខ្លួន និងស្រុកទេសខ្លួន ដូចពួកមនុស្សខ្លះនោះឡើយ ។ល។

សមត្ថភាពពិសេសៗរបស់សត្វតិរច្ឆាន ដូចបានដកយកមកជំណាលបន្តិចនេះឯងជាអារ្យធម៌របស់ពួកសត្វ ឃើញថា គ្រាន់បើជាងអារ្យធម៌របស់មនុស្សខ្លះផង។ អាស្រ័យហេតុនេះ ទើបបុព្វបុរសគ្រប់ប្រទេសទាំងអស់ក្នុងលោក បានយកអារ្យធម៌ និងអនារ្យធម៌របស់ពួកសត្វ បកចងជានិទាន ជាពាក្យស្លោក សុភាសិត ជំបូន្មាន បញ្ចូលមកក្នុងអារ្យធម៌របស់មនុស្ស សម្រាប់ប្រដៅពួកមនុស្ស ឲ្យមានសភាពល្អក្នុងការរស់នៅ ដូចលោកឡាហ្វុងតែន (បារាំង) និយាយពីចចកនិងកូនចៀមជាដើម លោក នារាយណៈមហាបណ្ឌិត (ឥណ្ឌា) និយាយពីសត្វស្វានិងពពែជាដើម លោកតែតុល្លីយាង (វ៉ូម៉ាំង) និយាយពីសិង្ហនិងប្រើសជាដើម ។ល។

ឯបុព្វបុរសខ្មែរ បាននិពន្ធចងក្រង ជានិទាន ជាពាក្យស្លោក សុភាសិត ជំបូន្មានបានច្រើនជាងបុព្វបុរសរបស់ជនជាតិនានាក្នុងលោក។ ផ្នែកនិទានរាប់រយរឿង មានរឿងសុភាទន្សាយជាដើម ផ្នែកពាក្យស្លោក សុភាសិត ជំបូន្មាន រឹតតែច្រើនណាស់ទៅទៀត សុទ្ធតែមានន័យយ៉ាងសំខាន់ៗដូចក្នុងច្បាប់កូនចៅថា ៖


www.elibraryofcambodia.org

«ទោះនឹងយាត្រា ទៅទីឋានណា ដើរដូចភុជង្គសិរសាទន់ទាប សុភាពផ្គត់ផ្គង់ លំឧតឱនអង្គ ការកេរ្តិ៍អ្នកជា។ រីអ្នកសាមន្យ ខ្សត់ខ្សោយសន្តាន អាប់ឥតប្រាជ្ញា ដំណើរអែងអោង កែងកោងហត្ថា ដូចខ្ទួយសោះសារ មែនមានពិសតិច។ បំពើងបំពើត ចំកោងស្កួយស្ទើត ពឹងពិសទ្រនិច ទិចតើប៉ុន្មាន»។

មួយឃ្លាទៀតក្នុងច្បាប់ដដែលថា ៖

«ធម្មតាជាស្ត្រី កុំចង់មេត្រី សាយសព្វអន្លើ យកម្តេចខ័ណ្ឌស្អុរ មកគរទុកលើ ស្រមោចហើយតើ អត់ម្តេចមិនឆី។ មួយដូចប្រុសខ្លោះ[1] ពោលពេញកម្លោះ ចិត្តចោរចង់ស្រី កលមួយដូចក្អែក ចេញលួចរកឆី មិនដឹងឬអ្វី យកពងមាន់ផ្ញើ»។

មួយឃ្លាទៀតក្នុងច្បាប់ដដែលថា ៖

«នីមួយៗលោកថា អំពីពុតខ្លា យល់សាច់ទាំងឡាយ ចងប៉ុនតែឆី ឥតបីរសាយ អស់មនុស្សទាំងឡាយកុំត្រាប់ពុតខ្លា»។

«លោកថាឲ្យត្រាប់ នូវសត្វកុកសាប អំពើប្រពៃកុំត្រាប់កុកស ភោភាវសព្វថ្ងៃ ហើរទំអាស្រ័យ ពុំប្លែកប្លែងប្រាណ»។

មួយឃ្លាទៀតក្នុងច្បាប់វិធូរបណ្ឌិតថា ៖

«ពានរពុំដែលស្ម័គ្រ ស្រីសាធសក្តិពុំដែលស្រែក រីឯមៀមនិងក្អែក ពុំដែលរួមទ្រនំគ្នា»។

មួយឃ្លាទៀតក្នុងច្បាប់ហែមហាជនថា ៖

«កង្កែបគីង្គក់ហ៊ីងអរឃើញភ្លៀងស្រក់សស្រាក់នាំគ្នាស្រែកឮជាក់លោតលេងសាយ កាលភ្លៀងនៅ។ លង់លុះដល់ភ្លៀងរាំង ដីរឹងគាំងស្ងួតទាំងស្មៅ កង្កែបហ៊ីងអាសៅ នេសាទទៅចាប់វាយឆី»។

មួយឃ្លាទៀតក្នុងច្បាប់ល្បើកបុរាណថា ៖

«កុំត្រាប់អណ្តើក ខំវារវើក ទៅពងឯលើ លុះពងបានហើយ ម្តេចឡើយទៅផ្ញើរ ទុកដាក់ពាក់លើ អាអូតមហាចោរ» ។ល។

ពាក្យស្លោក កំណាព្យ សុភាសិត ខាងលើនេះ មានន័យជ្រៅឆ្ងាយ និងរស់រវើកគ្រប់សម័យ ឃើញថា បុព្វបុរសខ្មែរ បានដកយកអារ្យធម៌ និងអនារ្យធម៌របស់ពួកសត្វភុជង្គ គឺសត្វនាគ និងសត្វខ្ទួយ ស្រមោច ក្អែក ខ្លា កុកសាប កុកស មៀម កង្កែប ហ៊ីង គីង្គក់ អណ្តើក និងសត្វអាអូត ជាដើមនេះ

[1] មានអធិប្បាយគ្រប់ប្រភេទទាំង ៤ ក្នុងទំព័រខាងមុខ។


www.elibraryofcambodia.org

មកនិពន្ធចងក្រងជាដំបូន្មាន បញ្ចូលមកក្នុងអារ្យធម៌របស់មនុស្ស បញ្ជាក់ឲ្យដឹងថាពួកសត្វតិរច្ឆានក៏មានអារ្យធម៌ និងអនារ្យធម៌ដូចពួកមនុស្សដែរ។ នេះគ្រាន់តែជានិទស្សនៈងាយៗ តាមការធ្លាប់ដឹងធ្លាប់ឃើញទាំងអស់គ្នាជាធម្មតាប៉ុណ្ណោះ។

បើនិយាយតាមការត្រិះរិះស្រាវជ្រាវរកហេតុផលអាចំកំបាំងឲ្យបានជ្រៅទៅទៀតនោះ ឃើញថា មនុស្សនិងសត្វមានអារ្យធម៌ មានសមត្ថភាពម្យ៉ាងម្នាក់ទេ នឹងថាខាងណាគ្រាន់បើជាងខាងណាក៏មិនបានគ្រាន់តែសត្វតិរច្ឆានគ្មានឋានៈពូជជាតិថោកទាបជាងមនុស្ស ប៉ុណ្ណោះ។ ចំពោះសមត្ថភាពក្នុងការរស់នៅវិញ ឃើញថា ខាងពួកមនុស្សទន់ខ្សោយជាងពួកសត្វ មិនអាចរស់នៅតាមសមត្ថភាពខ្លួនបានទាល់តែពឹងពាក់លើពួកសត្វ មានពឹងខាងកម្លាំង ខាងទឹកដោះនិងខាងសាច់ឈាមជាដើម របស់សត្វ ឲ្យជួយទប់ទល់ជីវិតផងទើបរស់នៅកើត។ ឯពួកសត្វវិញ អាចរស់នៅតាមសមត្ថភាពរបស់ពួកខ្លួនបានដោយស្រួល និងមានសមត្ថភាពជាគ្រូបង្ហាត់បង្ហាញផ្តល់ចំណេះវិជ្ជាឲ្យពួកមនុស្សថែមទៀត ជាពិសេសជាគ្រូផ្ទាល់របស់អ្នកវិទ្យាសាស្ត្រតែម្តង ព្រោះធម្មជាតិបង្កើតសត្វមកបានផ្តល់សមត្ថភាព និងក្បួនវិទ្យាសាស្ត្រភ្ជាប់នឹងខ្លួនសត្វតែម្តង ដើម្បីអនុគ្រោះពួកសត្វ ដែលមានពូជជាតិថោកទាបជាងមនុស្ស។ ឯពួកមនុស្សវិញ ធម្មជាតិបង្កើតមកមានតែរូបកាយ និងចិត្តវិញ្ញាណទទេប៉ុណ្ណោះ ត្រូវខំសិក្សាអស់ពាក់កណ្តាលជីវិតទៀត ទើបមានការចេះដឹងបាន។

ផ្នែកសមត្ថភាពសត្វ ដែលធម្មជាតិផ្តល់ឲ្យយ៉ាំយវិសេសជាងមនុស្សនោះ មានច្រើនបែប ដូចខាងការបង្កើតកូន ការចិញ្ចឹមរក្សាកូន របស់ពួកសត្វ គោ ក្របី ជាដើម កូនវាកើតចេញពីផ្ទៃមក មានសមត្ថភាព ចេះដើរ ចេះរត់ចេះទំពារស៊ីអាហារភ្លាមៗ មិនដូចកូនមនុស្ស ដែលកើតមកហើយគ្មានសមត្ថភាព ក្នុងការដើរ អង្គុយជាដើមសោះ ត្រូវដេកនៅមួយកន្លែងជាច្រើនខែនោះឡើយ។

ផ្នែកចំណេះវិជ្ជាក្បួនវិទ្យាសាស្ត្រ របស់ពួកសត្វ និងឋានៈជាគ្រូនៃពួកមនុស្សនោះ អ្នកវិទ្យាសាស្ត្របច្ចុប្បន្ន បានទទួលស្គាល់ ទទួលយកធ្វើជាគ្រូស្រេចទៅហើយ។


www.elibraryofcambodia.org

ពួកធម្មជាតិវិទូ និងគីមីវិទូ បានរកឃើញថា ពួកមនុស្សមិនគ្រាន់តែចាញ់ពួកសត្វខាងកម្លាំង និងខាងរាងកាយប៉ុណ្ណោះទេ ថែមទាំងចាញ់ខាងផ្លូវវិញ្ញាណ របស់ពួកសត្វឆ្ងាយណាស់ទៅទៀត។

មនុស្ស មិនមែនជាម្ចាស់ផែនដីនេះតែឯងទេ។ លុះតែពួកមនុស្សបានចេះដឹង បានស្គាល់ជាក់នូវចក្ខុវិញ្ញាណ ដែលស្ដាប់សូរស័ព្ទច្បាស់ នូវឃានវិញ្ញាណដែលស្រូបក្លិនច្បាស់ ដែលមានក្នុងពួកសត្វ ទើបមនុស្សធ្វើជាម្ចាស់ផែនដីម្នាក់ឯងបាន។ សព្វថ្ងៃនេះមនុស្សយើង មិនទាន់ស្គាល់វិញ្ញាណច្បាស់ទាំងនោះឡើយ ពួកអ្នកវិទ្យាសាស្ត្រទើបតែចាប់ផ្ដើមសិក្សាពីពួកសត្វ។

អំពីចក្ខុវិញ្ញាណច្បាស់របស់ពួកសត្វ លោក Autrum (អូទ្រុម) បានសិក្សាពីសត្វរុយប្រភេទ Alliphora (អាល្លីហ្វូរ៉ា) រុយនោះបានបង្រៀនលោកឲ្យដឹងថា ពួកសត្វល្អិតមានប្រដាប់វិទ្យាម្យ៉ាង ដែលលោក Chauvin (សូវ៉ាំង) ឲ្យឈ្មោះថា Loupe temporelle (កែវពង្រីកពេល) ដែលអ្នកវិទ្យាសាស្ត្របច្ចុប្បន្ន រៀនធ្វើតាមមិនទាន់កើត។ កែវនេះនៅជាប់នឹងចក្ខុវិញ្ញាណរបស់សត្វរុយទើបរុយនេះមានវិញ្ញាណអាចចាប់រូបនានាបានច្បាស់ បានរហ័សបំផុតក្នុងរយៈពេលត្រឹម១ភាគរយ (១/១០០) នៃវិនាទីប៉ុណ្ណោះ។ ឯវិញ្ញាណមនុស្សយើងចាញ់សត្វ ១០ ដង គឺចក្ខុវិញ្ញាណមនុស្សចាប់រូបនានាបានក្នុងរយៈពេល១ភាគដប់ (១/១០) នៃវិនាទី។

ពួកសត្វឃ្មុំ ឪម៉ាល់ និងសត្វកន្ទុំរុយជាដើម សុទ្ធតែមានចក្ខុវិញ្ញាណលើសពីវិស័យរំពើក (Fréquence) នៃពន្លឺ។ ឃើញថា ពូកែជាងភ្នែកមនុស្សឆ្ងាយណាស់។

អំពីសោតវិញ្ញាណច្បាស់របស់ពួកសត្វ អ្នកវិទ្យាសាស្ត្រមួយក្រុម បានសិក្សាពីសត្វឆ្កែ ឆ្កែនោះបានបង្រៀនឲ្យដឹងថា វាមានសោតវិញ្ញាណពូកែជាងមនុស្សឆ្ងាយណាស់ ក្នុងពេលមនុស្សស្ដាប់មិនឮសោះ វាអាចស្ដាប់ឮបានច្បាស់ នូវសូរដែលមានវិស័យរំពើក (Fréquence) ២៥ ពាន់សិកក្នុង ១ វិនាទី។ តមកគេបានសិក្សាពីសត្វល្អិតផ្សេងៗទៀត មានមូសជាដើម សត្វទាំងនោះបានបង្រៀនអ្នកវិទ្យាសាស្ត្រឲ្យដឹងថា ពួកវាមានសោតវិញ្ញាណ ពូកែជាងសត្វ


www.elibraryofcambodia.org

ផ្កែយ៉ាងក្រៃលែងអាចឮសម្រិបជាចលនាទៀងពេល នៃទម្រស្ទរ (Substrat) ដែលមាន កម្រិត១ភាគពាន់ (១/១.០០០) នៃមីល្លីម៉ែត្រ។ ឃើញថាពូកែជាងត្រចៀកមនុស្សឆ្ងាយណាស់។

អំពីឃានវិញ្ញាណច្បាស់របស់ពួកសត្វ លោក Melle (ម៉ែល) បានសិក្សាពីសត្វមេអំបៅឈ្មោលប្រភេទ Arctias Selene (អាកត្យា សេលេនេ) មេអំបៅនេះបានបង្រៀនលោកឲ្យបានដឹងថា វាអាចដឹងក្លិនញីវា ដែលនៅឆ្ងាយពីខ្លួនចំនួន ១១ គីឡូម៉ែត្របាន ដោយវាធុំក្លិន ដែលផ្សាយចេញពីក្រពេញ (Glende) របស់ញី។ ក្រពេញនេះតូចពេកណាស់មានក្លិនយ៉ាងតិចបំផុត ប្រហែល ១ អណូ (Molécule) ក្នុងខ្យល់ ១ម៉ែត្រគូប។ ឃើញថា ពូកែជាងច្រមុះមនុស្សឆ្ងាយណាស់ ។ល។

ពួកអ្នកវិទ្យាសាស្ត្រ ដែលបានសិក្សាពួកសត្វជាគ្រូមានការចេះដឹងយ៉ាងនេះហើយ ទើបដឹង ស្គាល់ សមត្ថភាពសត្វបានសសើរថា គួរឲ្យកោតណាស់ចំពោះពួកសត្វ ព្រោះវាមានប្រដាប់វិទ្យាសាស្ត្រយ៉ាងវិសេស ដែលធម្មជាតិផ្តល់ឲ្យវា វាអាចវាស់ភាពប្រែប្រួលនៃ ចុម្ពិតពល (Magnétique) ផែនដីបានស្មើនិងលើសពី រង្វាស់ចុម្ពិតពល (Magnétomètre) ដែលពួកមនុស្សបានបង្កើតដោយពិបាកនោះទៅទៀត។ ប្រដាប់ពង្រីកពេល និងសមត្ថភាពវិញ្ញាណរបស់ពួកសត្វនេះឃើញថា មានគុណភាពលើសពីចំណេះមនុស្សឆ្ងាយសែនឆ្ងាយ។

ម្យ៉ាងទៀត ពួកមនុស្ស មិនគ្រាន់តែពឹងពាក់សុំរៀនវិទ្យាសាស្ត្រប្លែកៗពីពួកសត្វទេ សូម្បីទៅស្ថានព្រះចន្ទ ក៏បានពឹងសមត្ថភាពសត្វស្វានិងឆ្កែ ឲ្យឡើងទៅស្ទង់ស្ថានការណ៍មើលជាមុន ដើម្បីឲ្យសត្វទាំងនោះប្រាប់ថា ពួកមនុស្សអាចទៅបានឬមិនបានដែរ។

សត្វតិរច្ឆាន មានលក្ខណៈវិសេសប្លែកៗជាច្រើនដែលមានលក្ខណៈខ្លះជឿនលឿនហួសពីការចេះដឹងរបស់មនុស្ស ក្នុងសម័យស្ថានព្រះចន្ទនេះឯង ជាអារ្យធម៌នៃពួកសត្វ។ អារ្យធម៌នេះកើតពីធម្មជាតិ។


www.elibraryofcambodia.org

រីឯពពួកមនុស្ស មកពីមានចិត្តចង់ពង្រីកអារ្យធម៌របស់ខ្លួនឲ្យបានជឿនលឿន កុំឲ្យចាញ់អារ្យធម៌របស់ពួកសត្វនេះឯង ទើបខំបង្កើតមន្ទីរពិសោធ ខាងធម្មជាតិវិទ្យា និងគីមីវិទ្យាជាដើម ហើយចាប់យកសត្វមកធ្វើជាគ្រូ ដើម្បីសិក្សារៀនចម្លងយកវិទ្យាសាស្ត្រ វិសេស ជឿនលឿនពីពួកសត្វ ដែលធម្មជាតិបានផ្តល់ឲ្យវា។

នេះជាចម្លើយ តាមការស្រាវជ្រាវជាក់ច្បាស់ សម្រាប់ដោះស្រាយនូវចម្ងល់ថា សត្វតិរច្ឆានមានអារ្យធម៌ ឬមិនមាននោះឯង។

(ចប់ទំព័រវែកញែក)

១៨

CAMBODIAN EDUCATION EXCELLENCE
មូលនិធិខ្មែរសម្រាប់ការសិក្សា
FOUNDATION


www.elibraryofcambodia.org

# ទំព័រចលនាអារ្យធម៌

ដើម្បីស្គាល់ច្បាស់នូវរូបរាង និងន័យពិតប្រាកដរបស់ពាក្យថា «អារ្យធម៌» នោះ គេអាចស្គាល់បានតាមប្រភេទ (Catégorie) និងតាមវិភាគ (Analyse) នៃអារ្យធម៌។

ប្រភេទនិងវិភាគនៃអារ្យធម៌នោះ ខ្ញុំនឹងចងក្រងសរសេរទុកជារបៀបមួយ តាមក្បួនច្បាប់ដែលបានជួបប្រទះ និងបានត្រិះរិះស្រាវជ្រាវរាវរកឃើញ។

ក្នុងសំណេរនេះ ខ្ញុំចែកជាពីរសង្កាត់គឺ សង្កាត់ទី ១ ជាអត្ថបទ (Texte) ប្រាប់មុខវិជ្ជាខ្លីៗ ដែលត្រូវសិក្សាអំពីអារ្យធម៌ សង្កាត់ទី ២ ជាអត្ថាធិប្បាយ (Commentaire) និយាយបួរបាច់ពន្យល់ន័យតាមមុខវិជ្ជានោះៗ ដើម្បីឲ្យងាយស្រួលដល់អ្នកសិក្សា និងអ្នកអានទូទៅ។

១៧

CAMBODIAN EDUCATION EXCELLENCE
មូលនិធិខ្មែរសម្រាប់ការសិក្សា
FOUNDATION


www.elibraryofcambodia.org

សង្កាត់ទី ១

## ផ្នែកអត្ថបទ (Texte)

ជាបឋម សូមជ្រាប អំពីពាក្យថា «ចលនាអារ្យធម៌» ដែលជាឈ្មោះសៀវភៅនេះសិន។

ចលនា (Mouvement) ការកម្រើក រំពើក ឬដំណើររវើកជានិច្ច គឺគ្មានភាពប្រក្រតី។

អារ្យធម៌ ធម៌ដែលនាំឲ្យកើតសេចក្ដីសុខចម្រើន ទំនៀមទម្លាប់ល្អ សណ្ដាប់ធ្នាប់ ឬបែបបទរៀបរយ។ ពាក្យខ្មែរក្លាយពីបរទេសថា ស៊ីវិល្យៃ។

រួមសព្ទទាំងពីរចូលគ្នា មានន័យថា រំពើកនៃធម៌ដែលនាំឲ្យកើតសេចក្ដីសុខចម្រើន បានដល់ការវិវត្តន៍ទៅនៃអារ្យធម៌ តាមនិន្នាការ (Tendance) នៃមនុស្សក្នុងកាលៈទេសៈមួយៗ គឺក្នុងកាលៈទេសៈណា ដែលពួកមនុស្សបរិបូណ៌ដោយសីលធម៌ មនុស្សធម៌ សុជីវធម៌ វប្បធម៌ និងវឌ្ឍនធម៌ ក្នុងកាលៈទេសៈនោះ អារ្យធម៌បានចម្រើនរុងរឿង មានឧត្តមភាពខ្ពង់ខ្ពស់អាចផ្ដល់សុខសន្តិភាពចម្រើនរុងរឿងឲ្យមនុស្សបានគ្រប់គ្រាន់តាមសេចក្ដីប្រាថ្នា។ បើក្នុងកាលៈទេសៈណា មនុស្សខ្វះសីលធម៌ជាដើមហើយ ក្នុងកាលៈទេសៈនោះ អារ្យធម៌តែងធ្លាក់ចុះទន់ខ្សោយ មិនអាចផ្ដល់សេចក្ដីសុខចម្រើនពិតប្រាកដឲ្យមនុស្សបានឡើយ។

ការនៅមិនស្ងៀម ចេះតែបែរវេឡើងចុះ នៃអារ្យធម៌បែបនេះឯង ឈ្មោះថា «ចលនាអារ្យធម៌» ដែលជាឈ្មោះសៀវភៅនេះ និយាយអំពីការឡើងចុះនៃអារ្យធម៌នោះឯង។

FOUNDATION

## ប្រភេទនៃអារ្យធម៌មាន ៤

១- អាចារៈ (Comportement) គំនិតមារយាទត្រឹមត្រូវល្អ ប្រាសចាកមិច្ឆាចារ

២- ទស្សនីយភាវៈ (Spectocle) ភាពនៃឥរិយាបថរូបឆោម និងទីឋានសមរម្យល្អ គួរឲ្យចង់មើលចង់ឃើញ

៣- លិង្គៈ (Genre) ភេទសមរម្យ តាមបែបបទបុរសស្ត្រី

៤- សមត្ថភាវៈ (Capacité) ភាពអង់អាចដោយចំណេះវិជ្ជា ការចេះដឹងវៃឆ្លាត។

ទាំង ៤ ប្រភេទនេះ ឈ្មោះថាអារ្យធម៌ដូចគ្នា មនុស្សណា មានចិត្តគំនិតកាយវិការប្រកបដោយប្រភេទណាមួយហើយ មនុស្សនោះឈ្មោះថា អារ្យជនបានគ្រាន់តែមានឋានៈខ្ពង់ខ្ពស់ និងថោកទាប តាមគុណភាពនៃប្រភេទប៉ុណ្ណោះ។

អារ្យធម៌ទាំង ៤ នេះ មានចែកជាអនុប្រភេទទៅទៀត។


www.elibraryofcambodia.org

# អនុប្រភេទនៃអារ្យធម៌

អាចារៈចែកជា ៣

ក) ប្រព្រឹត្តិល្អដោយកាយ ធ្វើតែអំពើល្អ

ខ) ប្រព្រឹត្តិល្អ ដោយវាចា និយាយតែសម្តីល្អ

គ) ប្រព្រឹត្តិល្អ ដោយចិត្ត មានចិត្តគំនិតល្អ។

ទស្សនីយភាវៈចែកជា ២

ក) ទិដ្ឋភាពនៃឥរិយាបថ និងរូបឆោមល្អសមរម្យ

ខ) ទិដ្ឋភាពនៃទីឋាន មានរបៀបរបបត្រឹមត្រូវ។

លិង្គៈចែកជា ២

ក) ភេទសមរម្យតាមបែបបទបុរស

ខ) ភេទសមរម្យតាមបែបបទស្ត្រី។

សមត្ថភាវៈចែកជា ២

ក) សមត្ថភាពខាងវិជ្ជាអក្សរសាស្ត្រ (Litérature)

ខ) សមត្ថភាពខាងវិជ្ជាបច្ចេកទេស (Technique)

ប្រភេទ និងអនុប្រភេទ នៃអារ្យធម៌ទាំងអស់នេះកើតមានឡើងដោយអាស្រ័យមូលធម៌ដែលហៅថា មូលនៃអារ្យធម៌។

## មូលធម៌មាន ៥

១- សីលធម៌ (Moralité) ហេតុដែលនាំឲ្យចៀសវាងនូវអំពើអាក្រក់ ធ្វើតែអំពើល្អ តាមដំបូន្មានតាមវិនយប្បញ្ញត្តិ

២- មនុស្សធម៌ (Humanité) ច្បាប់ប្រដៅមនុស្សឲ្យប្រព្រឹត្តសុចរិតត្រឹមត្រូវតាមឋានៈជាមនុស្ស

៣- សុជីវធម៌ (Savoir-vive) ច្បាប់រស់នៅសមរម្យតាមរបៀបមនុស្ស

៤- វប្បធម៌ (Culture) ការផ្សាំបណ្តុះចរិយាមារយាទ និងចំណេះវិជ្ជាប្រាជ្ញាស្មារតីឲ្យបានចម្រើនលូតលាស់

៥- វឌ្ឍនធម៌ (Progrès) ភាវៈនៃសេចក្តីចម្រើនលូតលាស់


www.elibraryofcambodia.org

# អត្ថ និងប្រភេទនៃមូលធម៌

សីលធម៌មាន ២

១) មេត្តា (Bien veillance) ចង់ឲ្យគេបានសុខចម្រើន មេត្តានេះ កម្ចាត់បង់បាននូវព្យាបាទ (Haine) គឺទោសចិត្តដែលនាំឲ្យចងគំនុំគុំគួនអ្នកដទៃ។

២) ករុណា (Compassion) ចង់ឲ្យគេរួចចាកទុក្ខ ករុណានេះ កម្ចាត់បង់បាននូវវិហឹង្សា (Violence) គឺការឃោឃៅ ការប្រើកម្លាំងប្រឆាំងនឹងច្បាប់ និងសិទ្ធិ ការធ្វើនូវទារុណកម្មយ៉ាងកំណាច។

មេត្តានិងករុណាទាំង ២ នេះឯង ឈ្មោះថាសីលធម៌ មនុស្សមានមេត្តាករុណាចំពោះអ្នកដទៃ ឈ្មោះថាមនុស្សមានសីលធម៌។ ដទៃពីនេះ មិនមែនជាសីលធម៌ឡើយ។

# មនុស្សធម៌

គ្រឿណមដែលមនុស្សមិនគួរធ្វើមាន ៥

១) បាណាតិបាត (Tuerie) ការបៀតបៀនចំពោះជីវិតរូបកាយ ឲ្យមានរបួសស្លាកស្នាម ឬឲ្យស្លាប់។ អំពើនេះមនុស្សជាតិគប្បីវៀរ កុំអោយមានទម្លាប់អាក្រក់ ជាបុរសឃាតករ ឬជាស្ត្រីឃាតការិនី ព្រោះអ្នកដទៃ គេចង់សុខចង់រស់ដូចយើងដែរ។

២) អទិន្នាទាន (Vol) ការលួចប្លន់ មានលួចទឹកដីទ្រព្យសម្បត្តិ និងការបន្លំលួច មានរត់គយ សូក ស៊ីសំណូក កេងកីបជាដើម។ អំពើនេះ មនុស្សជាតិគប្បីវៀរ កុំឲ្យមានទម្លាប់អាក្រក់ ជាបុរសលួច ឬជាស្ត្រីលួច ព្រោះអ្នកដទៃគេចង់មាន ចង់បាន មិនចង់ឲ្យខូចខាតបាត់បង់អ្វីៗ ដូចយើងដែរ។

៣) កាមេសុ មិច្ឆាចារ (Trahison à son conjoint) ការផិតក្បត់ចំពោះស្វាមីភរិយា។ អំពើនេះមនុស្សជាតិ គប្បីវៀរកុំឲ្យមានទម្លាប់អាក្រក់ ជាបុរសក្បត់ភរិយា ឬជាស្ត្រីផិតស្វាមី ព្រោះអ្នកដទៃ គេស្រឡាញ់ស្វាមីភរិយាដូចយើងដែរ។

៤) មុសាវាទ (Mensonge) ការនិយាយពាក្យមិនពិត កុហក បោកបញ្ឆោត។ អំពើនេះ មនុស្សជាតិគប្បីវៀរកុំឲ្យមានទម្លាប់អាក្រក់ ជាបុរសជើងបោក ឬជាស្ត្រីជើងបោក ព្រោះអ្នកដទៃគេមានការក្តៅក្រហាយចិត្ត ដោយការចាញ់បោកដូចយើងដែរ។

៥) សុរាមេរ័យ (Ivresse) ការផឹកនូវទឹកស្រវឹងឬជក់នូវគ្រឿងពុលញៀន ដែលនាំឲ្យខូចសតិស្មារតី បាត់លក្ខណៈមនុស្ស។ អំពីនេះមនុស្សជាតិគប្បីវៀរ


www.elibraryofcambodia.org

កុំឲ្យមានទម្លាប់អាក្រក់ជាបុរសប្រមឹក ឬជាស្ត្រីប្រមឹក ព្រោះជាអំពើញ៉ាំងចិត្តមនុស្សឲ្យសាហាវ ក្លើតក្លើន ហ៊ានប្រព្រឹត្តធ្វើបំពាននូវគ្រឿងណមទាំង ៤ ខាងដើម។

អ្នកតមនូវគ្រឿងណមទាំង ៥ នេះបាន ឈ្មោះថា អ្នកមានមនុស្សធម៌ គឺមានលក្ខណៈជាមនុស្សពិតប្រាកដ សមតាមរូបកាយមុខមាត់ជាមនុស្ស ដទៃពីនេះ មិនមែនជាមនុស្សធម៌ឡើយ។

## សុជីវធម៌

ច្បាប់រស់នៅតាមរបៀបមនុស្សមាន ៦

១) ការស្គាល់ហេតុផលគួរមិនគួ

២) ការស្គាល់ឋានៈខ្លួននិងអ្នកដទៃ

៣) ការស្គាល់ប្រមាណជីវភាព

៤) ការស្គាល់កាលសម័យ

៥) ការស្គាល់ប្រជុំជននិងទីប្រជុំ

៦) ការស្គាល់មិត្រសម្លាញ់។

សុជីវធម៌នេះ ខ្ញុំបានសរសេរ អធិប្បាយសព្វគ្រប់ចំនួន ២៥០ ទំព័រ ក្នុងសៀវភៅ «សុជីវធម៌ប្រចាំសង្គមគ្រួសារ» ដែលមានឈ្មោះ សុង-ស៊ីវ ខ្ញុំជាអ្នកនិពន្ធ។ បើចង់ជ្រាបឲ្យបានច្បាស់លាស់សូមអានសៀវភៅនោះចុះ។

## វប្បធម៌មាន៤ប្រភេទ

១) អាចារវប្បៈ (Culture comportement) ការផ្សាំបណ្តុះអាចារៈ គឺចរិយាមារយាទល្អត្រឹមត្រូវឲ្យកើតមានឡើង ដោយការហ្វឹកហាត់ តាមសីលធម៌ និងមនុស្សធម៌។ អាចារវប្បៈនេះ កើតមានឡើងតាមវិធាន ៤ យ៉ាង គឺ តាមកម្មវិធីសិក្សាជាតិ ១ តាមអក្សរសាស្ត្រ ១ តាមសិល្បៈ ១ និងតាមលទ្ធិសាសនា ១។

២) ទស្សនីយភាវវប្បៈ (Culture Spectocle) ការបណ្តុះបណ្តាលទស្សនីយភាពឲ្យកើតមានឡើងដោយអនុវត្តន៍តាមសុជីវធម៌។ ទស្សនីយភាវវប្បៈនេះ កើតមានឡើងតាមវិធាន ៥ យ៉ាង គឺតាមកម្មវិធីសិក្សាជាតិ ១ តាមអក្សរសាស្ត្រ ១ តាមសិល្បៈ ១ តាមលទ្ធិសាសនា ១ និងតាមក្បួនបច្ចេកទេស ១។

៣) លិង្គវប្បៈ (Culture de genre) ការបណ្តុះបណ្តាលភេទសមរម្យ តាមបែបបទបុរសស្ត្រី ដោយអនុវត្តន៍តាមសុជីវធម៌។ លិង្គវប្បៈនេះ កើតមានឡើងតាមវិធាន ៥ យ៉ាង


www.elibraryofcambodia.org

គឺតាមកម្មវិធីសិក្សាជាតិ ១ តាមអក្សរសាស្ត្រ ១ តាមសិល្បៈ ១ និងតាមលទ្ធិសាសនា ១ និងតាមក្បួនបច្ចេកទេសផ្នែកហត្ថកោសល្យ ១។

៤) បញ្ញាវប្បៈ (Culture intellectuelle) ការផ្សាំបណ្ដុះប្រាជ្ញាស្មារតី ដោយការសិក្សានូវវិជ្ជាផ្សេងៗ មានវិទ្យាសាស្ត្រជាដើម។ បញ្ញាវប្បៈនេះ ហៅថា វិជ្ជាវប្បៈ ដូច្នេះក៏បាន កើតមានឡើងតាមវិធាន ៤ យ៉ាង គឺ តាមអង្គការសិក្សាធិការជាតិ ១ តាមអក្សរសាស្ត្រ ១ តាមសិល្បៈ ១ និងតាមលទ្ធិសាសនា ១។

## វឌ្ឍនធម៌មាន ៤ ប្រភេទ

១) អាចារវឌ្ឍនៈ (Progrès comportement) ភាវៈនៃសេចក្ដីចម្រើនល្អតលាស់នូវចរិយាមារយាទល្អ

២) ទស្សនីយការវឌ្ឍនៈ (Progrès Spectocle) ភាវៈនៃសេចក្ដីចម្រើនល្អតលាស់នូវទស្សនីយភាព

៣- លិង្គវឌ្ឍនៈ (Progrès de genre) ភាវៈនៃសេចក្ដីចម្រើនល្អតលាស់នៃភេទសមរម្យ

៤- បញ្ញាវឌ្ឍនៈ (Progrès intellectuelle) ភាវៈនៃសេចក្ដីចម្រើនល្អតលាស់ នូវប្រាជ្ញាការចេះដឹងវៃឆ្លាត។

ពាក្យថា វប្បធម៌ និងវឌ្ឍនធម៌នេះ មានប្រភេទនិងន័យជាមួយគ្នា គ្រាន់តែផ្សេងដោយហេតុនិងផលប៉ុណ្ណោះ គឺវប្បធម៌ជាហេតុ វឌ្ឍនធម៌ជាផល។

## វិភាគនៃមូលធម៌ និងអារ្យធម៌

ដើម្បីស្គាល់ឫសគល់ និងព្រំដែននៃអារ្យធម៌មួយៗនោះ អាចស្គាល់បានតាមវិភាគដូចខាងក្រោម ៖

- អារ្យធម៌ទី ១ គឺ អាចារៈ កើតឡើងពេញជាអារ្យធម៌ត្រឹមត្រូវបាន ដោយមានសីលធម៌ទាំង ២ មនុស្សធម៌ទាំង ៤ និងអចារវប្បៈ អាចារវឌ្ឍនៈ ជាមូលធម៌។

- អារ្យធម៌ទី ២ គឺ ទស្សនីយភាវៈ កើតឡើងពេញជាអារ្យធម៌បាន ដោយមានសុជីវធម៌ និង ទស្សនីយភាវប្បៈ ទស្សនីយភាវឌ្ឍនៈ ជាមូលធម៌។

- អារ្យធម៌ទី ៣ លិង្គៈ កើតឡើងពេញជាអារ្យធម៌បាន ដោយមានសុជីវធម៌ និងលិង្គវប្បៈ លិង្គវឌ្ឍនៈ ជាមូលធម៌។

- អារ្យធម៌ទី ៤ គឺ សមត្ថភាវៈ កើតឡើងពេញជាអារ្យធម៌បាន ដោយមានបញ្ញាវប្បៈ និងបញ្ញាវឌ្ឍនៈជាមូលធម៌។


www.elibraryofcambodia.org

បណ្តាអារ្យធម៌ទាំង ៤ នេះ ទី ១ គឺ អាចារៈ ជាអារ្យធម៌ថ្នាក់ខ្ពស់បំផុត អាចផ្តល់បំណងមនុស្សលោក គឺ សុខសន្តិភាពឲ្យពួកមនុស្សបានពិតប្រាកដ។ អារ្យធម៌នេះមិនសូវមានក្នុងលោកឡើយ បច្ចុប្បន្ននេះ រឹតតែខ្វះខាតណាស់ទៅទៀត មានច្រើនតែអារ្យធម៌ ទី ២ ទី ៣ និងទី ៤ ដែលជាថ្នាក់បន្ទាប់បន្សំប៉ុណ្ណោះ ព្រោះបច្ចុប្បន្ននេះ សីលធម៌និងមនុស្សធម៌ពិតប្រាកដមែនទែននោះ មិនសូវមានក្នុងលោកឡើយ។

## នាទីអារ្យធម៌

- អារ្យធម៌ទី ១ មាននាទីបង្កើត សាមគ្គីធម៌ និងសុខសន្តិភាព។

- អារ្យធម៌ទី ២ មាននាទីរៀបចំឥរិយាបថ រូបឆោមសមរម្យ និងរៀបចំទីឋានមានរបៀបត្រឹមត្រូវ។

- អារ្យធម៌ទី ៣ មាននាទីរៀបចំភេទបុរសស្ត្រីឲ្យមានបែបបទ។

- អារ្យធម៌ទី ៤ មាននាទីរៀបចំលក្ខណៈវប្បធម៌និងរៀបចំ លក្ខណៈសង្គមធម៌។

នាទី ទី ២ ទី ៣ ទី ៤ កើតមានឡើងបានអាស្រ័យដោយនាទី ទី ១ ព្រោះថាក្នុងប្រទេសជាតិមួយៗ បើគ្មានសុខសន្តិភាព និងសាមគ្គីធម៌ ជាបឋមទេ សេចក្តីចម្រើនល្អតលាស់ក៏គ្មានដែរ។

## អាយុជីវិតនៃអារ្យធម៌

អារ្យធម៌របស់ជាតិមួយៗក្នុងលោក ដែលមានអាយុជីវិតរស់នៅ មានឥទ្ធិពលបាន អាស្រ័យដោយពលរដ្ឋមានសម្បជញ្ញជាតិ (Conscience nationale) គឺការមិនវង្វេងភ្លេចជាតិខ្លួន មានជាតិមនសិការ ចេះស្រឡាញ់ជាតិកំណើត មិនមានចិត្តចើក សារ៉ាត្រេកត្រអាលតាមអារ្យធម៌បរទេស។

សម្បជញ្ញជាតិនេះ កើតមានឡើងបាន អាស្រ័យដោយពលរដ្ឋម្នាក់ៗ ចេះប្រៀបធៀបខ្លួនទៅនឹងជនបរទេសឲ្យឃើញសភាវៈពិតច្បាស់ថា « គេនឹងអញមានជាតិផ្សេងគ្នា បើគេចេះស្រឡាញ់ជាតិគេ អញត្រូវចេះស្រឡាញ់ជាតិអញដែរ គេខំបម្រើមនោគមវិជ្ជាជាតិគេ អញត្រូវខំបម្រើមនោគមវិជ្ជាជាតិអញដែរ គេខំពង្រីកអារ្យធម៌ជាតិគេ អញត្រូវខំពង្រីកអារ្យធម៌អញដែរ ។ល។ បើអញឆោតល្ងង់ ឥតគំនិតទៅជួយស្រលាញ់ជាតិគេ ជួយបម្រើមនោគមវិជ្ជាជាតិគេ ជួយពង្រីកអារ្យធម៌ជាតិគេ អញជាសត្វពាហណៈសម្រាប់បម្រើគេ ខ្ញុំកញ្ជះគេទៅហើយ។


www.elibraryofcambodia.org

កាលបើពលរដ្ឋម្នាក់ៗ មានគំនិតមារយាទល្អ ចេះប្រៀបធៀបខ្លួននឹងជនបរទេស តាមហេតុផលជាសច្ចៈយ៉ាងនេះហើយ សម្បជញ្ញជាតិ ក៏កើតមានឡើង ចេះស្រឡាញ់ជាតិខ្លួនពិតប្រាកដ។

(ចប់អារ្យធម៌ផ្នែកលោកនិយម)

FOUNDATION


www.elibraryofcambodia.org

# អារ្យធម៌ផ្នែកពុទ្ធសាសនា

អារ្យធម៌របស់បព្វជិតអ្នកបួសក្នុងពុទ្ធសាសនា ក៏មាន ៤ ប្រភេទដែរគឺ ៖

១- អាចារារ្យ អ្នកមានចរិយាមារយាទល្អត្រឹមត្រូវតាមវិន័យសិក្ខាពុទ្ធសាសនា

២- ទស្សនារ្យ អ្នកមានរូបឆោមលោមពណ៌ល្អពីកំណើត និងអ្នកមានអនាម័យ ចេះរៀបចំសម្អាត គ្រឿងឧបភោគបរិភោគ មានការសម្អាត ស្បង់ ចីពរ បាត្រ កុដិ វិហារ ទីវត្តអារាមជាដើម និងមានឥរិយាបថស្រគត់ស្រគំនាំឲ្យកើតសេចក្ដីជ្រះថ្លា គួរឲ្យចង់មើល ចង់ឃើញ

៣- លិង្គារ្យ បព្វជិតដែលល្អតែភេទ ប្រុងប្រយ័ត្ន តែត្រង់ការស្លៀកពាក់ដណ្ដប់ឲ្យត្រឹមត្រូវតាមបែបបទសមណសារូប ប៉ុន្តែជាមនុស្សទ្រុស្តសីល

៤- បដិវេធារ្យ លោកអ្នកបានសម្រេចលោកុត្តរធម៌ គឺមគ្គ ៤ ផល ៤ និព្វាន ១។ បើមិនដល់ថ្នាក់ខ្ពស់នេះទេ គ្រាន់តែបានចេះដឹងច្បាស់លាស់នូវព្រះបរិយត្តិធម៌ ឬបានធ្វើចិត្តឲ្យស្ងប់រម្ងាប់ តាមវិបស្សនាធម៌ ក៏សង្គ្រោះចូលក្នុងអារ្យធម៌ទី ៤ នេះដែរ។

(ចប់សង្កាត់ទី ១ ផ្នែកអត្ថបទ Texte )

៩៧៨

មូលនិធិខ្មែរសម្រាប់ការសិក្សា FOUNDATION


www.elibraryofcambodia.org

សង្កាត់ទី២

# ផ្នែកអត្ថាធិប្បាយ (Commentaire)

ក្នុងសង្កាត់នេះ ខ្ញុំអធិប្បាយបំបែកជាពីរ គឺ៖

១- អារ្យធម៌សាកល

២- អារ្យធម៌ខ្មែរ។

ផ្នែកអារ្យធម៌សាកល ខ្ញុំអធិប្បាយទូទៅ មិនចំពោះ លក្ខណៈអារ្យធម៌របស់បុគ្គលណា ជាតិសាសន៍ណាឡើយ បញ្ជាក់តែអំពីគុណសម្បត្តិ នៃអារ្យជន (Civilisateur) និងគុណវិបត្តិ នៃអនារ្យជន (Barbare) តែប៉ុណ្ណោះ ដើម្បីកុំឲ្យប៉ះពាល់ដល់រូបបុគ្គល ដល់ជាតិសាសន៍នានា។ ឯលក្ខណៈវប្បធម៌ និងលក្ខណៈសង្គមធម៌ នឹងមានអធិប្បាយសព្វគ្រប់ក្នុងអារ្យធម៌ខ្មែរ។

## អារ្យធម៌សាកល

**អារ្យធម៌ប្រភេទទី ១- អាចារៈ** ការប្រព្រឹត្ត ចរិយា ឫកពារ មារយាទល្អត្រឹមត្រូវ បានដល់សកម្មភាពនៃកាយ វាចា ចិត្ត ល្អប្រពៃ របស់មនុស្សក្នុងពិភពលោក គឺអំពើណាដែលប្រព្រឹត្តធ្វើទៅហើយ បានសុខចំពោះខ្លួនផងមិនបៀតបៀនរំលោភលើច្បាប់ លើសិទ្ធិអ្នកដទៃផង ជាអំពើរបស់មនុស្ស ដែលមានសីលធម៌ និងមនុស្សធម៌។

អ្នកមានសីលធម៌ និងមនុស្សធម៌ តែងធ្វើនូវអ្វីៗត្រឹមត្រូវស្របតាមច្បាប់ជាតិ និងអន្តរជាតិជានិច្ច ព្រោះក្នុងរដ្ឋមួយៗ សុទ្ធតែមានច្បាប់ប្រចាំរដ្ឋ ដូចច្បាប់រដ្ឋប្បវេណី ក្រមព្រហ្មទណ្ឌ រដ្ឋធម្មនុញ្ញ និងច្បាប់សាសនាជាដើម។

ការប្រព្រឹត្តត្រឹមត្រូវតាមច្បាប់ទាំងអស់នេះឯង ឈ្មោះថាអាចារៈ ជាអារ្យធម៌ទី ១។

អារ្យធម៌ទី ១ នេះ កើតឡើងក្នុងលោក ក្នុងរដ្ឋមួយៗបានអាស្រ័យពលលោក ពលរដ្ឋ មានចិត្តគំនិតប្រកបដោយសីលធម៌ និងមនុស្សធម៌។

- ផ្នែកសីលធម៌ ពលលោក ពលរដ្ឋម្នាក់ៗ ត្រូវមានចិត្តគំនិតប្រកបដោយមេត្តា ចង់ឲ្យអ្នកដទៃបានសុខចម្រើនលះបង់នូវការចងគំនុំគុំគួនព្យាបាទ និងករុណា ចង់ឲ្យអ្នកដទៃរួចចាកទុក្ខ លះបង់នូវវិហឹង្សា ការឃោរឃៅ ប្រើកម្លាំងប្រឆាំងនឹងច្បាប់ នឹងសិទ្ធិអ្នកដទៃ។

ពាក្យថា «សីលធម៌» (Moralité) នេះ តាមមតិជាតិ និងអន្តរជាតិខ្លះយល់ថា «ដំបូន្មាន ឬវិនយប្បញ្ញត្តិ ដែលនាំឲ្យមានរបៀបបែបបទ សណ្តាប់ធ្នាប់» ការយល់បែបនេះ មិនត្រូវចំតួសីលធម៌ឡើយ មានន័យរលាយចូលគ្នាទៅក្នុងពាក្យថា មនុស្សធម៌


www.elibraryofcambodia.org

និងសុជីវធម៌ទៅវិញ ព្រោះសីលធម៌នេះ ជាតួហេតុ នាំឲ្យមនុស្សចេះគោរពប្រតិបត្តិតាម ជំបូន្មាន ឬវិនយប្បញ្ញត្តិ ដែលនាំឲ្យមានរបៀបបែបបទ សណ្តាប់ធ្នាប់ល្អ មិនមែនជាតួជំបូន្មាន ជាតួវិនយប្បញ្ញត្តិនោះទេ។

ដើម្បីងាយយល់អំពីន័យ របស់សីលធម៌នេះ សូមចំណាំថា «សីលគឺជាច្បាប់ ធម៌គឺហេតុ» បានដល់ហេតុដែលនាំឲ្យមនុស្សចេះគោរពប្រតិបត្តិតាមច្បាប់។

ពាក្យថាហេតុ គឺ ចិត្តគំនិតល្អ ចង់ឲ្យអ្នកដទៃបានសុខចម្រើន បានរួចចាកទុក្ខ ដែលខ្មែរយើងធ្លាប់និយាយថា មេត្តាករុណា មនុស្សមានមេត្តា ករុណា ជាអ្នកមានចិត្តគំនិតល្អ ស្អាត មិនមានព្យាបាទ និងវិហឹង្សា អាចគោរពប្រតិបត្តិតាមជំបូន្មាន តាមវិនយប្បញ្ញត្តិ ដែលនាំឲ្យមានរបៀបបែបបទសណ្តាប់ធ្នាប់ល្អ បានត្រឹមត្រូវ គឺអាចប្រព្រឹត្តិតាមច្បាប់ជាតិ និងអន្តរជាតិបានពិតប្រាកដ។

ពាក្យថាសីលធម៌នេះ ច្រើននិយាយច្រឡំនឹងពាក្យថា មនុស្សធម៌ និងសុជីវធម៌ ដូចពាក្យថា «កុមារនេះមានសណ្តាប់ធ្នាប់ល្អ ជាក្មេងមានសីលធម៌» ប្រយោគនេះ គួរនិយាយថា «ជាក្មេងមានសុជីវធម៌វិញ ទើបត្រូវជាង ព្រោះជាក្មេងមានរបៀបល្អក្នុងការរស់នៅ។

ខ្លះនិយាយថា «អង្គការជួយសង្គ្រោះមនុស្សទូទៅអង្គការប្រកបដោយមនុស្សធម៌» ប្រយោគនេះគួរនិយាយថា ជាអង្គការប្រកបដោយសីលធម៌វិញ ទើបត្រូវល្អជាង ព្រោះសីលអមិ គឺមេត្តា ករុណា ដែលចង់ឲ្យអ្នកដទៃ បានសុខរួចចាកទុក្ខ ទើបខំជួយសង្គ្រោះគ្នា។ ឯមនុស្សធម៌ គឺត្រណម ដែលមនុស្សម្នាក់ៗត្រូវតែម មិនត្រូវប្រព្រឹត្តធ្វើ ដើម្បីឲ្យសមឋានៈជាមនុស្សមិនមែនជាការសង្គ្រោះឡើយ។

-ផ្នែកមនុស្សធម៌ គឺត្រណមដែលមនុស្សត្រូវតែមមិនត្រូវប្រព្រឹត្តធ្វើ ព្រោះបើប្រព្រឹត្តធ្វើទៅ នាំឲ្យប្រឆាំងនឹងច្បាប់ និងសិទ្ធិអ្នកដទៃ ដូចជា៖

ត្រណមទី ១- បាណាតិបាត ការបៀតបៀនចំពោះរូបកាយអ្នកដទៃ ឲ្យមានរបួសស្លាកស្នាម ឬឲ្យស្លាប់។

ត្រណមនេះ រដ្ឋទាំងឡាយក្នុងលោក សុទ្ធតែមានច្បាប់ហាមឃាត់ដាច់ខាត បើពលរដ្ឋណា ធ្វើប្រឆាំងនឹងច្បាប់នេះ ពលរដ្ឋនោះ អស់សិទ្ធិជាមនុស្សហើយ ត្រូវទទួលទណ្ឌកម្មតាមទោសានុទោស មានប្រហារជីវិតជាដើម ព្រោះជាអ្នកប្រឆាំងនឹងច្បាប់រដ្ឋ នឹងសិទ្ធិអ្នកដទៃ ដែលគេចង់សុខចង់រស់
ដូចខ្លួនដែរ។


www.elibraryofcambodia.org

បាណាតិបាតនេះ ខាងច្បាប់ពុទ្ធសាសនា មានការតឹងតែងជាងច្បាប់រដ្ឋ ព្រោះព្រះសម្ពុទ្ធ ព្រះអង្គប្រកបដោយមហាករុនាទិគុណ ធំទូលាយ ចំពោះសត្វលោកទូទៅមិនរើសមុខ មិនប្រកាន់ឋានៈជីវិតខ្ពង់ខ្ពស់ ថោកទាបឡើយ ព្រះអង្គហាមមិនឲ្យបៀតបៀន កាប់សម្លាប់គ្នាទូទៅ ទាំងជីវិតមនុស្ស និងជីវិតសត្វតិរច្ឆាន ដោយព្រះអង្គជ្រាបច្បាស់ថា សត្វតិរច្ឆាន ក៏មានការភ័យតក់ស្លុត មានការឈឺចាប់ ចង់សុខ ចង់រស់ដូចមនុស្សដែរ មិនគួរប្រមាថ អាងថាគ្នាជាសត្វ មានឋានៈថោកទាបជាមនុស្សហើយបៀតបៀន កាប់សម្លាប់ បំបិទសិទ្ធិឡើយ គួរឲ្យគ្នាមានសិទ្ធិរស់នៅ បានសុខក្នុងលោកនេះផង ព្រោះពិភពលោកនេះ មិនមែនពិភពលោករបស់មនុស្សម្នាក់ឯងទេ គឺជាពិភពលោករបស់សត្វលោកទូទៅ មានមនុស្ស និងសត្វតិរច្ឆានជាដើម។

បើពិចារណាទៅតាមការស្រាវជ្រាវរកឃើញ នូវដើមកំណើតមនុស្ស របស់អ្នកប្រាជ្ញវិទ្យាសាស្ត្រនោះ គឺសត្វតិរច្ឆាននេះឯង ជាម្ចាស់ដើមនៃពិភពលោកនេះ ព្រោះគេរកឃើញថា «មនុស្សកើតមកពីសត្វ» មិនគួរពួកមនុស្សបៀតបៀន បំពារបំពានលើសិទ្ធិសត្វ ចាប់គ្នាចោះខួរស៊ីទាំងរស់ក៏មាន ចាប់ទាំងមេទាំកូនស្ងោរទាំងរស់ក៏មាន កាប់សម្លាប់ចាប់កាច់ករ ស្ងោរអាំង ធ្វើងៀត ធ្វើផ្អកក៏មាន ឃើញថា ពួកមនុស្សដែលមិនមែនជាម្ចាស់ដើមនៃពិភពលោកនេះ ជាមហាឃាតករកំណាច សាហាវឃោរឃៅបំផុតក្នុងលោក ជាងពួកយក្សក្នុងរឿងព្រេងទៅទៀត។

រឿងនេះ ជាចំណុចអាថ៌កំបាំងមួយ កប់បាត់ក្នុងចិត្តគំនិតមនុស្សលោក មិនដឹងថាដល់ទៅសតវត្សរ៍ទីប៉ុន្មាន ទើបមនុស្សលោកលះបង់នូវលទ្ធិអំណាចផ្តាច់ការនេះ ព្រមបើកសិទ្ធិ ឲ្យសត្វតិរច្ឆាន បានស្គាល់លទ្ធិប្រជាធិបតេយ្យផង ព្រោះក្នុងពាក្យថា «ប្រជា» នេះ បើតាមរូបស័ព្ទ មានន័យវែងឆ្ងាយទាក់ទងដល់សត្វតិរច្ឆានផងដែរ។

តាំងពីព្រេងនាយ មកដល់សម័យឋានព្រះចន្ទនេះ មានតែព្រះសម្ពុទ្ធប៉ុណ្ណោះ ដែលបានការពារ និងទាមទារសិទ្ធិ សេរីភាព ពីពួកមនុស្ស តាមច្បាប់សីលធម៌ និងមនុស្សធម៌ ប្រទានដល់សត្វតិរច្ឆាន ក្រៅពីព្រះអង្គចេញ គ្មានសោះឡើយ។

គ្រឿណមទី ២- អទិន្នាទាន ការយកទ្រព្យសម្បត្តិអ្នកដទៃ មានសម្បត្តិរដ្ឋជាដើម ដែលគេមិនឲ្យ ឬមិនចង់ឲ្យដោយឧបាយផ្សេងៗ មានលួចប្លន់ រត់គយ សូកស៊ីសំណូកជាដើម។

ឯការសូក និងការស៊ីសំណូកនេះ ជាប្រធាននៃអទិន្នាទាន ព្រោះអ្នកសូក គឺសូកគេឲ្យលួចឲ្យ ឬឲ្យគេបើកឱកាសឲ្យខ្លួនលួច ឯអ្នកស៊ីសំណូក គឺលួចឲ្យគេផង


www.elibraryofcambodia.org

លួចយកខ្លួនឯងផង ឬប្រើឧបាយពុតរលួយផ្សេងៗ បន្លំក្នុងច្បាប់រដ្ឋ ឲ្យម្ចាស់ទ្រព្យភ័យខ្លាច ដើម្បីយកទ្រព្យសម្បត្តិគេ ដែលគេមិនចង់ឲ្យដោយការលួចយ៉ាងកំសាក ខ្វះសេចក្ដីក្លាហាន មិនហ៊ានចេញមុខលួច ដូចពួកចោរ។ អទិន្នាទានកំសាកនេះឯង ដែលរដ្ឋទាំងឡាយក្នុងលោក ពិបាកបង្ក្រាបជាងអទិន្នាទានចេញមុខ។

ត្រណមនេះ រដ្ឋទាំងឡាយក្នុងលោក សុទ្ធតែមានច្បាប់ហាមឃាត់ជាដាច់ខាត បើពលរដ្ឋណា ធ្វើប្រឆាំងនឹងច្បាប់នេះ ពលរដ្ឋនោះ អស់សិទ្ធិជាមនុស្សហើយ ត្រូវទទួលទណ្ឌកម្មតាមទោសានុទោស ដែលរដ្ឋបានបញ្ញត្តទុក មានប្រហារជីវិតជាដើម ព្រោះជាអ្នកប្រឆាំងនឹងច្បាប់រដ្ឋ នឹងសិទ្ធិអ្នកដទៃ ដែលគេចង់មាន ចង់បាន មិនចង់ឲ្យខូចខាត បាត់បង់ទ្រព្យសម្បត្តិដូចខ្លួនដែរ។

ត្រណមទី៣- កាមេសុ មិច្ឆាចារ ការជឹតក្បត់លួចកូនប្រពន្ធអ្នកដទៃ ដើម្បីមេថុនសេវនៈ ដែលគេមិនបានអនុញ្ញាតឲ្យ។

ត្រណមនេះរដ្ឋទាំងឡាយក្នុងលោក ក៏មានច្បាប់ហាមឃាត់ដែរ បើពលរដ្ឋណា ប្រឆាំងនឹងច្បាប់នេះ ពលរដ្ឋនោះ អស់សិទ្ធិជាមនុស្សហើយ ត្រូវទទួលទណ្ឌកម្មតាមទោសានុទោស ដែលរដ្ឋបានបញ្ញត្តទុក ព្រោះជាអ្នកប្រឆាំងនឹងច្បាប់រដ្ឋ នឹងសិទ្ធិអ្នកដទៃ ដែលគេចេះស្រឡាញ់ស្វាមី ភរិយាកូនចៅគេដូចខ្លួនដែរ។

ត្រណមទី៤- មុសាវាទ ការនិយាយពាក្យមិនពិត កុហក បោកបញ្ឆោត ដោយវាចា ដោយក្លែងលិខិត ឬដោយខិតប័ណ្ណបាចសាច បំបះបំបោរកុហកបំផ្លើសឲ្យខុសពីការពិតនាំឲ្យខូចរបៀបរៀបរយរបស់រដ្ឋមួយៗ ឬនាំឲ្យខូចផលប្រយោជន៍ទ្រព្យសម្បត្តិអ្នកដទៃ។

ត្រណមនេះ រដ្ឋទាំងឡាយក្នុងលោក បានហាមឃាត់ដាច់ខាត បើពលរដ្ឋណា ធ្វើប្រឆាំង ពលរដ្ឋនោះអស់សិទ្ធិជាមនុស្សហើយ ត្រូវទទួលទណ្ឌកម្មផ្សេងៗ មាននិរទេសចាកដែន ឬប្រហារជីវិតជាដើម ព្រោះជាអ្នករំលោភលើច្បាប់រដ្ឋលើសិទ្ធិអ្នកដទៃ។

ត្រណមទី៥- សុរាមេរយៈ ការផឹកនូវទឹកស្រវឹងដែលនាំឲ្យឆ្កួតវង្វេង ស្រែកឡូឡា ធ្វើឲ្យមានការភ្ញាក់ផ្អើល រំខានដល់អ្នកដទៃ ឬស្រវឹងដួលដេកនៅទីណាមួយ ដែលនាំឲ្យខូចរបៀបជាសាធារណៈ ឬក៏ជក់នូវគ្រឿងពុល ញៀន មានអាភៀនជាដើម។

ត្រណមនេះ រដ្ឋទាំងឡាយក្នុងលោក ក៏មានច្បាប់ហាមឃាត់ដែរ បើពលរដ្ឋណា ប្រព្រឹត្តប្រឆាំងនឹងច្បាប់នេះ ពលរដ្ឋនោះ អស់សិទ្ធិជាមនុស្សហើយ ព្រោះគ្មានមនុស្សធម៌ ត្រូវទទួលទណ្ឌកម្មតាមទោសានុទោស ដែលរដ្ឋបានបញ្ញត្តទុក។


www.elibraryofcambodia.org

សុរាមេរ័យនេះ ខាងច្បាប់ពុទ្ធសាសនា ហាមមិនឲ្យផឹកដាច់ខាត ទោះផឹកមិនឲ្យស្រវឹងខ្លាំង ផឹកជាកិត្តិយស ឬផឹកឲ្យឆ្ងាញ់បាយក៏ដោយក៏មិនបាន ព្រោះជាហេតុនៃសេចក្ដីប្រមាទដែលជាប្រភពនៃអំពើអាក្រក់គ្រប់យ៉ាង គឺផឹកលេងបន្តិចៗក៏នាំឲ្យខូចសម្បជញ្ញៈ សាហាវភ្លើតភ្លើនក្នុងរាគៈ លោភៈ ទោសៈ មោហៈដែរ អាចនាំឲ្យប្រព្រឹត្តរំលោភនូវគ្រលាមទាំង ៤ ខាងដើម។

ចំណែកខាងលោកនិយម គេយល់ថា ការផឹកបន្តិចបន្តួចជាការសប្បាយ ជាកិត្តិយស ជាថ្នាំកែរោគ នាំឲ្យបែកញើសស្រួលខ្លួន បរិភោគបាយឆ្ងាញ់ផង នាំឲ្យចម្រើនដល់សេដ្ឋកិច្ចផង ព្រោះការធ្វើសុរាមេរ័យ ជាឧស្សាហកម្មធំមួយក្នុងលោក បើមិនឲ្យមនុស្សផឹក ឧស្សាហកម្មនេះនឹងរលំមិនខាន។

រឿងសុរាមេរ័យនេះ មិនខុសគ្នាពីរឿង បាណាតិបាតទេ ច្បាប់រដ្ឋមានហាមខ្លះ មិនហាមខ្លះ អនុលោមទៅតាមចំណង់ពលរដ្ឋភាគច្រើន ដែលត្រូវការយកសាច់សត្វជាចំណីអាហារ និងត្រូវការផឹកសុរាក្លែមសាច់សត្វ ប៉ុន្តែបើផឹកក្លែមជ្រុលហួស នាំឲ្យខូចរបៀបរៀបរយជាសាធារណៈ ឬនាំឲ្យកើតរឿងហេតុផ្សេងៗនោះ រដ្ឋផ្ដន្ទាទោសឥតត្រាប្រណីឡើយ។

មនុស្សធម៌ទាំង ៥ នេះ ខាងទ្រឹស្ដីពុទ្ធសាសនាហៅថា និច្ចសីល ឬសីល ៥ មានបទបញ្ញត្តិ មានអង្គនៃសិក្ខាបទមួយៗតឹងតែងជាងមនុស្សធម៌ខាងលោកនិយមបន្តិច។

ក្នុងទ្រឹស្ដីពុទ្ធសាសនាថា មនុស្សធម៌នេះ មិនគ្រាន់តែញ៉ាំងមនុស្សឲ្យបានសុខសន្តិភាពក្នុងជាតិនេះ ប៉ុណ្ណោះទេ អាចដឹកនាំបដិសន្ធិវិញ្ញាណ របស់អ្នកមានមនុស្សធម៌នេះឲ្យកើតជាមនុស្សក្នុងជាតិបន្ទាប់ៗទៀតបាន ព្រោះជាពូជរបស់មនុស្ស។ បើពួកមនុស្សគ្មានមនុស្សធម៌ក្នុងជាតិនេះទេ ជាមនុស្សដាច់ពូជ ឬមនុស្សឥតពូជ ដល់ពេលស្លាប់ទៀងតែទៅកើតជាសត្វតិរច្ឆានដាច់ខាត។

អាស្រ័យហេតុនេះ ទើបក្នុងពិភពលោកយើង មានបរិមាណនៃចំនួនសត្វតិរច្ឆានច្រើនជាងបរិមាណនៃចំនួនមនុស្ស មកអំពីពួកមនុស្សក្នុងពិភពលោក ច្រើនតែជាអ្នកដាច់ពូជ មិនសូវមានមនុស្សធម៌។ នេះបើគិតតាមទស្សនៈ នៃបរមត្ថវិជ្ជា (Métaphysique) ផ្នែកបដិសន្ធិវិញ្ញាណមនុស្ស។

អ្នកមានអាចារៈ ប្រកបដោយសីលធម៌ និងមនុស្សធម៌ ដូចបានអធិប្បាយមកនេះ ឈ្មោះថា អារ្យជន អ្នកមានអារ្យធម៌។ ជនបែបនេះ មានច្រើននៅប្រទេសណា ប្រទេសនោះទោះធំក្ដី តូចក្ដី ឈ្មោះថាអារ្យប្រទេសទី ១ ប្រសើរបំផុតក្នុងលោក។


www.elibraryofcambodia.org

ដើម្បីបណ្តុះបណ្តាលអារ្យធម៌ទី ១ នេះ ឲ្យមានក្នុងលោក ក្នុងរដ្ឋមួយៗបាន ត្រូវយកអាចារវប្បធម៌ មកអនុវត្តតាមវិធាន ៤ យ៉ាង ៖

១- បណ្តុះបណ្តាលអាចារៈ ដែលប្រកបដោយសីលធម៌ និងមនុស្សធម៌ តាមកម្មវិធីសិក្សាជាតិ ដែលមានក្នុងរដ្ឋមួយៗ ចាប់តាំងពីថ្នាក់ក្រោមរហូតដល់ថ្នាក់លើបំផុត ដើម្បីឲ្យពួកកុមារ និងយុវជន មានអាចារសម្បជញ្ញៈ ស្រឡាញ់ពេញចិត្ត ប្រព្រឹត្តធ្វើតែអំពើល្អស្អាតស្អំ មានចិត្តគំនិតខ្ពង់ខ្ពស់ ចេះស្អប់ខ្ពើមអំពើថោកទាប ពុករលួយ មានកាប់ចាក់ លួច ប្លន់ ឆក់ ស្វក ស៊ីសំណូកជាដើម។

២- បណ្តុះបណ្តាលតាមអក្សរសាស្ត្រ គឺនិយមអានសៀវភៅផ្ទាល់ ឬស្តាប់គេអានផ្សាយតាមវិទ្យុជាតិ និងសរសេរផ្សាយនូវសៀវភៅច្បាប់ផ្សេងៗ ដែលប្រកបដោយសីលធម៌ និងមនុស្សធម៌ ជាពាក្យកាព្យ ឬពាក្យរាយ ដូចទ្រឹស្តី និពន្ធ កវីនិពន្ធ រឿងល្បើក រឿងព្រេង រឿងល្ខោន ប្រលោមលោក និងនវកថាជាដើម ព្រោះអក្សរសាស្ត្រនេះ ជាគ្រូប្រសើរបំផុតក្នុងលោក អាចបង្រៀនអប់រំ ដឹកនាំមនុស្សលោកឲ្យបានចេះដឹង អំពីសីលធម៌ និងមនុស្សធម៌សព្វគ្រប់និងគ្រប់ពេលវេលា គ្មានពេលឈប់សម្រាក។ ប៉ុន្តែត្រូវរៀននូវសៀវភៅក្បួនច្បាប់ ដែលកើតឡើងដោយស្នាដៃពួកអនារ្យជនចេញ។

៣- បណ្តុះបណ្តាលតាមសិល្បៈ មានសិល្បៈខាង សូរសំឡេង គឺចម្រៀង ភ្លេង សិល្បៈខាងកាយវិការ និងសិល្បៈខាងរូបភាព គឺរូបថត ឬគំនូរ-ភាពយន្ត។ សិល្បៈទាំងអស់នេះ ជាថ្នាលសម្រាប់បណ្តុះសីលធម៌ និងមនុស្សធម៌សំខាន់មួយ ព្រោះមនុស្សនិយមរាប់អានមើលស្តាប់។ ប៉ុន្តែកុំមើលស្តាប់នូវសិល្បៈពុករលួយ ប្រាសចាក សីលធម៌ និងមនុស្សធម៌ ដែលនិពន្ធតាក់តែងឡើង ដោយពួកអានារ្យជន។

៤- បណ្តុះបណ្តាលតាមលទ្ធិសាសនា មានពុទ្ធសាសនាជាដើម។ វប្បធម៌ដែលទាក់ទងនឹងវិធាននេះ មានឥទ្ធិពលជាងវិធានទាំង ៣ ខាងដើម ព្រោះសង្គមមនុស្ស បានផ្ញើគំនិតជំនឿលើលទ្ធិសាសនានេះឯង តែងគោរពធ្វើតាមដោយស្មោះស្ម័គ្រ។ ប៉ុន្តែត្រូវរៀននូវលទ្ធិសាសនាពុករលួយ ប្រាសចាកសីលធម៌ និងមនុស្សធម៌ ដែលកើតមាន ឡើងដោយពួកអានារ្យជននេះម្យ៉ាង។

ម្យ៉ាងទៀត បើបានជួបប្រទះនូវលទ្ធិសាសនា ដែលបរិបូណ៌ដោយសីលធម៌ និងមនុស្សធម៌ហើយ បែរជាទុកដាក់លទ្ធិសាសនានោះដោយឡែក ក្រៅចិត្តគំនិតទៅវិញ គឺទុកសម្រាប់តែបន់ស្រន់ កាត់គ្រោះ លើករាសី បង្សុកូល ក្នុងពេលឈឺស្លាប់ មិនបានត្រងត្រាប់ស្តាប់ប្រតិបត្តិ សិក្សា អនុវត្តតាមនោះ ក៏មិនឈ្មោះថាបានបណ្តុះបណ្តាល


www.elibraryofcambodia.org

អាចារវប្បធម៌នេះដែរ ព្រោះបានទុកលទ្ធិសាសនាជាទឹកត្រី ទឹកស៊ីអ៊ីវ សម្រាប់តែពេលសាប ទៅហើយ។

កាលបើបានបណ្ដុះបណ្ដាល អាចារវប្បធម៌ តាមវិធានទាំង ៤ នេះ វិធានណាមួយឲ្យបានដុះដាល លូតលាស់កើតមានឡើងហើយ អាចារវឌ្ឍនធម៌ ក៏កើតមានឡើង អារ្យធម៌ប្រភេទ ទី១ គឺអាចារៈក៏កើតមានក្នុងពេលនោះដែរ។

**អារ្យធម៌ប្រភេទទី ២ - ទស្សនីយភាព:** ភាពដែលគួរឲ្យចង់មើលចង់ឃើញ ចែកជា ២ គឺ៖

ក- ទិដ្ឋភាពនៃឥរិយាបថ និងរូបឆោមមនុស្ស គឺ ឥរិយាបថស្រគត់ស្រគំ មិនច្រលើសបើស រងឹសរងាសច្រងេងច្រងាង រមុំាងរមោកខ្ជោកខ្ជាក បានដល់ឥរិយាបថ ដេក ដើរ ឈរ អង្គុយ របស់អ្នកមានសុជីវធម៌ ដែលចេះប្រើឥរិយាបថ ក្នុងទីប្រជុំ ឬក្រៅទីប្រជុំ សមរម្យល្អ មិនទាស់ឆ្គង គួរឲ្យចង់មើលចង់ឃើញ និងអ្នកដែលមាន រូបឆោមសមរម្យ ប្រកបដោយសម្រស់ពីធម្មជាតិ ឬអ្នកដែលមានរូបឆោមផ្ទុយពីនេះ ប៉ុន្តែចេះរៀបចំសម្អាតខ្លួន តាមក្បួនអនាម័យ មានដុសក្អែល កាត់ក្រចក កាត់សក់ បោកសម្លៀកបំពាក់ ស្អាតបាតមិនកខ្វក់ គួរឲ្យចង់មើលចង់ឃើញ។ អ្នកដែលមាន ឥរិយាបថសមរម្យមិនឆ្គង និងអ្នកមានសោភណភាព រូបកាយបែបនេះ ឈ្មោះថាអារ្យជន អ្នកមានអារ្យធម៌ដែរ។

ខ- ទិដ្ឋភាពនៃទីឋាន ដែលមានរបៀបរៀបចំត្រឹមត្រូវបានដល់ទិដ្ឋភាពនៃទីក្រុង-ខេត្ត-ស្រុក-ភូមិ និងផ្ទះលំនៅផ្ទាល់របស់ពលរដ្ឋម្នាក់ៗ ក្នុងប្រទេសជាតិមួយៗ ដែលចេះរៀបចំ ចេះស្ថាបនា វិមាន ប្រាសាទ គ្រឹះស្ថាន ផ្លូវ ស្ពាន សួនផ្កាជាដើម មានរបៀប មានជួរសង្កាត់ខ្វាត់ខ្វែង សក្តិសម ទូលំទូលាយប្រកបដោយអនាម័យ មិនចង្អៀតចង្អល់ មិនកខ្វក់ស្មោគគ្រោក គួរឲ្យចង់មើលចង់ឃើញ។ អ្នកចេះរៀបចំបានល្អប្រសើរយ៉ាងនេះ ឈ្មោះថា អារ្យជន អ្នកមានអារ្យធម៌ ជនបែបនេះមានច្រើននៅប្រទេសណា ប្រទេសនោះទោះធំក្តីតូចក្តី ឈ្មោះថា អារ្យប្រទេសដូចគ្នា ព្រោះជាប្រទេសដែលសម្បូណ៌ ដោយពលរដ្ឋ មានចិត្តគំនិត កាយវិការប្រកបដោយសុជីវធម៌។


www.elibraryofcambodia.org

ពាក្យថា សុជីវធម៌នេះ គឺជាឈ្មោះរួមសាខាធម៌ដែលបែកចេញមកពី សីលធម៌ខ្លះ មនុស្សធម៌ខ្លះ ចរិយាធម៌ខ្លះ វប្បធម៌ខ្លះ ពីទម្លាប់ទំនៀមប្រពៃណីខ្លះ ពីរបៀបសម័យទំនើបខ្លះ ។ល។ សាខាធម៌ទាំងអស់នេះឯង សម្រាប់រៀបចំសម្រួលដំណើរជីវិតមនុស្សម្នាក់ៗ ឲ្យបានរស់នៅសមរម្យ តាមរបៀបរបបមនុស្ស។

ដើម្បីបណ្ដុះបណ្ដាលអារ្យធម៌ប្រភេទទី២នេះ ឲ្យកើតមានក្នុងលោក ក្នុងរដ្ឋមួយៗបាន ត្រូវយកទស្សនីយភាពវប្បធម៌មកអនុវត្តតាមវិធាន ៥ យ៉ាង ៖

១- បណ្ដុះបណ្ដាលទស្សនីយភាពនៃឥរិយាបថ រូបឆោមនិងទីឋាន តាមកម្មវិធីសិក្សាជាតិ ចាប់ពីថ្នាក់ទាប រហូតដល់ថ្នាក់ខ្ពស់បំផុត ដើម្បីឲ្យកុមារនិងយុវជន មានចិត្តគំនិតកាយវិការ ប្រកបដោយសុជីវធម៌ ចេះរៀបចំដំណើរជីវិត ឲ្យមានសណ្ដាប់ធ្នាប់ មានរបៀបរៀបរយល្អ តាំងពីក្មេងៗទៅ។

២- បណ្ដុះបណ្ដាលតាមអក្សរសាស្ត្រ ដែលជាឃ្លាំងនៃសុជីវធម៌ គឺនិយមអានសៀវភៅផ្ទាល់ ឬស្ដាប់គេអានផ្សាយតាមវិទ្យុជាតិ និងសរសេរផ្សាយនូវសៀវភៅក្បួនច្បាប់ដែលប្រកបដោយសុជីវធម៌។ វៀរតែសៀវភៅក្បួនច្បាប់ដែលកើតឡើង ដោយពួកអនារ្យជនចេញ។

មូលនិធិឧត្តមភាពអប់រំកម្ពុជា FOUNDATION

៣- បណ្ដុះបណ្ដាល-តាមសិល្បៈទាំង៧ គឺសិល្បៈចម្រៀង ភ្លេង (Chant-musique) សិល្បៈល្ខោន-របាំ (Théâtre-dance) សិល្បៈកាព្យឃ្លោង *(poésie)* សិល្បៈគំនូរផាត់ពណ៌ (Peintre) សិល្បៈស្ថាបត្យកម្ម (Architecture) សិល្បៈប៉ាន់រូបឆ្លាក់រូប (Modelage-sculture) និងសិល្បៈថតរូបភាពយន្ត (Photographie-cinématographie)។ សិល្បៈទាំង៧នេះ ជាឃ្លាំងនៃសុជីវធម៌មួយដែរ ដែលមហាជននិយមមើល ស្ដាប់ និងឆាប់ប្រតិបត្តិតាមបានដោយងាយ។ វៀរតែសិល្បៈពុករលួយ របស់អនារ្យជនចេញ។

៤- បណ្ដុះបណ្ដាល-តាមលទ្ធិសាសនា ដែលជាប្រភពនៃសុជីវធម៌ និងជាវត្ថុសក្តិសិទ្ធិខាងការបង្កើតសាមគ្គីធម៌ដឹកនាំពលរដ្ឋ សាង សង់សំណង់ សមិទ្ធិផ្សេងៗ មានផ្លូវស្ពានជាដើម ព្រោះលទ្ធិសាសនានេះហើយ ដែលពលរដ្ឋនិយមរាប់អាន ទុកចិត្តជឿធ្វើតាម


www.elibraryofcambodia.org

ដោយស្មោះស្ម័គ្រមិនបាច់បង្ខំ។ វៀរតែលទ្ធិសាសនាពុករលួយ ដែលកើតឡើងដោយពួកអនារ្យជនចេញ។

៥- បណ្តុះបណ្តាល-តាមក្បួនបច្ចេកទេស ដែលជាឃ្លាំងនៃក្បួនខ្នាត ប្រកបដោយទេព្យកោសល្យ ការប៉ិនប្រសប់ក្នុងការស្ថាបនា ឲ្យបានសមល្អប្រពៃ បានជាប់មាំមួនស្របតាមស្ថាបនកម្មជាតិ និងអន្តរជាតិ។ បើខ្វះក្បួនបច្ចេកទេសនេះ ទិដ្ឋភាពនៃទីឋានក៏ដុះដាលឡើង មិនមាំទាំត្រឹមត្រូវល្អដែរ។

កាលបើបានបណ្តុះបណ្តាល ទស្សនីយភាវវប្បធម៌តាមវិធានទាំង ៥ នេះ ឲ្យរីកដុះដាលកើតមានឡើងហើយទស្សនីយភាវវឌ្ឍនធម៌ ក៏កើតមានឡើង អារ្យធម៌ប្រភេទទី២ គឺទស្សនីយភាវៈ ក៏កើតក្នុងពេលនោះដែរ។

**អារ្យធម៌ប្រភេទទី ៣ - លិង្គៈ** ភេទសមរម្យបានដល់ការរចនាសម្លៀកបំពាក់ ការប្រើគ្រឿងអលង្ការ ការរចនា សក់ ក្រចក ពុកមាត់ ពុកចង្កា ជាដើម ឲ្យបានត្រឹមត្រូវសមតាមភេទប្រុសស្រី និងចេះនូវវិធីប្រើសម្លៀកបំពាក់ជាដើមនោះឲ្យត្រូវតាមរបៀបតាមពេលវេលា ស្របតាមប្រពៃណីជាតិ និងអន្តរជាតិ។

លិង្គៈនេះ ធម្មជាតិបានដឹកនាំ ចិត្តគំនិតមនុស្ស ឲ្យចេះរចនាសម្លៀកបំពាក់ជាដើមប្រចាំជាតិមួយៗ តម្រូវតាមភេទ មានទម្រង់និងលម្អផ្សេងៗគ្នា។ អ្នកមានអារ្យធម៌ប្រភេទនេះ ចេះតែនាំគ្នារចនាកែទម្រង់ ឲ្យរឹតតែប្រកបដោយសោភភាពឡើង តាមលក្ខណៈជាតិខ្លួនស្របតាមកាលៈទេសៈជានិច្ច មិនបណ្តោយឲ្យបាត់បង់ទម្រង់ជាតិ ដោយយកតម្រាប់តាមបរទេសទាំងស្រុងនោះឡើយ។

ឯសម្លៀកបំពាក់ផ្នែកអន្តរជាតិ គេរក្សានូវឯកភាពខាងទម្រង់ និងរបៀបប្រើឲ្យបានត្រឹមត្រូវ កុំឲ្យឈ្លើយតែម្នាក់ឯង ចូលជំនុំ ចំណោមនឹងគេមិនចុះ។

ការចេះរចនាសម្លៀកបំពាក់ជាដើម ឲ្យបានសមរម្យតាមភេទប្រុសស្រី តាមប្រពៃណីជាតិ និងអន្តរជាតិ ហើយចេះប្រើឲ្យបានស្របតាមពេលវេលា តាមពិធីផ្សេងៗនោះ


www.elibraryofcambodia.org

អាស្រ័យដោយពលរដ្ឋ មានចិត្តគំនិត និងកាយវិការ ប្រកបដោយសុជីវធម៌ បើខ្វះសុជីវធម៌ហើយ មិនអាចរចនាភេទប្រុសស្រីបានសមរម្យឡើយ។

អ្នកមានសុជីវធម៌ ចេះរចនាភេទប្រុសស្រី ឲ្យមានសោភ័ណភាព សមរម្យតាមប្រពៃណីជាតិ និងអន្តរជាតិនេះឯងឈ្មោះថា អារ្យជន អ្នកមានអារ្យធម៌ដែរ។

ដើម្បីបណ្តុះបណ្តាល អារ្យធម៌ប្រភេទទី៣នេះ ឲ្យកើតឡើងបាន ត្រូវយកលិង្គវប្បធម៌ មកអនុវត្តតាមវិធាន ៥ យ៉ាងគឺតាមកម្មវិធីសិក្សាជាតិ ១ តាមអក្សរសាស្ត្រ ១ តាមសិល្បៈ ១ តាមលទ្ធិសាសនា ១ និងតាមក្បួនបច្ចេកទេស ១។ ផ្នែកក្បួនបច្ចេកទេស សំដៅយកហត្ថកោសល្យ ការប៉ិនប្រសប់ខាងគូរវាស វាស់ កាត់ ដេរ ប៉ាក់ ចាក់ ផុល ជាដើម។

វិធានទាំង ៥ នេះ មានន័យប្រហែលគ្នានឹងវិធានខាងអារ្យធម៌ប្រភេទទី២ ដែរ។

កាលបើបានបណ្តុះបណ្តាលលិង្គវប្បធម៌ តាមវិធានទាំង៥ នេះ ឲ្យរីកដុះដាលកើតមានឡើងហើយ លិង្គវឌ្ឍនធម៌ក៏កើតមានឡើង អារ្យធម៌ប្រភេទទី ៣ គឺលិង្គៈ ក៏កើតមានក្នុងពេលនោះដែរ។

**អារ្យធម៌ប្រភេទទី៤ - សមត្ថភាពៈ** ភាពអង់អាច ដោយចំណេះវិជ្ជា ការចេះដឹងវៃឆ្លាត បានដល់សមត្ថភាពខាងវិជ្ជាអក្សរសាស្ត្រ និងសមត្ថភាពខាងវិជ្ជាបច្ចេកទេស អាចរៀបចំលក្ខណៈវប្បធម៌ និងលក្ខណៈសង្គមធម៌បាន។

ខាងវិជ្ជាអក្សរសាស្ត្របរទេសខ្លះ ដែលមានផលប្រយោជន៍ចំពោះជាតិ ទស្សនវិជ្ជា សង្គមវិជ្ជា ចរិយាសាស្ត្រ ភូមិសាស្ត្រ និង ប្រវត្តិសាស្ត្រ ។ល។

ខាងវិជ្ជាបច្ចេកទេសមាន = គណិតសាស្ត្រ វជ្ជាគីមី វិទ្យាសាស្ត្រធម្មជាតិ វិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រពិសោធន៍ និងរូបសាស្ត្រ ។ល។

ចំណេះវិជ្ជាទាំងពីរផ្នែកនេះ អាចសាងពលរដ្ឋក្នុងរដ្ឋមួយៗដែលបានសិក្សារៀនចេះដឹង បរិបូណ៌ដោយសមត្ថភាព ហើយឲ្យមានឋានៈជាកសិករ និងឧស្សាហាករទំនើប ជា


www.elibraryofcambodia.org

ពាណិជ្ជករជំនាញ ជាសិល្បករចំណាប់ ជាកម្មករឯកទេស ជាបសុពេទ្យ ជាគ្រូពេទ្យ ជានាយទាហាន ជាអ្នកនិពន្ធ កវីនិពន្ធ ជាអ្នកបច្ចេកទេស ជាវិស្វករ ជាអ្នកនយោបាយ ជាមន្ត្រី និងជារដ្ឋមន្ត្រីខាងស៊ីវិល ទាហាន ។ល។

អ្នកដែលបរិបូណ៌ដោយសមត្ថភាព គឺការចេះដឹងវៃឆ្លាតបែបនេះ ឈ្មោះថា អារ្យជន អ្នកមានអារ្យធម៌ដែរ។ ជនបែបនេះមានច្រើននៅប្រទេសណា ប្រទេសនោះឯង ជាអារ្យប្រទេស។

ដើម្បីបណ្ដុះបណ្ដាលអារ្យធម៌ប្រភេទទី ៥ នេះ ឲ្យកើតមានក្នុងលោក ក្នុងរដ្ឋមួយៗបាន ត្រូវយកបញ្ញាវប្បធម៌មកអនុវត្តតាមវិធាន ៤យ៉ាង ៖

១- បណ្ដុះបណ្ដាលបញ្ញាវប្បធម៌ តាមអង្គការសិក្សាធិការជាតិរបស់រដ្ឋមួយៗ ដែលរដ្ឋបានប្រមូលមុខវិជ្ជា មករៀបចំតាក់តែងឡើង ជាវត្ថុសិក្សា ប្រកបដោយគរុកោសល្យ តម្រូវតាមភូមិសិក្សា ស្របតាមលក្ខណៈជាតិ និងអន្តរជាតិ ហើយវាតពង្រីក គ្រឹះស្ថានបឋមសិក្សា អនុវិទ្យាល័យ ទៅក្នុង សង្កាត់ ស្រុក ខេត្ត ក្រុង តាមចំនួនពលរដ្ឋ ដែលត្រូវការសិក្សា។

២- បណ្ដុះបណ្ដាល-តាមអក្សរ គឺការសរសេរផ្សាយនូវសៀវភៅក្បួនច្បាប់ ដែលត្រូវសិក្សា មើល អាន ឲ្យបានគ្រប់គ្រាន់ តាមសេចក្ដីត្រូវការរបស់សិក្ខាកាមៗ ម្នាក់ៗត្រូវនិយម អានសៀវភៅក្បួនច្បាប់ ឲ្យបានច្រើនមុខ ព្រោះការមើល អានច្រើន បានឃើញច្រើន ដឹងច្រើន នាំឲ្យរីកដុះដាលខាងបញ្ញាបានច្រើនយ៉ាងឆាប់រហ័ស។

៣- បណ្ដុះបណ្ដាល-តាមសិល្បៈ ដែលជាទីនិយមរាប់អានរបស់មនុស្សលោក ជាសាលារៀនខាងបញ្ញាវប្បធម៌យ៉ាងសំខាន់។

៤- បណ្ដុះបណ្ដាល-តាមលទ្ធិសាសនា ដែលជាថ្នាលយ៉ាងធំនៃបញ្ញាវប្បធម៌ មានឥទ្ធិពលផ្សាយទៅបណ្ដុះបណ្ដាលគ្រប់ទិសទី គ្រប់វ័យមនុស្ស។

មូលនិធិខ្មែរសម្រាប់ការសិក្សា FOUNDATION


www.elibraryofcambodia.org

កាលបើបានបណ្តុះបណ្តាល បញ្ញាវប្បធម៌តាមវិធានទាំង៤នេះ ឲ្យរីកដុះដាលកើតមានឡើងហើយ បញ្ញាវប្បធម៌ក៏ចម្រើនឡើង អារ្យធម៌ប្រភេទទី ៤ គឺសមត្ថភាពក៏កើតមានក្នុងពេលនោះដែរ។

# នាទីអារ្យធម៌

ដើម្បីស្គាល់នូវគុណភាពខ្ពស់ទាប នៃអារ្យធម៌ទាំង៤នេះ គេអាចស្គាល់បានតាមនាទីនេះឯង។

អារ្យធម៌ទី ១ ដែលមាននាទីផ្តល់សុខសន្តិភាព ឲ្យពួកមនុស្សនោះ ជាអារ្យធម៌ប្រសើរឯក មានគុណភាពខ្ពង់ខ្ពស់ ព្រោះជាមគ្គុទ្ទេស ដឹកនាំអង្គការពិភពលោក អង្គការរដ្ឋ និងអង្គការគ្រួសារមួយៗឲ្យប្រព្រឹត្តទៅក្នុងផ្លូវសុខសន្តិភាពដែលនាំឲ្យកើតសេចក្តីចម្រើនរុងរឿង។ បើគ្មានសុខសន្តិភាពនេះជាបឋមទេ សេចក្តីចម្រើនរុងរឿងក៏គ្មានដែរ។

ឯអារ្យធម៌ទី២ ទី៣ និងទី៤ នោះ គឺគ្រាន់តែចេះរៀបចំអង្គការពិភពលោក អង្គការរដ្ឋ និងអង្គការគ្រួសារនេះឯង បើគ្រាន់តែចេះរៀបចំ ឲ្យមានតែអង្គការ ហើយគ្មានអារ្យធម៌ទី ១ គឺអាចារៈ ប្រព្រឹត្តអនុវត្តតាមអង្គការនោះៗឲ្យបានត្រឹមត្រូវទេ គឺថាមានតែច្បាប់ មានតែរបៀបគ្រាន់តែបង្ហួតគ្នាលេង គ្មានការប្រតិបត្តិតាមច្បាប់ គិតតែនាំគ្នាធ្វើផ្តេសផ្តាស ជិះជាន់គ្នា សូក ស៊ីសំណូក រត់គយ យកច្បាប់ យកអង្គការទៅធ្វើជាឧបករណ៍រកប្រយោជណ៍ហោប៉ៅរៀងៗខ្លួននោះ សាមគ្គីធម៌ និងសុខសន្តិភាព មិនមានឡើយ បើកំពុងតែមាន ក៏ត្រូវវិនាសអន្តរាយទៅវិញយ៉ាងឆាប់រហ័សមិនខាន។ ទោះបីខំស្រែកអំពាវនាវហៅរកយ៉ាងណា ក៏សាមគ្គីធម៌ និងសុខសន្តិភាពនោះ មិនមកជិតឡើយ។ ព្រោះថាអារ្យធម៌ទី២ ទី៣ និងទី៤ នេះ គ្រាន់តែជាសភាវពិត តាមចលនាគតិនៃការរស់នៅប្រកបដោយព្យាយាម ឬខ្និលច្រអូស និងតាមចលនាគតិនៃទម្លាប់ទំនៀម គ្រឿងឧបភោគបរិភោគ និងលក្ខណៈច្បាប់ លក្ខណៈអង្គការ របស់ប្រជាជាតិក្នុងរដ្ឋមួយៗប៉ុណ្ណោះ ជាធម្មជាតិកណ្តាល ចាត់ថាមានតម្លៃក៏មិនទាន់បានថាគ្មានតម្លៃក៏មិនទាន់បាន។ បើអ្នកមានអារ្យធម៌បែបនេះហើយមានចិត្តគំនិត កាយវិការ ចរិយាល្អ គឺមានអារ្យធម៌ទី១ ដែលហៅថា


www.elibraryofcambodia.org

អាចារៈនោះថែមទៀត ទើបអារ្យធម៌ទី ២ ទី ៣ និងទី ៤ នេះមានតម្លៃ បានជាគុណប្រយោជន៍យ៉ាងធំ ចំពោះមនុស្សលោក បើគ្មានទេ គិតតែនាំគ្នាធ្វើផ្តេសផ្តាស តាមអំពើចិត្តដែលឡើងជំនោរ តាមឥទ្ធិពលនៃអារ្យធម៌ ទី ២ ទី ៣ និងទី ៤ នោះ នឹងប្រែក្លាយជា អនារ្យធម៌ យ៉ាងសាហាវ ជាងអនារ្យធម៌របស់ជនល្ងង់ខ្លៅ ជាសត្រូវធំ របស់មនុស្សលោកថែមទៀត ដូចជាឱសថកែរោគ បើអ្នកមិនចេះប្រើ នឹងក្លាយជាថ្នាំពិស យ៉ាងសាហាវដូច្នោះដែរ។

## ឧទាហរណ៍

ក្នុងរដ្ឋមួយៗ មានអង្គការជាច្រើន អង្គការទាំងអស់នោះ ស្របគ្នាខ្លះ ផ្សេងគ្នាខ្លះ តាមនយោបាយរដ្ឋ ដូចជា អង្គការសិក្សាធិការ និងសុខាភិបាល ជាដើម។ អង្គការទាំងអស់នេះ រដ្ឋមួយៗបានសម្រិតសម្រាំង បង្កើតឡើង ប្រកបដោយហេតុផល ត្រឹមត្រូវតាមគតិបណ្ឌិតឥតខ្ចោះ អាចផ្តល់សុខសន្តិភាព ចម្រើនរុងរឿង ឲ្យមនុស្សក្នុងរដ្ឋ បានពិតប្រាកដ។ ប៉ុន្តែអង្គការទាំងអស់នេះ គ្មានចិត្តវិញ្ញាណ គ្មានសមត្ថភាពឡើយ មានតែពួកមនុស្សដែលប្រកបដោយអាចារៈ ជាអារ្យជនប្រភេទទី ១ នេះឯង អាចញ៉ាំងអង្គការទាំងអស់នោះ ឲ្យផ្តល់ទិន្នផលដល់ពួកមនុស្សថបាន។ ព្រោះមនុស្សដែល ប្រកបដោយអាចារៈនេះ ជាអ្នកបរិបូណ៌ដោយសីលធម៌ និងមនុស្សធម៌ ចេះស្រឡាញ់គោរព អង្គការ មានកាយវិចាចិត្តទន់ភ្លន់ អនុវត្តតាមអង្គការបាន។

ចំណែកខាង មនុស្សដែលគ្មានអាចារៈ ជាអនារ្យជន (Barbare) គឺមនុស្សមាន ចិត្តគំនិត ចរិយាមារយាទកាចសាហាវ ពុករលួយ ប្រៀបប្រដូចបានទៅនឹងមនុស្សព្រៃ ឬសត្វតិរច្ឆាននោះ តែងដឹកនាំអង្គការ ឲ្យអនុវត្តតាមកាយវាចាចិត្តរបស់ខ្លួន ដែលក្រាស់ដោយ លោភៈ ទោសៈ មោហៈ នោះទៅវិញ ទោះជាអង្គការនោះ ប្រកបដោយគតិបណ្ឌិតល្អប្រសើរយ៉ាងណាក៏ដោយ។ សូម្បីតែអង្គការសុខាភិបាល ទាំងឡាយក្នុងលោក ដែលជាអង្គការប្រកបដោយសីលធម៌ និងមនុស្សធម៌ពេញបរិបូណ៌ សម្រាប់ផ្តល់សុខភាពឲ្យពួកមនុស្សមានការទាក់ទងដោយចំពោះ តែជាមួយអ្នកជម្ងឺទៅវិញ គឺពួកអនារ្យជននោះ ប្រាសចាកសីលធម៌ គ្មានមេត្តាចង់ឲ្យអ្នកជម្ងឺបានសុខ


www.elibraryofcambodia.org

គ្មានករុណាចង់ឲ្យអ្នកជម្ងឺរួចចាកទុក្ខឡើយ។ ចំណែកមនុស្សធម៌វិញ ក៏គេគ្មានកាន់ត្រណមអ្វីដែរ គិតតែពីប្រយោជន៍ផ្ទាល់ខ្លួនម្យ៉ាង មានចិត្តសាហាវអាក្រក់លើសអ្វីៗទាំងអស់ ហ៊ានធ្វើអំពើពុករលួយក្នុងពួកអ្នក ជម្ងឺដែលមនុស្សទូទៅ គេទុកជាមនុស្សទន់ខ្សោយបំផុត ប្រហែលនឹងខ្មោចទៅហើយ និងជាមនុស្សដែលគេមិនត្រូវបៀតបៀន សូម្បីជាប់កិច្ចសន្យា ធ្វើការឲ្យរដ្ឋក្ដី ឲ្យសហគ្រាសឯកជនក្ដី ឬធ្វើទាហានកំពុងជាប់ដៃច្បាំងក្ដី កាលបើមានជម្ងឺ ហើយគេឲ្យឈប់សម្រាកភ្លាម គេផ្ទាក់ថ្នមដោយពាក្យសំដី កាយវិការទន់ភ្លន់មិនកំហាក កំហែង កញ្ចក់រុញទាញ គេជួយ សង្គ្រោះគ្រប់បែបយ៉ាង មានឲ្យលុយកាក់ជាដើមនោះ ពួកអនារ្យជន បែរជាប្រើឧបាយពុករលួយផ្សេងៗ គាបចម្រាញ់ យកប្រយោជន៍ពីអ្នកជម្ងឺទៅវិញ។

ចំណែកខាងអង្គការដទៃទៀត របស់រដ្ឋទាំងឡាយក្នុងលោក ដែលមានការទាក់ទងចំពោះមនុស្សមានសុខភាពល្អ គ្មានជម្ងឺនោះ ពួកអនារ្យជននេះ រឹតតែក្លាហានធ្វើអំពើពុករលួយក្នុងអង្គការនោះៗឥតញញើតដៃ។

កាលបើពួកអនារ្យជន បែបនេះកាន់តែកើនចំនួនច្រើនឡើងៗ កើតជាពួក ជាក្រុម ជាសមាគមសម្ងាត់ ពួកសម្ងំបន្លំធ្វើអំពើពុករលួយ ក្នុងអង្គការរបស់រដ្ឋណាមួយហើយអ្នកបម្រើរដ្ឋដោយស្មោះត្រង់ មិនងាយបង្ក្រាបបានឡើយ បើមិនប្រយ័ត្នខ្លួន ពួកអនារ្យជននោះនឹងលើកទោសរបស់វាទម្លាក់ទៅឲ្យពួកអ្នកស្មោះត្រង់ទទួលវិញ ដូចជាសត្វស្វាយកបាយទៅលាបមាត់ពពែ។ អង្គការរបស់រដ្ឋនោះ ត្រូវមានវិបត្តិ ពលរដ្ឋភាគច្រើន មានជីវភាពទន់ខ្សោយ ក្រខ្សត់ រដ្ឋក៏ក្រខ្សត់ ខ្វះថវិការជាតិ ឯពួកអនារ្យជន កើតជាសេដ្ឋី អ្នកមានហឺហាគ្រប់ៗគ្នា។

កាលបើអង្គការរដ្ឋមានវិបត្តិយ៉ាងនេះហើយ ទោះបីរដ្ឋនោះកំពុងចម្រើនដោយសេដ្ឋកិច្ច និងវិទ្យាសាស្ត្រជាដើម ជាប្រទេសធំ មានពលរដ្ឋច្រើនយ៉ាងណាក៏ដោយ មិនបានឈ្មោះអារ្យប្រទេសខ្ពង់ខ្ពស់ឡើយ ព្រោះពលរដ្ឋគ្មានអាចារៈ ដែលជាអារ្យធម៌ថ្នាក់ខ្ពស់ មានតែអារ្យធម៌ ទី២ ទី៣ និងទី៤ ជាអារ្យធម៌បន្ទាប់បន្សំប៉ុណ្ណោះ គឺក្នុងប្រទេសនោះគ្មានសុខសន្តិភាពផ្ទៃក្នុង មានការបះបោរ មានពួកចោរប្លន់ មានអ្នកលេងបាតផ្សារ


www.elibraryofcambodia.org

កាប់ចាក់លួចឆក់ មានភេរវកម្មដោយគ្រាប់បែកគ្រាប់កាំភ្លើង មានក្លូដកម្ម ដែលបណ្ដាលមកពីមានអំពើពុករលួយក្នុងផ្ទៃប្រទេស គ្មានសាមគ្គីធម៌។ ឯសេដ្ឋកិច្ចនិងវិទ្យាសាស្ត្រជាដើម ដែលកំពុងចម្រើនក្នុងប្រទេសនោះ ថ្ងៃណាមួយ នឹងដល់នូវសេចក្ដីវិនាសបាត់បង់ទៅវិញ ព្រោះគ្មានសុខសន្តិភាពជាមូលដ្ឋាន។

ឧទាហរណ៍នេះបញ្ជាក់ឲ្យឃើញថា បណ្ដាអារ្យធម៌ទាំង៤ប្រភេទនោះ មានតែអារ្យធម៌ប្រភេទទី១ប៉ុណ្ណោះ ដែលមានគុណភាពខ្ពង់ខ្ពស់ ឯអារ្យធម៌បីទៀត គ្រាន់តែជាការបន្ទាប់បន្សំ សម្រាប់ផ្សំជាមួយអារ្យធម៌ទី ១ នោះឯង។

អាស្រ័យហេតុនេះ ទើបពី ៤៧០ ឆ្នាំមុន គ.ស មានទស្សនវិទូក្រិក ម្នាក់ឈ្មោះ Socrate (សូក្រាត) គាត់មិនសូវចាប់អារម្មណ៍ ចំពោះបញ្ហាមូលធាតុពិភពលោកដែលនាំឲ្យចម្រើនលូតលាស់ខាងសេដ្ឋកិច្ច និងវិទ្យាសាស្ត្រជាដើមនោះ ប៉ុន្មានទេ គាត់ចាប់អារម្មណ៍ខាងចរិយាវិទ្យាដែលដឹកនាំមនុស្សឲ្យមានសីលធម៌ និងមនុស្សធម៌វិញ គាត់និយាយថា «ទស្សនវិជ្ជាខាងមូលធាតុពិភពលោក ជាវិជ្ជាគ្មានតម្លៃ ឯចរិយាវិទ្យាខាងវិជ្ជាមនុស្សទើបមានតម្លៃជាង»។

ទស្សនៈនេះ មានអ្នកប្រាជ្ញជាច្រើនបានបដិសេធថា ជាទស្សនៈដើរថយក្រោយមិនជឿនលឿនទៅមុខ។ លុះសម័យក្រោយមក ទើបទស្សនៈរបស់លោក សូក្រាតមានប្រៀបទៅវិញ ព្រោះសំឡេងរបស់មនុស្សលោក នាំគ្នាស្រែកកងរំពងពេញផ្ទៃលោកទាមទាររកតែសុខសន្តិភាព ដែលកើតពីចរិយាវិទ្យានោះឯង។ ឃើញច្បាស់ថាចរិយាវិទ្យាជាវិជ្ជាមានប្រយោជន៍ចំពោះពួកមនុស្ស ជាងវិជ្ជាដទៃៗទៀតមែន ព្រោះបើគ្មានសុខសន្តិភាពជាមូលដ្ឋានទេ សេចក្ដីចម្រើនរុងរឿងក៏គ្មាន បើកំពុងតែមាន ក៏ត្រូវវិនាសបាត់បង់ទៅដែរ។

បើនិយាយចំពោះបុគ្គលម្នាក់ៗវិញ រឹតតែឃើញភាពជាក់ច្បាស់ជាងនេះទៅទៀត គឺបុគ្គលណាដែលហឺហាដោយសម្លៀកបំពាក់ មានលុយ ឡាន ផ្ទះថ្មមានចំណេះវិជ្ជាខាងអក្សរសាស្ត្រ និងបច្ចេកទេសជ្រៅជ្រះ ជាបញ្ញវន្តនោះ បើគ្មានចរិយា


www.elibraryofcambodia.org

មារយាទល្អ ប្រកបដោយសីលធម៌ និងមនុស្សធម៌ ជាអារ្យជនថ្នាក់ខ្ពស់ទេ បញ្ញវន្តនោះ ក្លាយជាសត្រូវយ៉ាងសាហាវរបស់សង្គមមនុស្សក្នុងពិភពលោកទៅវិញ ព្រោះមានការក្លាហានក្នុងផ្លូវអកុសលពុករលួយ ហ៊ានជិះជាន់រំលោភលើច្បាប់ជាតិនិងអន្តរជាតិ បៀតបៀនអ្នកទន់ខ្សោយ ដោយអាងអាវុធ អាងចំណេះវិជ្ជា សម្រាប់ជជែកតវ៉ាដោះសារការពារខ្លួន គឺចំណេះវិជ្ជារបស់បញ្ញវន្តពួកនេះ ដូចជាពិសដែលបិតនៅក្នុងក្បាលពស់វែក ញ៉ាំងអ្នកជួបប្រទះឲ្យតក់ស្លុតរន្ធត់ខ្លាច។ បញ្ញវន្តធុននេះ ឈ្មោះថា បញ្ញវន្តក្បាលពស់ ដែលពួកមនុស្សអាខ្លាច មិនចង់ឲ្យកើតមានក្នុងពិភពលោក។

ត្រង់ចំណុចនេះ ឃើញច្បាស់ថែមទៀតថា ចំណេះវិជ្ជាសេចក្ដីចម្រើនរុងរឿងទាំងអស់ ដែលមានក្នុងលោក បើប្រាសចាកសីលធម៌ និងមនុស្សធម៌ហើយ មិនគ្រាន់តែគ្មានប្រយោជន៍ដល់ពួកមនុស្សប៉ុណ្ណោះទេ ថែមទាំងជាសត្រូវយ៉ាងសាហាវរបស់ពួកមនុស្សថែមទៀត។

ប៉ុន្តែក្នុងសម័យវិទ្យាសាស្ត្រសម្ភារៈនិយម ដែលពួកមនុស្សភាគច្រើន ទន់ខ្សោយខាងសីលធម៌ និងមនុស្សធម៌មានចិត្តគំនិតរាប់អានតែខាងសម្ភារៈ មាស ពេជ្រ លុយ ឡាន ផ្ទះថ្មជាដើមនោះ គេមិនសូវចាប់អារម្មណ៍អួតសរសើរចំពោះអារ្យធម៌ប្រភេទទី១ ដែលមានឋានៈខ្ពង់ខ្ពស់បំផុតក្នុងលោកនេះទេ គេនាំគ្នាចាប់អារម្មណ៍តែខាងអារ្យធម៌ ទី២ ទី៣ និងទី៤ទៅវិញ។ បើចំពោះបុគ្គល គេនិយមអួតសរសើរ តែបុគ្គលណាដែលចេះតុបតែងខ្លួន ចេះស្លៀកពាក់ហឺហា មានមាសពេជ្រ លុយ ឡាន ផ្ទះថ្ម ទោះជននោះរកបានមកដោយទុច្ចរិតក៏ដោយ។ បើចំពោះប្រទេស គេនិយមតែប្រទេសណា ដែលចេះរៀបចំទីក្រុង ផ្ទះ ភូមិឋាន បានល្អថ្កើនថ្កាន ចេះធ្វើគ្រឿងឧបភោគ បរិភោគ បានប្លែកៗតាមក្បួនវិទ្យាសាស្ត្របច្ចេកទេស និងចេះធ្វើគ្រឿងយុទ្ធោបករណ៍ មានកាំជ្រួចហោះ គ្រាប់បរមាណូជាដើម។

បើប្រទេសណា មានសមត្ថភាព អាចបង្កើនសម្ភារៈ ដូចខាងលើនេះបានចម្រើនហើយ គេនាំគ្នាអួតសរសើរឲ្យកិត្តិយសដល់ប្រទេសនោះថា ជាអារ្យប្រទេសធំដុំ ជាមហាប្រទេសជឿនលឿនក្នុងលោក ទោះបីក្នុងផ្ទៃប្រទេសនោះ សម្បូរណ៍ដោយអ្នកលេងបាតផ្សារ កាប់ចាក់ លួចឆក់ មានកូដកម្មញឹកញាប់ មានភេរវកម្មដោយគ្រាប់បែកគ្រាប់កាំភ្លើង


www.elibraryofcambodia.org

សម្ប្រណិអំពើពុករលួយ ពលរដ្ឋភាគច្រើនរងទុក្ខវេទនា ក្រខ្សត់អត់ឃ្លាន បែកបាក់សាមគ្គីធម៌ ប្រកាន់បក្សពួក សម្បុរស្បែក មានអានាធិបតេយ្យ ឬក្នុងប្រទេសនោះគេបំបិទសិទ្ធិ គេប្រើឲ្យធ្វើការដូចសត្វ ឲ្យតែបាយស៊ីមួយចម្អែតៗ យ៉ាងណាក៏ដោយគេមិនសូវគិតគូរប៉ុន្មានទេ គេគិតតែខំផ្សាយឥទ្ធិពល ខាងគ្រឿងឧបភោគបរិភោគ និងគ្រឿងយុទ្ធោបករណ៍ទៅក្រៅប្រទេស ឲ្យពួកបរទេសអួតសរសើរ កោតស្ញប់ស្ញែងតែប៉ុណ្ណោះ។

ចំណែកពលរដ្ឋក្នុងផ្ទៃប្រទេសនោះវិញ អ្នកណាអាចប្រមូលទ្រព្យសម្បត្តិ មាស ពេជ្រ លុយ ឡាន ផ្ទះថ្ម ជាដើម ដោយមធ្យោបាយណាបាន ក៏ចេះតែខំប្រមូលទៅ ឥតគិតគូរពីច្បាប់ទម្លាប់រដ្ឋឡើយ បើជួបប្រទះឧបសគ្គ គេក៏យកប្រាជ្ញនិងទ្រព្យសម្បត្តិដែលរកបាននោះ ជជែកតវ៉ា ដោះសារ គិតគូរកែខ្លួនទៅ បើមិនរួចខ្លួនទេត្រូវស្លាប់កូនប្រពន្ធគេធ្វើអ្នកមានទៅ បើត្រូវជាប់គុក ដល់ចេញមកវិញគេធ្វើអ្នកមានទៅ បើគ្រាន់តែផ្លាស់ទីកន្លែងមួយទៅមួយទេ ក៏ជាលាភរបស់គេទៀត រកមិត្រថ្មី ខំប្រមូលរឹតតែបានច្រើន។ នេះជាទំនៀមរបស់ពួកមនុស្សលោកដែលទន់ខ្សោយខាងសីលធម៌ និងមនុស្សធម៌។

ទំនៀមអាក្រក់នេះ ស្ថិតនៅក្នុងលោកមិនបានយឺនយូរទេ ព្រោះផ្ទុយពីបំណងរបស់មនុស្សលោកភាគច្រើន ជាហេតុនាំឲ្យឆាប់មានគ្រោះថ្នាក់ធំ ឆាប់កើតសង្គ្រាមធំៗ មហន្តរាយធំនេះឯង ដែលញ៉ាំងពួកមនុស្សទាំងនោះ ឲ្យរាងចាល បាក់ស្បាត បែរចិត្តគំនិតទៅរកសម័យវិទ្យាសាស្រ្តសន្តិភាពនិយមវិញ គឺយកវិទ្យាសាស្រ្ត ទៅបម្រើតែនសន្តិភាពម្យ៉ាង។ ពេលនោះ ទើបមនុស្សលោកមានចិត្តគំនិតយល់ត្រូវនិយមរាប់អានអារ្យធម៌ប្រភេទទី ១ វិញ។

## អាយុជីវិតនៃអារ្យធម៌

អារ្យធម៌របស់ជាតិមួយៗ ក្នុងលោក មានអាយុជីវិតរស់នៅ និងចម្រើនរុងរឿងបាន អាស្រ័យពលរដ្ឋមានសម្បជញ្ញជាតិ (Conscience nationale) គឺការមិនវង្វេងភ្លេចជាតិខ្លួន មានជាតិមនសិការ ចេះស្រឡាញ់ជាតិកំណើត មិនមានចិត្តចើកសាវ៉ា ត្រេកត្រអាលតាមអារ្យធម៌បរទេស ចេះស្រឡាញ់អារ្យធម៌ជាតិខ្លួន ស្រឡាញ់វប្បធម៌ជាតិខ្លួន


www.elibraryofcambodia.org

ស្រឡាញ់អក្សរសាស្ត្រជាតិខ្លួន ស្រឡាញ់ប្រពៃណី ទម្លាប់ទំនៀមជាតិខ្លួន ស្រឡាញ់លទ្ធិសាសនាជាតិខ្លួន ស្រឡាញ់បូរាណភាពទឹកដីជាតិខ្លួន ហើយស្ម័គ្រចិត្តធ្វើពលិកម្ម ថែរក្សាការពារ លើកតម្កើងបិយវត្ថុ ដែលខ្លួនស្រឡាញ់នោះស្មើជីវិត។

សម្បជញ្ញជាតិនេះឯង ដែលដឹកនាំពលរដ្ឋក្នុងរដ្ឋមួយៗឲ្យមានចិត្តគំនិតថ្លៃថ្នូរ ចេះនិយមរាប់អាន ប្រើគ្រឿងឧបភោគបរិភោគជាដើម ដែលជាតិធ្វើកើត ទោះវត្ថុនោះមានគុណភាពអន់ថយជាងវត្ថុបរទេសក៏ដោយ និងចេះគោរពដោយស្មោះត្រង់តាមច្បាប់រដ្ឋ មិនប្រព្រឹត្តនូវអំពើពុករលួយក្នុងរដ្ឋ មិនមានគំនិតថោកទាប ជួយបម្រើមនោគមវិជ្ជាបរទេសជាដើម។

សម្បជញ្ញជាតិនេះ កើតមានឡើងបាន ដោយពលរដ្ឋមានចិត្តគំនិតចេះគិតប្រៀបធៀបខ្លួននឹងជនបរទេស ឲ្យឃើញសភាវៈពិតច្បាស់ផ្ទាល់ខ្លួនថា «គេនិងអញមានជាតិផ្សេងគ្នា ជាតិគេនិងជាតិអញ មានសិទ្ធិសេរីភាព រស់នៅក្នុងលោកដូចគ្នា បើគេគោរពលទ្ធិសាសនាជាតិគេ អញត្រូវគោរពលទ្ធិសាសនាជាតិអញដែរ គេខំបម្រើមនោគមវិជ្ជាជាតិគេ អញត្រូវខំបម្រើមនោគមវិជ្ជាជាតិអញដែរ គេនិយមប្រើ និយាយភាសាអក្សរសាស្ត្រជាតិគេ អញត្រូវនិយមប្រើនិយាយភាសាអក្សរសាស្ត្រជាតិអញដែរ គេខំរក្សាការពារ បូរាណភាពទឹកដីជាតិគេ អញត្រូវខំរក្សាការពារបូរាណភាពទឹកដីជាតិអញដែរ ។ល។ បើអញឆោតលង់ទៅជួយស្រឡាញ់ ជួយប្រើ ជួយការពារឲ្យគេ អញជាខ្ញុំកញ្ជះគេ ជាមនុស្សអន់គម្រក់ថោកទាបជាងគេក្នុងលោក ជីវិតរបស់អញ ដែលរស់នៅក្នុងលោកនេះ ជាជីវិតសត្វពាហណៈសម្រាប់តែធ្វើការបម្រើគេ»។

កាលបើមានចិត្តគំនិត ចេះគិតប្រៀបធៀបសមហេតុសមផលយ៉ាងនេះហើយ សម្បជញ្ញជាតិកកើតមានឡើង ចេះស្រឡាញ់ជាតិខ្លួន ទាំងកាយ វាចា ចិត្ត មិនស្រឡាញ់តែមាត់ឡើយ។ ជាបឋម ចេះស្រឡាញ់ភាសា និងអក្សសាស្ត្រជាតិ ខំយកចិត្តទុកដាក់សិក្សា ឲ្យបានចេះដឹងច្បាស់លាស់ អាចដឹងស្គាល់គុណសម្បត្តិជាតិខ្លួនបាន។


www.elibraryofcambodia.org

ព្រោះថា ការមិនចេះភាសា និងអក្សរសាស្ត្រជាតិច្បាស់លាស់ ជាគ្រោះថ្នាក់ធំមួយរបស់ជាតិ ដូចជាខ្វាក់ភ្នែកជាតិ មើលជាតិឯងមិនឃើញ មានតែភ្នែកបរទេសម្ខាង មើលឃើញតែខាងបរទេសនេះឯង ដឹកនាំកាយ វាចា ចិត្ត ឲ្យមានសកម្មភាពតែខាងបរទេស ពេញចិត្តអួតសរសើរតែបរទេស ស្រឡាញ់តែអារ្យធម៌បរទេស ស្អប់ខ្ពើមអារ្យធម៌ជាតិខ្លួន បន្ទុះបង្អាប់ជាតិខ្លួន គឺនិយមប្រើ និយាយតែភាសា អក្សរបរទេស ចូលចិត្តតែប្រើគ្រឿងឧបភោគបរិភោគបរទេស ស្រឡាញ់តែមនោគមវិជ្ជាបរទេស ហ៊ានក្បត់ជាតិខ្លួន ខំជួយពង្រីក សេដ្ឋកិច្ចវប្បធម៌ និងនយោបាយបរទេស ។ល។

ប៉ុន្តែបើបានចេះដឹងច្បាស់លាស់ នូវភាសា អក្សរសាស្ត្រជាតិ និងបរទេសស្មើគ្នា ជាការប្រសើរបំផុត ដូចជាមនុស្សមានភ្នែកភ្លឺទាំងពីរ។ ប៉ុន្តែត្រូវមានសម្បជញ្ញជាតិផង។

(ចប់អារ្យធម៌សាកលដោយសង្ខេប)

១០៤

## អារ្យធម៌ខ្មែរ

ដើម្បីស្គាល់អារ្យធម៌ខ្មែរ ឲ្យបានច្បាស់លាស់ ត្រូវស្គាល់សម័យ ប្រភព អនុប្រភព និងនិយមនៃអារ្យធម៌ខ្មែរជាមុនសិន។

## សម័យនៃអារ្យធម៌ខ្មែរ

១- សម័យបុរេប្រវត្តិ ពី ០ គ.ស. ដល់ គ.ស. ៦៨

២- សម័យបុរេអង្គរ ពី គ.វ. [2]ទី ១ ដល់ ទី ៨

៣- សម័យអង្គរ ពី គ.វ. ទី ៩ ដល់ ទី ១៤

៤- សម័យបច្ឆាអង្គរ ពី គ.វ. ទី ១៥ ដល់ ទី ១៩

៥- សម័យអាណានិគម និងឯករាជ្យ ពីគ.ស. ១៨៦៣ ដល់ គ.ស. ១៩៧០

## ប្រភពនិងអនុប្រភពនៃអារ្យធម៌ខ្មែរ

[2] គ.វ. អានថា គ្រិស្តសតវត្សរ៍


www.elibraryofcambodia.org

១- ប្រភពមនខ្មែរ

២- អនុប្រភពឥណ្ឌា

៣- អនុប្រភពចិន

៤- អនុប្រភពបស្ចិមប្រទេស។

## និយមនៃអារ្យធម៌ខ្មែរ

១- ខេមរនិយម

២- ពុទ្ធនិយម

៣- ព្រហ្មនិយម

៤- បរទេសនិយម។

ពាក្យថាប្រភព (Source) គឺដើមកំណើតនៃអារ្យធម៌ខ្មែរ បានផ្តួចផ្តើមកើតឡើងអំពីជនជាតិមន-ខ្មែរ ដែលជាម្ចាស់ដើមបំផុតនៃសុវណ្ណភូមិ (ឧបទ្វីបអាស៊ីភាគអាគ្នេយ៍) នេះផ្ទាល់តែម្តង មិនមែនជនជាតិ ឥណ្ឌា-ចិន និងបស្ចិមប្រទេស មកបង្កើតឲ្យខ្មែរ ឬខ្មែរចម្លងយកពីគេមកឡើយ។

ឯអារ្យធម៌ ឥណ្ឌា-ចិន-បស្ចិមប្រទេស ដែលផ្សាយចូលមកក្នុងប្រទេសកម្ពុជាដោយឯកឯងនោះ គ្រាន់តែជាឧបករណ៍គ្រឿងផ្សំ ឬជាជីវជាតិ ជួយបម្រើអារ្យធម៌ខ្មែរ ឲ្យកាន់តែរីកដុះដាលឡើងប៉ុណ្ណោះ។

អាស្រ័យហេតុនេះ ទើបអារ្យធម៌ ឥណ្ឌា-ចិន-បស្ចិមប្រទេសនោះ ចាត់ជាប្រភពរបស់អារ្យធម៌ខ្មែរ មិនបានឡើយ គ្រាន់តែជាអនុប្រភពបន្ទាប់បន្សំប៉ុណ្ណោះ ព្រោះអារ្យធម៌ខ្មែរជាអារ្យធម៌ខាងអម្បូរ អូស្ត្រូ-អាស្យាទីក (Austro-asiatiques) និងអូស្ត្រូ-នេស៊ីយែន (Austro-nésiennes) ដែលមានកំណើតឧប្បត្តិកកើតឯង នៅលើផែនដី លើជ្រោយ លើកោះនានានៅតាមសមុទ្រប៉ាស៊ីហ្វិក មិនមែនជាអារ្យធម៌ខាងអម្បូរ ឥណ្ឌូ-អឺរ៉ុប (Indo-européennes) ដែលមានកំណើតឧប្បត្តិក កើតនៅឥណ្ឌា-នៅអឺរ៉ុបឡើយ។





www.elibraryofcambodia.org

# អារ្យធម៌ខ្មែរសម័យបុរេប្រវត្តិ
## ប្រភពមនខ្មែរ
(ពី ០ គ.ស. ដល់ ឆ្នាំ ៣០៩ មុន គ.ស.)

ប្រភពមនខ្មែរនេះឯង ដែលអារ្យធម៌ខ្មែរ បានឧប្បត្តិកកើតឡើងដំបូងបំផុត ក្នុងសម័យបុរេប្រវត្តិ គឺសម័យមុនប្រវត្តិសាស្ត្រខ្មែរ មុនគ្រិស្តសករាជរាប់ពាន់ឆ្នាំ។

មននិងខ្មែរ ជាគូដែកសាងអារ្យធម៌ វប្បធម៌ជាតិក្នុងកុលសម្ពន្ធមួយ នៅឧបទ្វីបអាស៊ីភាគអាគ្នេយ៍។ អ្នកប្រវត្តិសាស្ត្រ បានរកឃើញថា ប្រជាជននៅឧបទ្វីបអាស៊ីភាគអាគ្នេយ៍នេះ បាននាំគ្នាចុះបន្តបន្ទាប់គ្នា ពីយូណាន តំបន់ដីខ្ពស់ តាមទន្លេក្រហម សាលូអង់ ឥរាវតី និងតាមទន្លេមេគង្គមកបង្កើតជាភូមិភាគឧបទ្វីបនេះឡើង ហើយលោយឈាមជ័រចូលគ្នា។ ក្រោយមកបង្កើតជាកុលសម្ពន្ធ ឥណ្ឌូណេស៊ី មេឡាណេស៊ី និងកុលសម្ពន្ធមនខ្មែរ។

មនតាំងទីឋាននៅភាគបស្ចិមនៃឧបទ្វីប ខ្មែរតាំងទីឋាននៅភាគបូព៌ានៃឧបទ្វីប។ ជនជាតិទាំងពីរនេះ ជាមិត្ររួមវប្បធម៌ អារ្យធម៌ជាមួយគ្នា ទើបមានទម្លាប់ទំនៀម ពាក្យសម្ដីភាសាដូចគ្នា ស្រដៀងគ្នាច្រើនណាស់។ ក្រោយមក មនក្លាយខ្លួនជាភូមាទៅ ឯខ្មែរជាពូជឆ្អឹងដែកស្បែកពេជ្រនៅរឹងជំហរជាខ្មែរដដែល រហូតដល់សព្វថ្ងៃនេះ។

ក្នុងសៀវភៅ Les populations du cambodge របស់លោក G. olivier ថា មន ខ្មែរ និងមុណ្ឌា នាំគ្នាចុះមកពីទីបេត៍ ដោយហេតុអ្វីមួយ មកនៅឥណ្ឌា រួចមកនៅត្រង់ឥណ្ឌូចិននេះឯង។ ក្នុងសៀវភៅ L'asie ថា មន ខ្មែរ ត្រូវពួកទ្រាវិទ (dravidiens) រុញច្រានឲ្យចេញពីឥណ្ឌាមក។ ឃើញសមដំណើរសេចក្ដីគ្នាដែរ គឺមុនដំបូង មន-ខ្មែរ-មុណ្ឌា មានកំណើតនៅទីបេត៍ តំបន់ដីខ្ពស់ បានាំគ្នាចុះមកនៅឥណ្ឌា ត្រូវពួកទ្រាវិទបៀតបៀន ទើបមនខ្មែរនាំគ្នាមកនៅត្រង់ឥណ្ឌូចិនតែម្ដង។

ឯពួកមុណ្ឌា ជាជនជាតិភាគតិច មិនបានចុះមកទេ នាំគ្នានៅក្នុងប្រទេសឥណ្ឌា ខាងទិសឦសានខ្លះ ខាងពាយ័ព្យខ្លះ សព្វថ្ងៃនៅក្នុងរដ្ឋ Orissa (អូរិស្ស) ឥណ្ឌាហៅពួកនេះថា ជនជាតិកម្ពុជា។ ពួកមុណ្ឌានេះជាជាតិខ្មែរយើងដែរ ចាស់ៗបុរាណថា ខ្មែរដើម គឺខ្មែរដែលនៅទីបេត៍ពីដើមជាមួយគ្នា។

ក្នុងឯកសាខ្លះរបស់ខ្មែរយើងថា មន-ខ្មែរ ដែលនាំគ្នាចុះពីយូណាន ឬយូណង់នោះ គឺចុះមកពី យោនកប្រទេស ត្រង់នេះហាក់ដូចជាមិនសូវសម ព្រោះយោនកប្រទេសនេះ គឺប្រទេសហ្វ្រិក ដូចជាឆ្ងាយពីគ្នាណាស់។ នៅមានយោនកៈមួយទៀត ដែលខ្មែរយើងពី

បុរាណ ហៅពួកលាវប៉ែកខាងលិចថា យោនក:ដែរ នេះក៏រិតតែមិនសមទៅទៀត ព្រោះអ្នកដែលមកនៅលើទឹកដីត្រង់ឥណ្ឌូចិន មុនគេបំផុតនោះ គឺ មន-ខ្មែរ-ចាម តែបីគត់ និង ម៉ាឡេស ថ្វា នៅលើកោះនានា ឯសៀម លាវ យួន ជាពួកជនជាតិ បញ្ញើក្អែក នៃឧបទ្វីបអាស៊ីអាគ្នេយ៍នេះទេ។

ដើម្បីរាវរក អារ្យធម៌ខ្មែរក្នុងសម័យបុរេប្រវត្តិ ឲ្យឃើញរូបរាងច្បាស់លាស់នោះ គួរលើកយកអត្ថបទភាគខាងដើមនៃពង្សាវតារប្រទេសកម្ពុជា ដែលបារាំងសរសេរឲ្យយើងរៀនក្នុងសម័យអាណានិគមនិយមនោះ មកពិចារណា គឺត្រង់ដើមកំណើតប្រទេសកម្ពុជា ដែលមានសេចក្ដីថា «ពីព្រេងនាយប្រទេសកម្ពុជា ជាសមុទ្រ លាតសន្ធឹងទៅខាងកើតទល់នឹងជួរភ្នំអណ្ណាម ខាងជើងទល់នឹងភ្នំដងរែក ខាងលិចទល់នឹងភ្នំកំចាយ មានកោះជាច្រើននៅក្នុងផ្ទៃសមុទ្រនោះ។ ទន្លេមេគង្គ បាននាំដីល្បាប់មកចាក់បន្តិចម្ដងៗ រហូតបានកើតជាកោះយ៉ាយធំ ឈ្មោះថា កោះគោកធ្លក តាំងនៅត្រង់អង្គរបុរី ស្រុកព្រៃកប្បាស ខេត្តតាកែវសព្វថ្ងៃនេះ។

លុះដីមានទំហំកាន់តែធំឡើង មានមនុស្សមកតាំងទីលំនៅផ្សេងៗពីគ្នា មិនចំណុះចុះចូលគ្នាឡើយ។ មនុស្សទាំងនោះស្រាតខ្លួនទទេ មានសាក់ពេញខ្លួន មិនចេះត្បាញសំពត់ស្លៀកពាក់ឡើយ។ មនុស្សខ្លះសង់ផ្ទះនៅលើគោក រកស៊ីបរបាញ់សត្វ ខ្លះនៅដោយទូករកស៊ីនេសាទត្រី ។ល។

សូមបើកវង់ក្រចក សាកល្បងធ្វើវិចារណកម្មត្រិះរិះពិចារណាឲ្យបានវែងឆ្ងាយដូចតទៅ ៖

(ក្នុងអត្ថបទខាងលើនេះ យើងទាំងអស់គ្នា ធ្លាប់ស្ដាប់យល់ស៊ប់ដរាបដល់ស្លាប់គំនិតសូន្យឈឹងថា បុព្វជនខ្មែរ សម័យនោះល្ងង់ណាស់ គ្មានអារ្យធម៌ទេ ជាមនុស្សព្រៃដូចបុព្វជនជាតិដទៃៗក្នុងលោកដែរ។

ប៉ុន្តែបើស្ដាប់ប្រកបដោយវិចារណញ្ញាណ ពិតជាយល់ច្បាស់ថា បុព្វជនខ្មែរក្នុងសម័យច្រើនរយឆ្នាំ មុន គ.ស. ជាមនុស្សមានអារ្យធម៌ ចេះដឹងជឿនលឿនជាងគេទៅវិញ មិនមែនជាមនុស្សព្រៃល្ងង់ខ្លៅឡើយ ព្រោះថា បើល្ងង់ខ្លៅមែននោះ បុព្វជនខ្មែរពិតជានៅតាមគល់ឈើ រូងភ្នំ ដូចបុព្វជនជាតិដទៃទៅហើយ មិនចេះធ្វើទូក ជាផ្ទះនៅលើទឹកកើតឡើយ។ ការធ្វើទូកនៅបានមួយគ្រួសារ មិនមែនយកដើមត្នោតមកពុះលុងធ្វើជាផ្ទះនៅលើទឹកបានឡើយ ពិតជាមានបច្ចេកទេស (Techniques) ចេះតទូក


www.elibraryofcambodia.org

ចេះបិទលាបជ័រ ចេះធ្វើនាប ទ្វារបង្អួច ដំបូល ដែលមនុស្សភាគច្រើនក្នុងសម័យហាន ព្រះចន្ទនេះល្ងង់ធ្វើមិនកើត សូម្បីតែទូកតូចមួយ ក៏ជួលជាងឲ្យធ្វើដែរ។

បើដូចនេះ តើគេគួរស្តាប់យល់ថា បុព្វជនខ្មែរល្ងង់ជាមនុស្សព្រៃ ដូចបុព្វជនបរទេសខ្លះ ដេលនៅតែដោយគល់ឈើ រូងភ្នំនោះដែរឬ?។

មួយទៀតថា មានសាក់ពេញខ្លួនផង តើអ្នកប្រាជ្ញណាទៅសាក់ឲ្យក្នុងសម័យនោះ ព្រោះសាក់នេះ ជាសិល្បកម្មមួយប្រកបដោយបច្ចេកទេស ខាងវណ្ណៈអក្សរ គឺគេគូរយ័ន្ត តំណាងវត្ថុសក្តិសិទ្ធិ មន្តអាគម ជាក្បាច់ក្បូរ ឬជារូបអ្វីៗមានលេខ សូន្យ ឯក-ទោ-ត្រី-កាកបាទ និងអក្សរនខ្វាក់ជាដើម ។ល។ នៅលើសាច់មនុស្ស ហើយចាក់នឹងម្ជុលឬឈើស្រួចបញ្ចូលទឹកខ្មៅ ឬទឹកក្រហម ឲ្យជិតជាប់នៅក្នុងសាច់ នេះបើតាមយើងឃើញរូបសាក់ ដែលចាស់បុរាណយើងឆ្លាក់លើថ្ម ឬគូរនៅក្នុងក្រាំងក្បួនតម្រា។ បើយើងបដិសេធថា រូបសាក់ក្នុងសម័យនោះ គ្មានប្រើលេខអក្សរទេ ក៏ហើយទៅចុះ នៅសល់ត្រង់សិល្បៈគំនូរក្រឡា បីជ្រុង បួនជ្រុង-កាកបាទ ក្បាច់ភ្ញី ស្លឹកឈើ ឬជារូបសត្វនោះដែរ ត្រង់នេះហើយដែលបង្ហាញឲ្យយើងដឹងថា សម័យនោះ ខ្មែរយើងចេះប្រើវណ្ណៈគឺស្នាមគំនូស-អក្សរតំណាងមន្តអាគមមនោគតិ និងចេះធ្វើទឹកសរសេរ ប្រដាប់សរសេរ (ប៉ាកកា) ហើយ។

បើដូចនេះ តើគេគួរស្តាប់យល់ថា បុព្វជនខ្មែរល្ងង់ដូចបុព្វជនបរទេស ជាមនុស្សព្រៃសុទ្ធនោះដែរឬ?។

ត្រង់ដែលថា ខ្មែរសម័យនោះស្រាតខ្លួនទទេនោះពិតជានិយាយស្មាន ទៅតាមការធ្លាប់ដឹង ធ្លាប់ឃើញបុព្វជនបរទេសស្រាតខ្លួនទទេនោះឯង ព្រោះមានតំបន់មួយ នៅស្រុកបារាំង នៅមានមនុស្សស្រាតដល់សព្វថ្ងៃនេះ។ ឯបុព្វជនមនខ្មែរ មិននិយមការស្រាតនទលនោះឡើយ គឺមានប្រដាប់បិទបាំងកេរ្តិ៍ខ្មាស មានភស្តុតាងសល់នៅ តាមចម្លាក់ថ្ម និងតាមការនិយមប្រើរបស់ខ្មែរលើយើង សព្វថ្ងៃនេះស្រាប់។

ឯការនិយមប្រើសម្លៀកបំពាក់ តែបន្តិចបន្តួចរបស់បុព្វជនខ្មែរ តាំងពីបឋមសម័យរហូតដល់សម័យមហានគរនោះ មិនមែនមកពីមិនចេះធ្វើសំពត់ ដូចធ្លាប់ស្តាប់យល់នោះឡើយ ព្រោះគ្រឿងលំអរបស់មនុស្សលោក មានពីរបែបគឺ ៖

១- គេនិយមយក សម្បុរស្បែក និងសាច់ដុំ ជាលំអ ទើបគេបិទបាំងតែកេរ្តិ៍ខ្មាសប៉ុណ្ណោះ ដើម្បីបញ្ចេញសម្បុរស្បែកនិងសាច់ដុំ ជាគ្រឿងលំអ នេះជាអារ្យធម៌មួយក្នុងលោកតាមកាលនិយម។


www.elibraryofcambodia.org

២- គេនិយមយកសាច់សំពត់ រាងសំពត់ជាលំអ ដូចបច្ចុប្បន្ននេះ គេកាត់សម្លៀកបំពាក់វែងៗ បិទបាំងរូបកាយជិតទុកតែត្រឹមដៃ កជើង និងមុខប៉ុណ្ណោះ។

បើដូចនេះ តើគេគួរស្តាប់យល់ថា បុព្វជនខ្មែរ ដែលមិនស្លៀកពាក់ដូចសព្វថ្ងៃនេះ ជាមនុស្សព្រៃល្ងង់ខ្លៅ មិនចេះត្បាញសំពត់ស្លៀក ដូចបុព្វជនបរទេសដែរឬ? បើក្នុងសម័យឋានព្រះច័ន្ទនេះ មានជនបរទេសជាច្រើន ក្នុងមហាប្រទេសវិទ្យាសាស្ត្រ ដែលសម្បូរណ៍រោងចក្រតម្បាញ បាននាំគ្នាស្រាតនទលគក បញ្ចេញកេរ្តិ៍ខ្មាស ស្រមេមស្រមាមអស់គ្មានសល់ថែមទាំងនាំគ្នាស្រាតប្រឡង បង្ហាញកេរ្តិ៍ខ្មាសទស្សនិកជនទៀតផង ឃើញថា ស្រាតហួសសម័យបុព្វជនខ្មែរ ជាអតិបរមាស្រាតទាល់តែអស់លក្ខណៈមនុស្សទៅហើយ តើពួកអ្នកស្រាតទាំងអស់នេះ មកពីមិនចេះត្បាញសំពត់ មកពីគ្មានសំពត់ស្លៀកដែរឬ? ឬក៏ជនអាក្រាតទាំងអស់នោះ ត្រូវជាសិស្សគុណរបស់ពួកអចេលក៍នៅប្រទេសឥណ្ឌា?) ។ សូមបិទវង់ក្រចកត្រឹមនេះចុះ។

រឿងបុព្វជនខ្មែរយើងនេះ បើតាមការពិនិត្យសង្កេតងតាមប្រវត្តិ សិលាចារឹកដែលមានសេសសល់នៅដល់សព្វថ្ងៃហើយយកមកធ្វើវិចារណកម្ម ដូចក្នុងវង់ក្រចកខាងលើ និងតាមបុរាណវត្ថុ ដែលគេបានរកឃើញ នៅសំរោងសែន អន្លង់ផ្តៅ ក្នុងស្រុកកំពង់ត្រឡាច (កំពង់ឆ្នាំង) និងម្លូព្រៃ ក្នុងស្រុកព្រំទេព (កំពង់ធំ) ដែលជាឯកសារតាងនៃអារ្យធម៌វប្បធម៌ខ្មែរសុទ្ធៗក្នុងសម័យបុរេប្រវត្តិនោះ ឃើញវត្ថុខ្លះធ្វើពីដែកស្ពាន់ លង្ហិន សំរឹទ្ធិ ខ្លះធ្វើពីដីឥដ្ឋ ខ្លះធ្វើពីថ្មរលីង ខ្លះធ្វើពីឆ្អឹងសត្វ ដូចផ្តៅពួថៅ ពន្លាក ញញួរ ខ្មោស កាំបិត អង្រែ ត្រល់ ផ្លែសន្ទូច កណ្តៀរ និងគ្រឿងអលង្ការផ្សេងៗ ដែលមានខ្លះធ្វើពី ខ្យង ខ្ចៅ ជាដើមនោះ ឃើញថា ទឹកដៃសិល្បករខ្មែរសម័យនោះ មានកម្រិតខ្ពស់ដែរហើយ ខ្មែរចេះធ្វើឧស្សាហកម្ម ដុត ឥដ្ឋ សិតស្ពាន់ លង្ហិនស្រេចទៅហើយ។

បុរាណវត្ថុទាំងនេះ ប្រវត្តិវិទូខ្មែរ និងបរទេសដែលបានឃើញ ស្មានថា មានចំណាស់ប្រហែល ២០០ ឬ ៣០០ ឆ្នាំមុន គ.ស.។ បើគិតតាមកាលបរិច្ឆេទនៃពុទ្ធសាសនាផ្សាយចូលមកប្រទេសខ្មែរជាដំបូងបំផុត តាមឯកសារដែលផ្សាយចេញពីប្រភពកោះសិរីលង្កា និងពីប្រភពចិននោះ បុរាណវត្ថុទាំងនេះ ត្រូវមានអាយុជាង ៣០០ ឆ្នាំ មុន គ.ស. ទើបត្រូវជាង ព្រោះពុទ្ធសាសនាដែលនាំអារ្យធម៌ឥណ្ឌា ចូលមកប្រទេសខ្មែរដំបូងបំផុត ក្នុងឆ្នាំ ៣០៩ មុន គ.ស.។ ឯសាសនាព្រាហ្មណ៍ចូលមកប្រទេសខ្មែរ ក្រោយពុទ្ធសាសនាវិញទេ គឺចូលមកតាមស្តេច ហ៊ុន-ទៀន ដែលហៅថា ព្រាហ្មណ៍ ហ៊្វ-ឥន្ទៀន ក្នុងគ្រិស្តសតវត្សរ៍ទី ១។


www.elibraryofcambodia.org

បណ្ដាបុរាណវត្ថុ ដូចរាប់ឈ្មោះខាងលើនេះ ឃើញមានត្រល់ ដែលជាឧបករណ៍ខាងវាយនភណ្ឌ សម្រាប់ត្បាញសំពត់ផងដែរ ឃើញថា បុព្វជនខ្មែរមិនមែនល្ងង់ មិនចេះត្បាញសំពត់ស្លៀក ស្រាតខ្លួនទទេ ទាល់តែជនជាតិឥណ្ឌា គឺស្ដេច ហ៊ុន-ទៀន មកនាំត្បាញនោះឡើយ។

សូមបញ្ជាក់ថា ក្នុងខាងដើមសម័យបុរេប្រវត្តិនេះគ្មានអារ្យធម៌ វប្បធម៌ ជាតិសាសន៍ណា ចូលមកលាយឡំឡើយ អ្វីៗដែលខ្មែរចេះដឹង ធ្វើកើតក្នុងសម័យនោះ គឺជាគំនិតខ្មែរ ជារបស់ខ្មែរ ជាស្នាដៃខ្មែរ ជាខេមរនិយមសុទ្ធសាធដូចជាវប្បធម៌ អារ្យធម៌ និងភាសាជាដើម សុទ្ធតែកើតមកពីប្រភពមនខ្មែរនេះឯង។

តើមនខ្មែរនេះ មានចំណេះចេះដឹងពីណាមក? ដូចជាចំណេះខាងការធ្វើទូក ខាងសាក់ ខាងតម្បាញ ខាងភាសា និងខាងគ្រឿងឧបភោគបរិភោគផ្សេងៗ ដូចមានរាប់ឈ្មោះក្នុងបញ្ជីបុរាណវត្ថុខាងលើនេះជាដើម។

រឿងបុព្វជនខ្មែរនេះ មានអ្នកប្រាជ្ញខាងប្រវត្តិសាស្ត្រជាច្រើនរូប ដែលបានឃើញបុរាណវត្ថុ នៅស្ថានីយសំរោងសែនជាដើមនេះហើយ គេសន្និដ្ឋានថា បុព្វជនខ្មែរមិនមែនរស់នៅក្នុងយុគទាំង ៤ គឺយុគថ្មចាំង យុគនវសិលា យុគស្ពាន់លង្ហិន ឬយុគដែកឡើយ ព្រោះបុរាណវត្ថុទាំងនោះមានគ្រប់យុគទាំងអស់ គេសន្និដ្ឋានថា បុព្វជនខ្មែរដែលបានរស់នៅក្នុងអារ្យធម៌បែបនេះ បុព្វជននៅអាស៊ីភាគខាងត្បូងព្រោះនៅក្នុងជំនាន់ជាមួយគ្នានេះ បុព្វជននៅអាស៊ីភាគខាងត្បូងទូទៅ មានលក្ខណៈសំខាន់ដូចតទៅនេះ គឺ ៖

- ចេះគោរពជឿ ទេពតាម អារក្ស អ្នកតា គោរព មាតាជាធំ ហៅថាព្រះមេដែលក្លាយមកជាម៉ែ
- ចេះបញ្ចុះសព
- ចេះប្រើ គោ ក្របី ធ្វើស្រែ ចម្ការ
- ចេះស្លដែកស្ពាន់
- ហ៊ានធ្វើដំណើរដោយទូកតាមមហាសាគរ។

ឯបុព្វជនខ្មែរយើង ក៏ប្រកបដោយលក្ខណៈទាំងអស់នេះដែរ។ ចំពោះការគោរពមាតាជាធំនេះ នៅជាប់ក្នុងសម្ដីភាសារបស់ខ្មែរយើងរហូតដល់សព្វថ្ងៃ ដូចពាក្យថា «មេភូមិ មេស្រុក មេផ្ទះ មេទឹក មេខ្យល់ មេជំបូល មេទ្វារ មេបង្ហួច ។ល។» តើហេតុអ្វីក៏ហៅថា «មេ» មិនហៅថា «បា» ផង ដូចជា មេភូមិ មេស្រុក ជាដើម សព្វថ្ងៃឃើញតែមនុស្សប្រុសធ្វើ


www.elibraryofcambodia.org

ម៉េចមិនហៅថា «បាភូមិ បាស្រុក» ទៅយកពាក្យថា «មេ» សម្រាប់ហៅមនុស្សស្រីមកប្រើវិញ?

នេះជាភស្តុតាមបញ្ជាក់ថា បុព្វជនខ្មែរយើងជាអារ្យជន ដូចអារ្យជននៅអាស៊ីភាគខាងត្បូង ដែលនិយមគោរពមាតាជាធំដែរ ឲ្យតែអ្វីដែលជាធំជាងគេ សុទ្ធតែហៅថា «មេ» ទាំងអស់ រហូតដល់អ្នកគ្រប់គ្រងដឹកនាំសង្គមជាតិ ក៏គេរើសយកស្ត្រី ឲ្យធ្វើជាធំដែរ ដូចឲ្យធ្វើស្តេចជាដើម ទើបខ្មែរយើងជំនាន់ដើមមានតែស្តេចស្រីទេ សោយរាជ្យតៗរហូតមកដល់ព្រះនាងលៀវ-យី ក្នុង គ.ស. ទី ១។

ម្យ៉ាងទៀត ដោយហេតុការគោរពស្ត្រីមាតាជាធំនេះឯង ទើបក្នុងពិធីអាពាហ៍ពិពាហ៍ខ្មែរ បុរសត្រូវចូលទៅគោរពស្ដីដណ្ដឹងស្ត្រី លើកជំនូនទៅជូនស្ត្រី តាមបញ្ជារបស់មេបាខាងស្រី ទៅរៀបពិធីខាងផ្ទះស្ត្រី។ ពីសម័យបុរាណ កូនកម្លោះត្រូវទៅធ្វើកម្មករបម្រើមាតាបិតាខាងស្រី ជាច្រើនខែផងទម្រាំបានរៀបការ បើមារយាទមិនបាន ធ្វើការបម្រើគេមិនល្អ គេផ្ដាច់ចោល បណ្ដេញឲ្យមកផ្ទះវិញក៏សឹងមាន។

អាស្រ័យហេតុនេះឯង ដែលនាំឲ្យយើងសន្និដ្ឋានបានថា បុព្វបុរសខ្មែរ មិនមែនអ្នកល្ងង់ មិនមែនជាមនុស្សព្រៃ ដែលកើតក្លាយពីសត្វមកហើយ រស់នៅក្នុងព្រៃយូរៗ ទើបមានការចេះដឹងបន្តិចៗឡើង ដូចបុព្វជនបរទេសនោះឡើយ គឺពិតជាពួកជនចេះដឹងជឿនលឿនមួយក្រុម នៅយូណាន ឬទីបេត៍ តំបន់ដីខ្ពស់ បាននាំគ្នាចុះមកដីទាបតាមទន្លេ ដោយហេតុណាមួយ មានហេតុក្នុងភូមិភាគដីខ្ពស់នោះ ខ្វះជីវជាតិប្រកបអាជីវកម្មជាដើម។ ជនជាតិនេះមិនមែនជាចិន មិនមែនជាពូងចិន ដូចអ្នកខ្លះធ្លាប់ស្មាននោះឡើយ ព្រោះជនជាតិនេះមានសម្បុរខ្មៅស្រអែម សក់រួញ មាឌមាំ ទំហំមធ្យម ធម្មជាតិឲ្យឈ្មោះថា មន-ខ្មែរ ឬ មន-ខម។ លុះដល់មកទីទំនាបហើយក៏នាំគ្នារើស ទីជីជយភូមិ ចាប់ស្ថាបនាជាកុលសម្ព័ន្ធមួយៗឡើង ដរាបកើតបានជាមហាសង្គមខ្មែរ ជាប្រទេសខ្មែរ ជាមហាសង្គមមន ជាប្រទេសមនក្នុងលោក។

អ្នកដែលមានសមត្ថភាព អាចកសាង បណ្ដុះបណ្ដាលឲ្យកើតមានជាជាតិ ជាប្រទេសមួយៗក្នុងលោក ហើយមានបុរាណវត្ថុ ទុកជាភស្តុតាង នៅរាប់ពាន់ឆ្នាំដូច្នេះ មិនមែនជាមនុស្សព្រៃឡើយ គឺពិតជាមហាបុរសមានប្រាជ្ញា មានចិត្តមុតមាំដាច់ស្រេច ស្វាហាប់ជាញជ័យ តៗមកដល់សម័យមហានគររហូតមកដល់សព្វថ្ងៃនេះ។


www.elibraryofcambodia.org

ប៉ុន្តែគួរឲ្យស្ដាយណាស់ ដែលយើងមិនអាចដឹងឲ្យវែងឆ្ងាយបានថា មហាបុរសជាប្រធានអ្នកធ្វើការបដិវត្តន៍ដឹកនាំសង្គមជាតិខ្មែរ ក្នុងបឋមសម័យនោះឈ្មោះអ្វីឡើយ ព្រោះជាសម័យមុនប្រវត្តិសាស្ត្ររាប់ពាន់ឆ្នាំហើយ។

រឿងអ្នកចេះដឹងជឿនលឿន បាននាំគ្នាទៅនៅក្នុងព្រៃ ក្នុងទីដែលគ្មានមនុស្សធ្លាប់នៅចាប់កសាងជាជាតិ ជាប្រទេសមួយឡើងនេះ មិនមែនមិនធ្លាប់មានឡើយ ដូចជនជាតិសាក្យជាម្ចាស់នៃនគរកបិលពស្ដុ ដែលជាជាតិភូមិ ព្រះអរហន្តសម្មុទ្ធនោះជាភស្តុតាងស្រាប់។

រឿងនោះ មានដំណាលក្នុងគម្ពីរពុទ្ធសាសនាថា «ពីព្រេងនាយ នៅក្នុងជម្ពូទ្វីបភាគខាងជើងនៃហិមវន្តប្រទេសក្នុងសហភាពឥណ្ឌាសព្វថ្ងៃនេះ មានព្រះរាជាមួយអង្គព្រះនាមឱក្កាករាជ ដោយសេចក្ដីស្លាំងភ្លាត់របស់ព្រះអង្គ ដែលបានព្រះរាជទានពរ ចំពោះមហេសីទី២ ឲ្យរើសយកពរតាមបំណងនោះ ព្រះនាងក៏ទូលសុំរាជសម្បត្តិ ឲ្យរាជឱរសរបស់ព្រះនាងដើម្បីរក្សាពាក្យសច្ចៈ ព្រះរាជាបានត្រាស់បង្គាប់ រាជឱរស ៤ ព្រះអង្គ និងរាជធីតា ៥ ព្រះអង្គ ដែលប្រសូត អំពីមហេសីទី១ ឲ្យនាំគ្នាចេញផុតពីព្រំដែន ព្រះនគរសិន។

ព្រះអង្គម្ចាស់ទាំង ៩ អង្គ និងពួករាជបរិពារ បានលះបង់មាតុភូមិ ទៅគង់នៅក្នុងព្រៃហេមពន្ត ជិតអាស្រមកបិលតាបស ចាប់ត្រួសត្រាយទីព្រៃហេមពន្ត ជិតអាស្រមកបិលតាបស ចាប់ត្រួសត្រាយទីព្រៃធ្វើជាភូមិលំនៅ ស្ថាបនាជាសង្គមជាតិមួយឡើង ដោយសព្វព្រះទ័យផ្សំផ្គុំព្រះរៀម និងព្រះអនុជតាមលំដាប់វ័យ ជាស្វាមីភរិយា នៅសល់តែព្រះរាជធីតាជាព្រះរៀមមួយព្រះអង្គ ទុកជាទីគោរពដូចព្រះមាតា។

តមក ក៏បានកើតជាជនជាតិសាក្យៈ កើតជានគរកបិលពស្ដុឡើងក្នុងលោក។ ព្រះសម្មុទ្ធទ្រង់សោយព្រះជាតិក្នុងត្រកូលសាក្យៈនេះឯង។

ឯបុព្វជនខ្មែរ បើតាមការសន្និដ្ឋាន របស់អ្នកនិពន្ធ ខ្ញុំថាមិនមែនមនុស្សល្ងង់ខ្លៅទេ ពិតជាអារ្យជន អ្នកចេះដឹងជឿនលឿនមួយក្រុម បាននាំគ្នាមកកាន់ទីទំនាប ដែលមានជីវជាតិល្អហើយ ទំនេរគ្មានមនុស្សនៅ ដើម្បីធ្វើការបដិវត្តន៍សាងឲ្យកើតជាជាតិ ជាប្រទេសមួយឡើងក្នុងលោក ដូចពួកសាក្យៈនេះដែរ គ្រាន់តែមានបុព្វហេតុផ្សេងគ្នាប៉ុណ្ណោះ។

អត្ថបទដែលនិយាយពី ប្រភពមន-ខ្មែរ ក្នុងសម័យបុរេប្រវត្តិខាងលើនេះ យើងអាចដឹង ស្គាល់ អារ្យធម៌ខ្មែរទាំង ៤ ប្រភេទ ក្នុងសម័យច្រើនពាន់ឆ្នាំមុន គ.ស. នោះបានខ្លះហើយគឺ ៖

- **អារ្យធម៌ប្រភេទទី ១ - អាចារៈ** ចរិយាគំនិតមារយាទល្អ ប្រកបដោយសីលធម៌ និងមនុស្សធម៌ អារ្យធម៌ប្រភេទនេះ ពិតជាមានបរិបូណ៌ក្នុងចិត្តគំនិតបុព្វជនខ្មែរនាសម័យ


www.elibraryofcambodia.org

នោះ ទើបអាចរួបរួមគ្នាកសាងជាសង្គមជាតិ ជាកុសលសម្ពន្ធមួយ បានចម្រើនរុងរឿងតៗមក។

ការដែលបុព្វជនខ្មែរ អាចបណ្តុះបណ្តាល ពូជជាតិខ្មែរ ប្រទេសខ្មែរ ឲ្យកើតមានក្នុងផ្ទៃលោកនឹងគេនេះឯង ជាភស្តុតាង ឲ្យយើងដឹងនូវចរិយាមារយាទល្អរបស់បុព្វជនខ្មែរក្នុងបឋមសម័យបាន ព្រោះថា អារ្យធម៌ប្រភេទទី ១ នេះមាននាទីបង្កើតនូវសេចក្តីសុខ សេចក្តីសុខនេះឯង ជាហេតុនាំឲ្យមានសេចក្តីចម្រើនល្វតលាស់។ បើក្នុងសង្គមបុព្វជនខ្មែរសម័យនោះ គ្មានសេចក្តីសុខទេ ពូជ ជាតិខ្មែរ ប្រទេសខ្មែរវិនាសបាត់បង់ចាកពិភពលោកទៅហើយ។

- **អារ្យធម៌ប្រភេទទី២ - ទស្សនីយភាព:** ទិដ្ឋភាពនៃរូបឆោម ឥរិយាបថ និងទីឋានសមរម្យ មានរបៀបត្រឹមត្រូវមានអនាម័យ។ អារ្យធម៌ប្រភេទនេះ ពិតជាមានក្នុងសង្គមបុព្វជនខ្មែរដែរ ព្រោះប្រវត្តិសាស្ត្របានប្រាប់ថា ខ្មែរសម័យនោះ មានសក់រួញ មានឧមាំស្វាហាប់ អាចឲ្យយើងដឹងបានថា មានរូបឆោមសង្ហាណាស់ ល្អទាំងសក់ ល្អទាំងមាឌដែលបរិបូណ៌ដោយសុខភាព ពិតជាមានអនាម័យគ្រប់គ្រាន់ ឯឥរិយាបថ និងទីឋានវិញក៏ប្រវត្តិសាស្ត្រប្រាប់ថា បុព្វជនខ្មែរសម័យនោះ មានផ្ទះនៅលើគោក និងនៅដោយទូកលើទឹក មិនមែនជាមនុស្សផ្តេសផ្តាស អាក់សែ ដើរដេកនៅដោយរូងភ្នំ ឬគល់ឈើឡើយ ពិតជាមានទីឋាន និងឥរិយាបថ ដេកនៅសមរម្យ តាមរបៀបមនុស្ស។

- **អារ្យធម៌ប្រភេទទី ៣ - លិង្គ:** ភេទសមរម្យតាមបែបបទបុរសស្ត្រី។ អារ្យធម៌ប្រភេទនេះក៏មានក្នុងសង្គមបុព្វជនខ្មែរសម័យនោះដែរ។ យើងអាចដឹងបានតាមបុរាណវត្ថុ ដែលកើតមានក្នុងកាលនោះ ដូចគ្រឿងអលង្ការសម្រាប់តែងកាយបុរសស្ត្រី និងដឹងបានតាមសិលាចារឹក ដែលកើតមានក្នុងកាលបន្ទាប់ៗមក។ បុរាណវត្ថុ និងសិលាចារឹកនេះឯង បង្ហាញឲ្យយើងដឹងថា បុព្វជនខ្មែរសម័យនោះ បានរៀបចំភេទប្រុសស្រី បានសមរម្យតាមកាលៈទេសៈដែរ។

- **អារ្យធម៌ប្រភេទទី ៤ - សមត្ថភាព:** ភាពអង់អាចដោយចំណេះវិជ្ជា ការចេះដឹងវៃឆ្លាតបានដល់សមត្ថភាពខាងវិជ្ជាអក្សរសាស្ត្រ និងបច្ចេកទេស។ សមត្ថភាពនេះឯង ដែលអាចរៀបចំលក្ខណៈវប្បធម៌ [3]និងលក្ខណៈសង្គមធម៌តម្រូវតាមកាលៈទេសៈ ឲ្យជាតិបានចម្រើនល្វតលាស់ ព្រោះអារ្យធម៌ទី ៤ នេះ មាននាទីខាងការបង្កើតសេចក្តីចម្រើនរុងរឿង។

---

[3] លក្ខណៈវប្បធម៌ ផ្សេងពីប្រភេទនៃវប្បធម៌


www.elibraryofcambodia.org

ឯលក្ខណៈវប្បធម៌ និងលក្ខណៈសង្គមធម៌ ដែលបុព្វជនខ្មែរសម័យនោះ បានរៀបចំឲ្យកើតមានឡើង តាមសមត្ថភាព ការចេះដឹងវៃឆ្លាតរបស់ខ្លួននោះគឺ ៖

## លក្ខណៈវប្បធម៌

### លក្ខណៈវប្បធម៌នេះ ចែកជាបីផ្នែកគឺ ៖

១- ការចេះដឹង (Connaissans)

២- ការផ្សាយ (Publication)

៣- ការអនុវត្តន៍ (Application)

១) **ការចេះដឹង** បានដល់ការចេះដឹងទូទៅ ដែលកើតពីការសិក្សា ការត្រិះរិះពិចារណាយល់ឃើញ តាមស្ថានការណ៍ និងតាមកាលៈទេសៈ មានលក្ខណៈដូចតទៅនេះ ៖

**ក- ទស្សនវិជ្ជា** (Philosophie) ការត្រិះរិះពិចារណា តាមការឃើញ ការដឹងដោយប្រើវិចារណញ្ញាណ ពិនិត្យសង្កេតរកហេតុផលតូចធំ នៃសេចក្ដីវិនាស ចម្រើនព្រោះក្នុងវប្បធម៌មួយៗ សុទ្ធតែមានទស្សនវិជ្ជាជាបឋមសម្រាប់ឆ្លុះបំភ្លឺ រាវរកផ្លូវទៅកាន់សេចក្ដីចម្រើនរុងរឿង។

អាស្រ័យហេតុនេះ ទើបបុព្វជនយើង បណ្ដុះនូវលទ្ធិគឺសេចក្ដីយល់ឃើញ និងជំនឿឲ្យកើតមានឡើង តាមទស្សនៈរបស់ខ្លួនក្នុងសម័យនោះ។

ខ- លទ្ធិ (Religion) សេចក្ដីយល់ឃើញ តាមតម្រិះ ឬតាមទម្លាប់ ហើយប្រកាន់យកថាត្រូវល្អ។ បុព្វជនខ្មែរសម័យនោះ មានទស្សនៈយល់ឃើញថា នៅក្នុងព្រៃ ទន្លេ សមុទ្ទ ទីវាល ជ្រោះជ្រលង ដងអូរ ទីស្រែចម្ការ និងភូមិស្រុក ផ្ទះ វិមាន ប្រាសាទ ជាដើម តែងមានវត្ថុសក្ដិសិទ្ធិអាស្រ័យនៅ ដូចជា ទេព្តា អារក្ស អ្នកតា បង់បត់ ព្រះភូមិ ម្រេញគង្វាល ខ្មោច ជូរ ជំបូរ ជាដើម ហើយប្រកាន់យក ជាសរណៈ ជាទីពឹងទីរលឹក តាមសេចក្ដីយល់ឃើញនោះ។

លទ្ធិនេះ បានជាមធ្យោបាយមួយ ខាងការរៀបចំចិត្តគំនិតមនុស្សក្នុងសម័យនោះ ឲ្យមានមនោគមស្របគ្នា ចេះយោគយល់រាប់រក យកគ្នាជាមិត្រជិតស្និទ្ធិគ្នា នាំឲ្យកើតជំនឿរួមគ្នាឡើង។

**គ- ជំនឿ** (Croyances) ការចុះចិត្តស៊ប់ចំពោះអ្វីៗ ដែលបានប្រកាន់យកជាសរណៈ ហើយ ធ្វើសក្ការៈគោរពបូជាបួងសួង បន់ស្រន់ ថ្វាយសំណែន រៀបលៀងប្រគំតូរ្យតន្ត្រី តាមពេលវេលាដែលបានកំណត់ ឬតាមហេតុភេទដែលកើតមានឡើង ដើម្បីសេចក្ដីសុខចម្រើន។


www.elibraryofcambodia.org

ជំនឿរបស់បុព្វជនខ្មែរសម័យនោះ មិនមានការជឿចំពោះព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ និងព្រះព្រហ្ម ព្រះឥសូរ ដូចសម័យបន្ទាប់មក និងសព្វថ្ងៃនេះឡើយ ប្រកាន់ជឿតែអ្នកមានគុណ មាតាបិតា គ្រូអាចារ្យ មេបា ដូនតា និងទេព្តា អារក្ស អ្នកតា ជាដើម។

ការប្រកាន់ជំនឿបែបនេះ អាចប្រមូលចិត្ត គំនិតមនុស្សឲ្យចេះខ្លាចខុស ស្រឡាញ់ត្រូវ ចេះគោរពប្រតិបត្តិធ្វើសក្ការៈបូជា ចំពោះមាតាបិតា មេបា គ្រូអាចារ្យ វត្ថុសក្តិសិទ្ធិនិងចេះអនុវត្តតាមជំនូន្មាន តាមតម្រា តាមបទបញ្ញត្តិរួមគ្នាដើម្បីបានសុខចម្រើន។ កាលបើមានហេតុ ដែលនាំឲ្យកើតអន្តរាយ ទុក្ខព្រួយណាមួយកើតឡើង ក៏នាំគ្នាបង្កើតបម្រាម ត្រណម បទបញ្ញត្តិ និងអនុញ្ញាត ជំនូន្មាន ឲ្យកើតមានថែមទៀត ដរាបដល់បានសេចក្តីសុខស្រួលស្របតាមជំនឿរបស់ខ្លួន។

បទបញ្ញត្តិ អនុញ្ញាត ជំនូន្មាន ត្រណម បម្រាមនេះឯងឈ្មោះថា មនុស្សធម៌ សីលធម៌ និងសុជីវធម៌។

**ឃ- មនុស្សធម៌** (Humanité) ត្រណម គឺបទបញ្ញត្តិដែលមនុស្សជាតិត្រូវតែមមិនត្រូវធ្វើ។ មនុស្សធម៌របស់របស់បុព្វជនខ្មែរសម័យនោះ បើពិនិត្យ សង្កេត ចិត្តគំនិតមនុស្សតាមជំនាន់បុព្វជន បន្តបន្ទាប់មកឃើញថា វិសេសវិសាលជាងមនុស្សធម៌សម័យបច្ចុប្បន្ននេះឆ្ងាយណាស់ ដូចជាការកាប់សម្លាប់មនុស្ស ការលួចប្លន់ កេងកិប ស្វកស៊ីសំណូក ការផឹតក្បត់ក្នុងផ្លូវកាមតណ្ហា ការនិយាយកុហក បោកប្រាស់ គ្មានពាក្យសច្ចៈ និងការផឹក ជក់ គ្រឿងពុល ញៀន គ្រឿងស្រវឹងឡូឡា។ ទង្វើទាំងអស់នេះ បុព្វជនខ្មែរមិនហ៊ានប្រព្រឹត្តធ្វើងាយៗ ឥតតក់ស្លុត កោតញញើត ដូចមនុស្សសព្វថ្ងៃនេះឡើយ ចំពោះការនិយាយពាក្យមមិនពិត និងការផឹតក្បត់ស្នេហា ក្នុងផ្លូវកាមតណ្ហានោះរឹតតែកាន់ត្រណមបានយ៉ាងវិសេសណាស់ យើងសង្កេតមើលត្រឹមតែជំនាន់ដូនតាទួតយើងក៏ឃើញថា លោកមានមនុស្សធម៌វិសេសជាងយើងទៅហើយ។

**ង. សីលធម៌** *(Moralité)* ហេតុដែលនាំឲ្យអាចគោរពប្រតិបត្តិតាមជំនូន្មាន តាមបទបញ្ញត្តិ តាមត្រណម បម្រាម បានដល់ចិត្តគំនិត ដែលប្រកបដោយ មេត្តា ករុណា ចង់ឲ្យអ្នកដទៃបានសុខចម្រើន ប្រាសចាកព្យាបាទនិងវិហឹង្សា។

សីលធម៌របស់បុព្វជនខ្មែរសម័យនោះ បើពិនិត្យសង្កេតតាមហេតុផល ឃើញថាត្រឹមត្រូវវិសេសជាងសីលធម៌សម័យបច្ចុប្បន្ននេះ ព្រោះបុព្វជនខ្មែរ ជាមនុស្សដាច់ស្រេចទៀងត្រង់ ជាញជ័យ ហ៊ានថាហ៊ានធ្វើ ចិត្តគំនិតបែបណាធ្វើបែបនោះ មិនចេះតែថាឲ្យពិរោះត្រចៀកអ្នកដទៃបំភាន់ឲ្យគេជឿ ហើយធ្វើផ្ទុយពីមាត់ ពីច្បាប់នោះឡើយ។


www.elibraryofcambodia.org

មជ្ឈដ្ឋានខ្លះយល់ថា បុព្វជនខ្មែរ ជាមនុស្សព្រៃ មិនទាន់ចេះយកស្មារតីត្រិះរិះពិចារណាក្នុងផ្លូវសីលធម៌ឲ្យបានជ្រៅជ្រះឡើយ សីលធម៌បុព្វជនខ្មែរ គ្រាន់តែហាមកូនចៅកុំឲ្យដេកខិតលើស្មើក្បាលនឹងមនុស្សចាស់ ខ្លាចដូនកាយចាក់ទឹកបាយលើ ជាដើមប៉ុណ្ណោះ។ បើបុព្វជនខ្មែរអន់គម្រក់បែបនេះ ក្នុងសម័យបន្តបន្ទាប់មក គឺតាំងពីគ្រិស្តសតវត្សរ៍ទី ១ រហូតមកដល់សម័យមហានគរ ខ្មែរមិនអាចដើរជឿនលឿន កសាងប្រទេសជាតិឲ្យកើតជាមហាអំណាចផ្ដាច់គេ ក្នុងឧបទ្វីបអាស៊ីភាគអាគ្នេយ៍នេះបានឡើយ។ ជាពិសេសនៅគ្រិស្ត...

(បាត់ ២ ទំព័រ)

CAMBODIAN EDUCATION EXCELLENCE
មូលនិធិខ្មែរសម្រាប់ការសិក្សា
FOUNDATION


www.elibraryofcambodia.org

...រោគគ្រប់ជំពូក រាវរកវិធីឆ្អឹង ផ្សះមុខរបួសខាងក្នុង ឱសថបំបាត់ជាតិពិសគ្រប់យ៉ាង ការផ្សំបង្កើតជាតិពិសយ៉ាងសាហាវសម្រាប់ធ្វើជំរេក់ ថ្នាំបំពុល ការព្យាបាលរោគ ដោយមនោមយិទ្ធិវិជ្ជា (Volonté) ការធ្វើផ្ទះ ធ្វើនាវាធំៗ សំរាប់ឆ្លងទន្លេ សមុទ្ទ ការស្គាល់ឧតុនិយមសម្រាប់ធ្វើដំណើរតាមមហាសាគរ និងការធ្វើគ្រឿងប្រើប្រាស់ ពីដី ពីដែក ស្ពាន់ លង្ហិន សំរិទ្ធិ អម្បោះ សូត្រ ខ្សង ខ្មៅជាដើម ដូចមានបុរាណវត្ថុ នៅសំរោងសែន អន្លង់ផ្តៅ និងម្លូព្រៃ ជាភស្តុតាងស្រាប់។

វត្ថុទាំងអស់នេះ សុទ្ធតែកើតឡើង ដោយសិល្បកម្ម និងឧស្សាហកម្ម ដែលជា វិទ្យាសាស្រ្ត-បច្ចេកទេសខ្មែរក្នុងសម័យនោះ។

**២. ការផ្សាយ** កាលបើមានការចេះដឹងដូចខាងលើនេះហើយ តែងតែផ្សព្វផ្សាយ នូវចំណេះនោះៗ ឲ្យបានជ្រួតជ្រាបដល់មហាជន តាមលក្ខណៈដូចខាងក្រោមនេះ ៖

**ក- ភាសា** (Langage) បុព្វជនខ្មែរ មានភាសាសម្រាប់និយាយប្រាស្រ័យគ្នា និយាយផ្សាយផ្ទេរចែកចាយនូវចំណេះវិជ្ជាជាដើម ចំពោះគ្នានិងគ្នា បានគ្រប់គ្រាន់ក្នុង សម័យនោះ មិនខ្វះពាក្យប្រើឡើយ ព្រោះបានបង្កើតវិទ្យាសាស្រ្តបច្ចេកទេស និងលទ្ធិជំនឿ ជាដើម ដោយខ្លួនឯង មិនបាច់បង្កើតពាក្យដែលខ្វះ ដោយយានកម្មឡើយ។

ចំណែកសូរស័ព្ទ ភាសា របស់បុព្វជនខ្មែរ ដែលជាភាសាដើមសុទ្ធសាធក្នុងសម័យ នោះ យើងមិនអាចដឹងឲ្យសព្វគ្រប់បានឡើយ គ្រាន់តែដឹងថា ភាសានោះកើតមកពីប្រភព មន-ខ្មែរ ក្នុងអម្បូរ អូស្ត្រូ-អាស្យាទីក (Austro-asiatiques) អូស្ត្រូនេស៊ីយែន (Austro-nésiennes) ជាភាសាឧប្បត្តិកកើតឯង នៅលើដែនដីនានា ជាជ្រោយ ជាកោះតាមសមុទ្ទ ប៉ាស៊ីហ្វិក មិនមែនជាភាសាខាងអម្បូរ ឥណ្ឌូ-អឺរ៉ុប (Indo-Européennes) ដែលឧប្បត្តិកកើត នៅ ឥណ្ឌា នៅអឺរ៉ុបនោះឡើយ។

ដើម្បីស្គាល់ សូរស័ព្ទ សម្តី ភាសា របស់បុព្វជនខ្មែរក្នុងសម័យបុរេប្រវត្តិឲ្យច្បាស់ថា លោកនិយាយដូចយើងសព្វថ្ងៃឬមិនដូចនោះ ជាការពិបាកណាស់ ព្រោះមុនប្រវត្តិសាស្រ្ត ខ្មែរ។

ប៉ុន្តែមានមធ្យោបាយមួយ ដែលយើងអាចយកមកធ្វើវិភាគ វែកញែក ថ្លឹងរកឃើញ បានខ្លះដែរ គឺត្រូវយកសម្តីភាសារបស់បុព្វជនខ្មែរយើង ក្នុងសម័យបុរេអង្គរ ពី គ.វ. ទី១ ដល់ទី ៨ ដែលជាសម័យតបន្ទាប់ពីសម័យបុរេប្រវត្តិនោះ ១ យកសម្តីភាសារបស់បុព្វជនខ្មែរ ក្នុងសម័យអង្គរ ពី គ.វ. ទី ៩ ដល់ទី ១៨ នោះ ១ និងយកសម្តីភាសារបស់យើងសព្វថ្ងៃពី គ.វ.


www.elibraryofcambodia.org

ទី ១៩ ដល់ទី ២០ នេះ ទៅប្រៀបផ្ទឹមជាមួយសម្ដីភាសាក្នុងសម័យទាំង ២ ខាងលើ តើឃើញពាក្យសម្ដីណានៅដូចគ្នា ណាខុសគ្នា: ខុសឆ្ងាយឬជិត។

បើពាក្យសម្ដីណា នៅដូចគ្នារហូតគ្រប់សម័យទាំងបីនោះ ពិតជាពាក្យសម្ដីរបស់បុព្វជនខ្មែរ ក្នុងសម័យបុរេប្រវត្តិនោះហើយ ព្រោះថា បើ ២០ សតវត្សរ៍ ពី គ.វ. ទី១ ចុះមកបច្ចុប្បន្ននៅតែដដែល ២០ សតវត្សរ៍ ពីគ.វ. ទី១ ឡើងទៅអតីតវិញ ក៏នៅដដែលដែរ នេះជាការវិនិច្ឆ័យទី១។

មួយទៀត បើពាក្យសម្ដី ក្នុងសម័យបុរេអង្គរនោះខុសឆ្ងាយពីពាក្យសម្ដីយើងសព្វថ្ងៃនេះ ក៏គួរសម្គាល់ថា ជាពាក្យសម្ដីរបស់បុព្វជនខ្មែរ ក្នុងសម័យបុរេប្រវត្តិដែរ ព្រោះជាសម័យនៅជិតជាប់គ្នា។

សូមអ្នកអាន ជួយធ្វើវិភាគវែកញែក នូវពាក្យសម្ដីក្នុងសម័យទាំងបី ហើយវិនិច្ឆ័យរកសម្ដីភាសារបស់បុព្វជនខ្មែរក្នុងសម័យបុរេប្រវត្តិនោះ ដោយផ្ទាល់ខ្លួនផងចុះ ខ្ញុំនឹងដកស្រង់យកពាក្យសម្ដីក្នុងសម័យទាំងបី តាមដែលបានរកឃើញមកជូនដូចខាងក្រោមនេះ[4]

## ភាសាខ្មែរក្នុងសម័យទាំងបី

CAMBODIA EDUCATION EXCELLENCE
មូលនិធិខ្មែរសម្រាប់ការសិក្សា
FOUNDATION

[4] ដកស្រង់ពីឯកសារផ្សេងៗ របស់ព្រះភិក្ខុ ប៉ាង ខាត់ អ្នកប្រាជ្ញខាងសិលាចារឹកខ្មែរ ដែលព្រះអង្គភាវរកយកទៅបង្រៀនក្នុងមហាវិទ្យាល័យអក្សរសាស្ត្រជាដើម។ ឯកសារទាំងអស់នោះ ខ្ញុំបានឃើញផ្ទាល់ខ្លួនខ្លះ ជាអំណោយរបស់ព្រះមហាបរិញ្ញា មៅ សាម៉ន ខ្លះ។


www.elibraryofcambodia.org

| សម័យបុរេអង្គរ | សម័យអង្គរ | សម័យបច្ចុប្បន្ន |
|---|---|---|
| កិនមោយ | កនម្យ | ក្មួយ |
| កន្តោន កំតោន | កន្ទួ កំតួន | ជីដូន |
| កន្តាល | កន្តាល | កណ្តាល |
| កន្លោង | កន្លោង | កន្លោង (មេខ្លោង) |
| កម្រតាង | កម្រតេង | តម្តែង គម្តែង |
| កុរុង | កុប្រុង | ក្រុង |
| កោន | ក្វន | កូន |
| ក្ម | ក្មុំ | ខ្ញុំ |
| ក្មេរ | ខ្មេរ | ខ្មែរ |
| ក្របិ | ក្របិ | ក្របី |
| ?[5] | ក្រវេ | ក្រពើ |
| គេ | គេ | គេ |
| ច្យ (អានថាចី) | ឆី | ស៊ី |
| ចំរេង | ចំរ្យង | ចម្រៀង |
| ច្កេ | ? | ឆ្កែ |
| ច្មា | ? | ឆ្មា |
| ច្ទិង | ឆ្ទឹង | ស្ទឹង |
| ច្បោង | ? | ច្បង |
| ចន្លេក | ចន្លៀក | សម្លៀក |

CAMBODIAN EDUCATION EXCELLENCE
មូលនិធិខ្មែរសម្រាប់ការសិក្សា
FOUNDATION

[5] សញ្ញា? នេះគឺសុង-ស៊ីវ
ខ្ញុំរកមិនទាន់ឃើញ
ដល់បោះទី២
បើឃើញដាក់ជូន។


www.elibraryofcambodia.org

| | | |
|---|---|---|
| ជោន | ជូន | ជូន |
| ផ្ទះ | ផ្មោះ | ឈ្មោះ |
| ឈេ | ឈេ | ឈើ |
| តេម | តេម | ដើម |
| តេមត្រសេក | តេមត្រសេក | ដើមត្រសេក |
| តេមស្ដៅ | តេមស្ដៅ | ដើមស្ដៅ |
| តេមស្លា | តេមស្លា | ដើមស្លា |
| តេមតោង | តេមត្វូង | ដើមដូង |
| ? | តេមស្វឹ | ដើមស្ដឹ |
| ? | តេមតន្នោត | ដើមត្នោត |
| តេល | តេល | ដែល |
| ? | ត្នូង | ផ្ដល់ |
| តំវេ | ថ្វេ | ធ្វើ ទង្វើ |
| ត្វៃលុច | ? | ថ្ងៃលិច |
| ត្មេងវិណា | ? | អ្នកដេញពិន |
| ត្មុរ | ថ្មុរ | សត្វគោ |
| ? | តម្រៀ | ដំរី |
| ? | ត្រតួន | ត្រកួន |
| ត្រវង | ត្រវាង | ត្រពាំង |
| តុំ (អានថាឫដុំ) | ? | រដូវ |
| ទៅ | ទៅ | ទៅ |
| ទំរឹង | ? | ដំណាំ ច្បារដំណាំ |
| និតិ | ? | នេះគឺ |
| នេះ | នេះ | នេះ |
| នោះ | នោះ | នោះ |
| នៅ | នៅ | នៅ |
| បុណ្យ | បុណ្យ | បុណ្យ |
| បោន | ប្អូន | ប្អូន |


www.elibraryofcambodia.org

| | | |
|---|---|---|
| បំចំ | ? | បញ្ចាំ |
| ប្រក | ប្រាក | ប្រាក់ |
| ប្រកសោលិង | ? | ប្រាក់១ ស្លឹង |
| ប្រេ | ប្រេ | ប្រើ |
| ផោង | ផោង | ផង |
| មន មាន | មាន | មាន |
| ? | មនុម្ស | មនុស្ស |
| មាស | មាស | មាស |
| មោយ | ម្យ | មួយ |
| រង្កោ | តន្ទុល | អង្ករ |
| រមំ | រមំ | អ្នករាំ |
| រំ | រំ | រាំ |
| លង្គាយ | លង្កៅ | ស្ពាន់ |
| លោះ | ល្វះ | លុះ |
| វវេ | វវេ | ពពែ |
| ? | វសេ | ពស់ |
| វ្នំ | វ្នំ ព្នំ | ភ្នំ |
| ប្រនេង | ? | ព្រងនាយ |
| ប្រច | ប្រច | ព្រេច (ដំរីព្រេច) |
| ប្រែយ | ប្រែ | ព្រៃ |
| ប្រៈ | ប្រៈ | ព្រះ |
| វ្លះ បន្លស្ស | ? | ផ្លាស់ បន្លាស់ |
| សឧយ | សអុយ | ស្អុយ |
| ? | សោម | សុំ សូម |
| ស្តេ | សង្កេ | ដើមសង្កែ |
| ? | ស្រុ | ស្រូវ |
| ស្រុក | ស្រុក | ស្រុក |
| អញ | អញ | អញ |

CAMBODIAN EDUCATION EXCELLENCE FOUNDATION
មូលនិធិខ្មែរសម្រាប់ការសិក្សា


www.elibraryofcambodia.org

| | | |
|---|---|---|
| អំបិល | ? | អំបិល |
| អ្នក | អ្នក | អ្នក |
| ឧក្ក | ? | ចិត្ត |
| ឧយ | ឱយ | ឲ្យ ។ល។ |

សំណោរខាងលើនេះ បុព្វបុរស លោកអានខុសពីយើងសម័យនេះ ដែលយើងអានតាមតែសំណោរត្រង់ៗនោះ គឺលោកមានពិធីអានពិសេសដូចខាងក្រោមនេះ ៖

១- អក្សរ «ត» លោកប្រើជា «ត» ផង ជា «ដ» ផង តាមដំណើរសេចក្ដី គឺលោកបង្កើតតែ «ត» មួយ ប្រើបានពីរពាក្យ។

២- អក្សរ «រ» លោកប្រើជា «រ» ផង ជា «ព ប៉» ផង ជើង រ «្ញ» ប្រើជាជើង «រ» ផង ជាជើង «ព» ផង ជាស្រះ «ួ ួ» ផង តាមដំណើរសេចក្ដី ដើម្បីឲ្យមានចំនួនតួរអក្សរតិច ហើយ សរសេរ អានឲ្យបានច្រើនពាក្យ។

៣- ស្រះ «េ» លោកប្រើជាស្រះ «េ» ផង ជា «ែ» ផង ជា «ើ» ផង ជា «ៀ» ផង តាមដំណើរសេចក្ដី។

៤- ជើង «្យ» ប្រើជាតួ «យ» ផង ជាស្រះ «ិ ី» ផង ស្រះ «ិ» ប្រើជា «ឹ ឺ» ផង តាមដំណើរសេចក្ដី។

៥- សញ្ញារបាទ «៑» នេះ លោកប្រើជា «ឫ» ជាសំឡេង «រ» ក៏មានតាមដំណើរសេចក្ដី។

វិធីបែបនេះ នៅមានច្រើនទៀត ខ្ញុំនិយាយតែប៉ុណ្ណោះដើម្បីតម្រូវតាមសំណោរ ដែលខ្ញុំបានយកមកសរសេរខាងលើ ដូចសំណោរ ៖

«កន្តោន កំតោន កន្ទួន កំតួន កួន ក្របិ ក្រវេ ច្យ ចំរ្យង ច្ពេ ឈេ តេម ថ្វេ ត្ររង គិនិ ប្វន ប្រេ ម្យ្ស ល្វះ តុំ វេវ ព្វេ» ។ល។ សំណោរបែបនេះ បុព្វបុរសខ្មែរ លោកអានថា ៖

«កន់ដោន កំដោន កន់ដូន កំដូន កូន ក្របី ក្រពើ ចី ចំរឹង>ចម្រៀង ច្ពៃ ឈើ ដើម ថ្វើ=ថ-វើ>ធ្វើ ត្រពង>ត្រព័ង>ត្រពាំង នេះគឺ បួន ប្រើ មួយ លូះ>លុះ ឫជុ ពពៃ ព្រៃ» ។ល។ ឃើញថាមិនខុសប៉ុន្មាន ពីពាក្យសម្ដីយើងសព្វថ្ងៃនេះឡើយ។



www.elibraryofcambodia.org

លុះសម័យក្រោយមក ទើបបុព្វបុរសបង្កើតអក្សរ «ដ ព ស្រះ ◌ឹ ◌ឺ ◌ុ ◌ូ ◌ើ ◌ៀ» តម្រូវឲ្យត្រូវតាមលំអានកុំឲ្យពិបាករៀនអានទៀត គឺឃើញសំណេរយ៉ាងណា ថាយ៉ាងនោះតែម្តង។

ប្រសិនបើបុព្វជនខ្មែរជំនាន់មុន លោកអានតាមតែសំណេររបស់លោកថា «តេម ឈេ ក្វន ក្រវេ វវេ វស» ។ល។ ដូច្នេះនោះ បុព្វបុរសជំនាន់ក្រោយ ក៏មិនអាចបង្កើតអក្សរបង្កើតស្រះថែមបានដែរ ព្រោះអក្សរកើតឡើងក្រោយសូរស័ព្ទភាសា គឺមានភាសាមកយូរហើយ ទើបបង្កើតអក្សរតាមភាសា។ នេះជាមតិផ្ទាល់របស់ខ្ញុំ។

ឧទាហរណ៍ ដូចស្រះ «ែ» ដែលខ្ញុំថាបុព្វជនអានថា «អែ» នោះ នៅជាប់មាត់តតមករហូតដល់សតវត្សរ៍ទី ២០ ក្នុងសម័យវចនានុក្រមនេះ ដែលមានស្រះ «ៃ» យុរយារហើយនោះ កាលបើគេឃើញសំណេរ «ែ» នេះ គេនៅតែអានថា «ៃ» ដដែល ដូច «ឯវមេ ថាអែវៈម៉ែ ខែចេត្រថាខែចែត ខេត្ត ថា ខែត ពេទ្យ ថា ពែត ហេតុ ថា ហែត ព្រះកេតុ ថា ព្រះកែត ចេត្តិយ ថា ចែតដី តេជះ ថា ដែចជះ» ។ល។

លំអានពិសេស ខុសពីសំណេរបែបនេះ ក្នុងវចនានុក្រមយើងសព្វថ្ងៃ ក៏មានដែរ ដូច «សុនខ អានថា សុណាក់ វិតក្ក ថា វិតក់-វិតុក ហេតុថា ហែត ខេត្រ ថា ខែត ទស ថា ទស់ ទារក ថា ទារក់ យស ថា យស់ ធន ថា ធន់ សេកមន្ត ថា សែកមន្ត សេព ថា សែប តេជដៃ ថា ដែចដៃ តេជះ ថា ដែចជះ ។ល។

ឧទាហរណ៍ទាំងអស់នេះ បញ្ជាក់ឲ្យឃើញថា បុព្វជនជំនាន់បុរេអង្គរក្តី ជំនាន់អង្គរក្តី យើងសព្វថ្ងៃនេះក្តី សុទ្ធតែមានវិធីអានខុសពីសំណេរដូចគ្នា នេះឯងជាភស្តុតាងច្បាស់ឲ្យយើងឃើញដឹងថា ដែលបុព្វជនយើងសរសេរក្នុងសិលាចារឹកថា «តេម ឈេ ក្របិ ក្វន វវេ វស វ្រៃ» ជាដើមនេះ គឺលោកអានថា «ដើម ឈើ ក្របី កូន ពពែ ពស់ ព្រៃ» ជាដើមដូចយើងសព្វថ្ងៃនេះដែរ។

ពាក្យសម្តីទាំងអស់ខាងលើនេះ ឃើញពាក្យខ្លះនៅដូចដើម ពាក្យខ្លះបានប្រែប្រួលទៅតាមកាលសម័យហើយអាចឲ្យយើងដឹងបានថា បុព្វបុរសយើងក្នុងសម័យបុរេប្រវត្តិពិតជាមានពាក្យសម្តីគ្រប់គ្រាន់ មានសូរស័ព្ទប្រហាក់ប្រហែលគ្នានឹងពាក្យសម្តីយើងសព្វថ្ងៃនេះដែរ។ រីតតែច្បាស់ជាងនេះទៅទៀត យើងយកពាក្យក្នុងអំបូរមន ដែលមានកំណើតជាមួយគ្នា មកប្រៀបផ្ទឹមមើល ឃើញដូចគ្នាច្រើនណាស់ ពាក្យដូចគ្នានោះឯង ជាសម្តីបុព្វបុរសក្នុងសម័យបុរេប្រវត្តិ។


www.elibraryofcambodia.org

| ពាក្យខ្មែរ | ពាក្យក្នុងអំបូរមន |
|---|---|
| ឈើ | ឈុះ |
| ថ្ម | តមើ ម៉ |
| កំដៅ | កតៅ |
| កោន ជូន | កោន |
| ខ្លា | ក្លក់ |
| ដី | ដេយ |
| ព្រៃ | ប្រី ប្រេ |
| ជើង | ចើង ចិង |
| គិត | កេត គឹត |
| មនុស្ស មនឹស | មនិស |
| មុះ ច្រមុះ | មុ៊ះ មមត មោះ |
| រមាស | រមើស រមឹស រម៉ាយ ។ល។ |

ដោយបុព្វជនខ្មែរ មានភាសាគ្រប់គ្រាន់យ៉ាងនេះហើយ ទើបមាននាមថា ជាអក្សរសាស្ត្របាន។

**ខ- អក្សរសាស្ត្រ** (Littérature) ដែលហៅថាអក្សរសាស្ត្រនេះ សំដៅយកភាសា (Langage) និងវណ្ណៈ ស្នាមគំនូសអក្សរ (Ecriture) រួមទាំងពីរមុខនេះចូលគ្នាហៅថា អក្សរសាស្ត្រ មានន័យប្លែកពីពាក្យថា អក្សរ ថាភាសា គឺមានន័យចំពោះភាសាផង អក្សរផង។

បុព្វជនខ្មែរសម័យបុរេប្រវត្តិ ជាអ្នកអក្សរសាស្ត្រមួយដែរ ព្រោះបានចេះចាំនូវចំណេះវិជ្ជា គោលមតិទូទៅហើយផ្សាយតាមការនិទាន តាមការសម្តែងកាយវិការ និងតាមការបង្ហាត់បង្ហាញផ្ទាល់មាត់ ឲ្យមានការចេះដឹងតៗគ្នាមក។

ឯការប្រើតួអក្សរ (Ecriture) ដើម្បីសរសេរកត់ត្រាជាក្បួនខ្នាត ចែកគ្នាអាននោះ ពួកប្រវត្តិវិទូបច្ចុប្បន្នថា បុព្វជនខ្មែរសម័យនោះ មិនទាន់មានអក្សរប្រើឡើយ ព្រោះគេរកមិនឃើញភស្តុតាង ដូចសិលាចារឹកជាដើម។

ប៉ុន្តែបើយើងរាវរកឲ្យល្អិតល្អន់ទៅទៀត ប្រហែលជាខ្មែរយើងមានអក្សរប្រើ តាំងពីដើមបំផុតនោះមកដែរហើយ ពិតមែនតែគ្មានសិលាចារឹក គ្មានបុរាណវត្ថុ ដែលមានតួអក្សរជាភស្តុតាងក៏ដោយ ព្រោះក្នុងពង្សាវតារខ្មែរបានប្រាប់ថា បុព្វជនខ្មែរមានសាក់ពេញខ្លួន


www.elibraryofcambodia.org

សាក់នេះឯគឺការប្រើវណ្ណៈស្នាមគំនូស សម្រាប់សម្គាល់អ្វីៗតាមមនោគតិ ដែលយើងហៅថា អក្សរ (Ecriture) ទោះបីសាក់ក្នុងសម័យនោះ យើងសន្មតថា គ្មានប្រើតួអក្សរ ន-មោ-ក-ខ គ្មានប្រើលេខ ១-២-៣ ក៏ជៀសមិនផុតពីការប្រើចំណុចមូល បីជ្រុង បួនជ្រុង កាកបាទ និងគំនូសស្លឹកឈើ រូបសត្វ ក្បាច់ភ្ញី ជាដើម សម្រាប់សម្គាល់វត្ថុសក្តិសិទ្ធិ មន្តអាគមតាមមនោគតិដែរ។

ការប្រើស្នាមគំនូសបែបនេះ ជនជាតិ អេហ្ស៊ីប កាលពី ៣ ពាន់ឆ្នាំមុន គ.ស. ក៏គេប្រើរូបសត្វ សម្រាប់កត់ត្រាព្រឹត្តិការណ៍ផ្សេងៗដែរ។ ហេតុដែលគេដឹងថា បុព្វជនជាតិអេហ្ស៊ីប ប្រើរូបសត្វជាអក្សរ ព្រោះមានសំណល់អក្សរ។ ឯបុព្វជនខ្មែរយើង ដែលថាមានអក្សរប្រើតាំងទីដើមបំផុតមកនោះ ក៏ព្រោះមានពង្សាវតាប្រាប់ថា មានសាក់ជាប់នឹងខ្លួនដែរ បើមានប្រើសាក់ដូច្នេះហើយ ពិតជាចេះធ្វើទឹកសរសេរ ចេះធ្វើប្រដាប់សម្រាប់កាន់សរសេរ។ បើចេះដល់ទៅសរសេរភ្ជាប់លើសាច់មនុស្សហើយ ពិតជាចេះសរសេរលើស្បែកសត្វ លើបន្ទះឈើ និងលើស្លឹកឈើទៀតមិនខាន គ្រាន់តែមិនបានឆ្លាក់លើថ្មប៉ុណ្ណោះ ទើបសំណេរទាំងអស់នោះ វិនាសបាត់អស់ទៅ គ្មានភស្តុតាងនៅដល់សព្វថ្ងៃ ព្រោះច្រើនពាន់ឆ្នាំណាស់មកហើយ។

ឯការឆ្លាក់លើថ្មនោះ ក៏យើងថាគ្មានមិនទាន់ត្រូវដែរ ព្រោះយើងមិនទាន់បានជីកកកាយ ក្នុងទឹកដីរបស់ខ្មែរពីដើម ឲ្យបានគ្រប់សព្វនៅឡើយ។

ខ្ញុំនិយាយដូច្នេះ ពិតជាមានអ្នកអានខ្លះរិះគន់ថា និយាយឈ្លើយតែម្នាក់ឯង ព្រោះពួកប្រវត្តិវិទូបរទេសគេមិនដែលនិយាយថា បុព្វជនខ្មែរសម័យបុរេប្រវត្តិជាមនុស្សចេះដឹង មានអក្សរប្រើឡើយ ខ្មែរអួតសរសើរតែខ្មែរ ជិះចង្កេះលើកតែខ្លួនឯង។

ការរិះគន់បែបនេះពិតជាត្រូវ ព្រោះគ្មាននណារស្រឡាញ់ខ្មែរជាងខ្មែរ គ្មាននរណាខំស្រាវជ្រាវរកឲ្យខ្មែរជាងខ្មែរ និងគ្មាននរណាផ្តល់យុត្តិធម៌ឲ្យខ្មែរជាងខ្មែរឡើយ។

ដូច្នេះយើងជាខ្មែរ មិនត្រូវធ្វើសេកសាលិកា ចាំតែថាត្រាប់តាមគេ ចាំតែចម្លងពីគេ ចាំតែជឿតាមគេ ឥតវិចារណញ្ញាណផ្ទាល់ខ្លួននោះឡើយ។ នេះជាគំនិតប្រពៃណីស្មារតីរបស់បុព្វជនខ្មែរ-ខមតាំងពីបុរាណកាលមក គួរកូនខ្មែរចាំកុំភ្លេច ហើយឲ្យចេះអនុវត្តតាមផង។

**ឥ- សិល្បៈ** (Arts) ក្នុងទីនេះ សំដៅយកការសម្តែងចេញនូវកាយវិការ និងសូរស័ព្ទតាមលក្ខណៈមនោសញ្ចេតនារបស់មនុស្ស បានដល់សិល្បៈផ្នែករបាំ តូរ្យតន្ត្រីនិងចម្រៀង។ មនុស្សកើតមានក្នុងលោកពេលណា សិល្បៈបែបនេះក៏កើតមានក្នុងពេលនោះដែរ។


www.elibraryofcambodia.org

ឯសិល្បៈផ្នែកនេះរបស់បុព្វជនខ្មែរ សម័យបុរេប្រវត្តិ បើតាមការសង្កេតឃើញ ដូចជាការផ្លុំស្លឹក បី ស្គរ គង ក្រាប់ និងរបាំផ្សេងៗ មានរបាំកន្ត្រែរ៉ែ ស្នែងទន្សោង និង អាយ៉ងជាដើម អាយ៉ងនេះ ឥណ្ឌូនេស៊ី នៅមានដល់ឥឡូវដូចខ្មែរ។ ចំពោះសិល្បៈខាងសូន្យរូប និងចម្លាក់ជាដើម ក៏បានបង្កើតឡើង បំពេញសេចក្តីត្រូវការ តាមទេពកោសល្យខ្លួនដែរ។

ពាក្យថាសិល្បៈនេះ អ្នកប្រាជ្ញក្នុងពិភពលោកសម័យបច្ចុប្បន្ន បានចែកជាបីប្រភេទ ៖

- សម្ផស្សសិល្បៈ (Artchrnel) សិល្បៈខាងសម្រើបចិត្ត គឺការបញ្ចេញសម្ផស្សរូបរាងសាច់មនុស្សជាលម្អមានការប្រើសម្លៀកបំពាក់ខ្លី ខើច ដើម្បីបញ្ចេញសាច់ដុំ សាច់ភ្លៅ និងក្បាលពោះជាដើម ដែលបុព្វជនខ្មែរយើងនិយមប្រើ ដូចមានរូបចម្លាក់នៅតាមប្រាសាទអង្គរស្រាប់។

- ចេតនាសិល្បៈ (Artcérébral) សិល្បៈនិយមន័យតាមគំនិត គឺធ្វើអ្វីៗសុទ្ធតែឲ្យមានន័យជាប់នៅក្នុងទង្វើនោះផង។ មិនគ្រាន់តែឲ្យមានន័យខាងសិល្បៈភ្លេង របាំ ចម្រៀង ជាដើមនោះទេ រហូតដល់សិល្បៈខាងស្ថាបត្យកម្មក៏ឲ្យមានន័យដែរ ដូចការស្ថាបនាទីក្រុងអង្គរ របស់បុព្វជនខ្មែរសម័យអង្គរ ដែលមានធ្វើកំពែងធំខ្ពស់ វែង និងជីកគូឲ្យមានទឹកដក់នៅជុំវិញក្រុងនោះ មិនមែនគ្រាន់តែការពារសត្រូវទេ មានន័យធំទូលាយណាស់ គឺតួទីក្រុង ជាតំណាងពិភពលោកទាំងមូល កំពែងព័ទ្ធជុំវិញ ជាតំណាងជួរភ្នំចក្កវាឡ គូដែលមានទឹកដក់នៅជុំវិញ ជាតំណាងមហាសាគរ ដែលព័ទ្ធជុំវិញពិភពលោក។ ត្រង់កណ្តាលក្រុង បានសាងប្រាសាទភ្នំមួយ ដូចតួប្រាសាទបាយ័ន អង្គរវត្តជាដើម ជាតំណាងភ្នំព្រះសុមេរុ គឺតំណាងទេវលោក ជាទីលំនៅនៃពួកទេវតា។

- សភាវគតិសិល្បៈ សិល្បៈនិយមតាមសភាវៈធម្មតា តាមការប្រព្រឹត្តទៅរបស់មនុស្សត្រង់ៗតែម្តង គឺដំណើរ បង្គុយ ការលើកដៃជើង តាមកាយវិការធម្មតាស្ទើរតែគ្មានអ្វីជាសិល្បៈផង ដូចសិល្បៈ ពួកជនស្បែកខ្មៅជាដើម។

សិល្បៈទាំងបីប្រភេទនេះ ចែកជាអនុប្រភេទមាន ៧ ទៅទៀត ដែលធ្លាប់ហៅថាសិល្បៈទី ១ ។ល។ ទី ៧ ដូចមានរាប់ឈ្មោះនៅទំព័រខាងដើមរួចហើយ។

៣) **ការអនុវត្ត** កាលបើមានការផ្សព្វផ្សាយនូវចំណេះវិជ្ជា តាមលក្ខណៈខាងលើនេះ ឲ្យបានជ្រួតជ្រាបដល់មហាជនហើយ ពួកមហាជនក៏នាំគ្នាអនុវត្តប្រព្រឹត្តធ្វើតាមមានលក្ខណៈដូចខាងក្រោមនេះ ៖

**ក- ទម្លាប់ទំនៀម** (Moeurs et coutumes) កាលបើបុព្វជនខ្មែរបង្កើតបានជា លទ្ធិជំនឿ ជំបូន្មាន វិទ្យាសាស្ត្រ-បច្ចេកទេស ភាសា អក្សរសាស្ត្រ និងសិល្បៈ ហើយផ្សព្វផ្សាយ


www.elibraryofcambodia.org

ទៅ ពួកមហាជនក៏នាំគ្នាប្រកាន់យកតាមទ្រឹស្តីនោះៗ មកទម្លាប់ប្រើគ្រប់ៗគ្នា កើតជាទម្លាប់ទំនៀម ប្រពៃណីឡើង ដូចជាទម្លាប់ទំនៀមខាងធ្វើសក្ការៈបូជា សែនព្រេនបន់ស្រន់ចំពោះវត្ថុសក្តិសិទ្ធិ ការកាន់ត្រណមផ្សេងៗ កំណោរសក់ បង្កក់ឆ្មប ប្រពៃណីខាងអាពាហ៍ពិពាហ៍ និងបុណ្យសពជាដើម។

ទម្លាប់ទំនៀម ប្រពៃណី របស់បុព្វជនខ្មែរក្នុងសម័យបុរេប្រវត្តិនោះ យើងមិនអាចដឹងច្បាស់បានឡើយ គ្រាន់តែដឹងតាមឯកសារចិនថា ក្នុងគ្រិស្តសតវត្សរ៍ទី ១ ពិធីបុណ្យសពរបស់ប្រទេសខ្មែរ ដូចគ្នានឹងប្រទេសចម្ប៉ាក្នុងសម័យនោះ គឺទម្លាប់ទំនៀមកាន់ទុក្ខត្រូវកោរសក់ កោរពុកមាត់ របៀបទុកដាក់សពមាន ៤ បែបគឺ កប់ក្នុងដី ចោលក្នុងព្រៃស្មសាន ទម្លាក់ក្នុងទឹក និងបូជាដោយភ្លើង។

បើក្នុងសម័យបន្ទាប់គ្នានោះ មានទម្លាប់ទំនៀមដូច្នេះប្រហែលជាក្នុងសម័យបុរេប្រវត្តិមុននោះ ក៏មានទម្លាប់ទំនៀមដូចគ្នាដែរ ព្រោះតាំងពីគ្រិស្តសតវត្សរ៍ទី ១ មកដល់សព្វថ្ងៃនេះ ២០ សតវត្សរ៍ហើយ ខ្មែរយើងនៅតែកោរសក់កាន់ទុក្ខ នៅតែកប់ ឬបូជាសពដដែល។

**ខ- ការសិក្សាអប់រំ** (Enseignement-Education) កាលបើមានទម្លាប់ទំនៀម ច្បាប់ដំបូន្មាន សិល្បៈ អក្សរសាស្ត្រ ដូច្នេះជាដើមហើយ បុព្វជនខ្មែរចូលចិត្តសិក្សាណាស់ កាលបើសិក្សាបានចេះដឹងហើយ តែងអប់រំខ្លួនឲ្យមានបែបបទសណ្តាប់ធ្នាប់ចរិយាសកម្មភាពល្អប្រសើរ តាមការសិក្សានោះៗ និងជួយអប់រំគ្នីគ្នាឲ្យបានចេះដឹងដូចខ្លួនដែរ មិនកំណាញ់ចំណេះវិជ្ជា យកចេះយកល្អតែខ្លួន បណ្តោយឲ្យជនរួមជាតិល្ងង់ខ្លៅឡើយ។ ជាពិសេស ជនជាតិខ្មែរយើង តាំងពីសម័យបុរេប្រវត្តិ រហូតដល់សព្វថ្ងៃ ច្រើនតែមានសន្តានចិត្តល្អប្រសើរណាស់ ខំជួយបង្ហាត់បង្រៀនអប់រំគ្នា ឥតយកតម្លៃឡើយ ដូចព្រះសង្ឃខ្មែរគ្រប់វត្តអារាមទាំងអស់ក្នុងប្រទេសបានយកព្រះទ័យទុកដាក់ជួយសង្គ្រោះបង្ហាត់បង្រៀនអប់រំយុវជន និងយាយ តា ខ្មែរ ឲ្យចេះដឹង ឲ្យបាយទឹក ទីដេកនៅថែមទៀត។

ក្នុងសម័យបុព្វជនខ្មែរ ច្រើនមានការសិក្សាអប់រំផ្ទាល់មាត់ ពីគ្រូអាចារ្យអ្នកដឹកនាំ ព្រោះលោកយល់ថា ពូកែសក្តិសិទ្ធិ ដូចបានទទួលចំណេះវិជ្ជា ដំបូន្មានពីមាត់ទិព្វ ហើយគោរពដឹងគុណគ្រូអាចារ្យនោះ ដូចមាតាបិតាបង្កើតដែរ។

**គ- ល្បែងកីឡា** (Jeux-Sport) លក្ខណៈវប្បធម៌នេះ ជាការអនុវត្តមួយមានប្រយោជន៍យ៉ាងសំខាន់ ចំពោះផ្លូវកាយ និងចិត្ត គឺការហ្វឹកហាត់អត្តពលខាងកាយសម្បទាផង ការកម្សាន្ត សប្បាយ កែអផ្សុក ឲ្យមានកម្លាំងប្រាជ្ញាថ្លាគំនិតផង។


www.elibraryofcambodia.org

បុព្វបុរសខ្មែរសម័យបុរេប្រវត្តិ បានបង្កើតល្បែងកីឡានេះ ច្រើនបែបណាស់ តាមបច្ចេកទេសរបស់ខ្លួនផ្ទាល់ ដើម្បីបំពេញនូវកាយសម្បទា និងចិត្តសម្បទា ឲ្យមានថាមពលបរិបូណ៌ អាស្រ័យហេតុនេះ ទើបបុព្វបុរសខ្មែរ មានមាឌមាំៗបរិបូណ៌ដោយសាច់ដុំ មានកម្លាំងច្រើន មានរាងសង្ហាស្វាហាប់ ចិត្តមុតដាច់ស្រេច ជាញជ័យណាស់។

ឯល្បែង-កីឡាក្នុងជំនាន់នោះ បើតាមការសង្កេតឃើញដូចជា ការប្រដាល់ គុណដំបង បោកចំបាប់ បាញ់ធ្នូស្នា ចោលកំបិត គុនដាវ លំពែង ហែលទឹក ប្រណាំទូក ទាត់សី ទល់អង្រែ ទាញព្រ័ត ចោលឈូង វាយហ៊ឹង និងវាយប៉ាងក្នុងទឹកជាដើម។ ល្បែង-កីឡាទាំងអស់នេះ នៅរហូតដល់សព្វថ្ងៃ មានខ្លះបានក្លាយជាកីឡាអន្តរជាតិផង។

## លក្ខណៈសង្គមធម៌

### លក្ខណៈនេះចែកជាបីផ្នែកដែរ គឺ៖

១- សង្គមវិធី (Sociologie)

២- សង្គមសម្ភារៈ (Equipement social)

៣- សង្គមរចនាសម្ពន្ធ (Structure sociale)

**១- សង្គមវិធី** គឺជាទ្រឹស្តីនៃសង្គម សម្រាប់សិក្សាផង សម្រាប់ប្រតិបត្តិបង្កើតផលក្នុងសង្គមផង មានលក្ខណៈដូចតទៅនេះ ៖

**ក. នីតិសាស្ត្រ** (Juridique) កាលណាវប្បធម៌មានលក្ខណៈគ្រប់គ្រាន់ហើយ វឌ្ឍនធម៌ក៏កើនចម្រើនឡើង សង្គមជាតិ ក៏ចម្រើនលូតលាស់ដែរ។ ពេលនោះ បញ្ហាសង្គមបានចោទឡើង ត្រូវរៀបចំលក្ខណៈសង្គមធម៌ ក្នុងពេលជាបន្ទាន់ដែរ ជាបឋមត្រូវរៀបចំបង្កើតឲ្យមានច្បាប់ ដែលហៅថា នីតិសាស្ត្រ បានដល់នីតិបញ្ញត្តិ និងនីតិប្រតិបត្តិ គឺមានអ្នកបង្កើតច្បាប់ និងអ្នកប្រតិបត្តិច្បាប់ សម្រាប់ការពារសិទ្ធិសេរីភាព របស់បុគ្គលម្នាក់ៗ ឲ្យបានរស់នៅប្រកបដោយយុត្តិធម៌ក្នុងសង្គមជាតិ។

ក្នុងសម័យបុរាណ ច្រើនតែមេកន្ទ្រាញ ឬមហាក្សត្រជាអ្នកបង្កើតច្បាប់ នីតិបញ្ញត្តិ មេកង ឬអ្នករាជការ ជាអ្នកប្រតិបត្តិច្បាប់។

នីតិសាស្ត្រក្នុងសម័យបុរេប្រវត្តិនោះ យើងមិនអាចដឹងឲ្យបានច្បាស់លាស់ថា បុព្វជនខ្មែរបានរៀបចំដូចម្តេចឡើយ គ្រាន់តែដឹងតាមហេតុផលថា ច្បាប់ក្នុងសម័យនោះ ទោះមានឈ្មោះ មានលក្ខណៈប្លែកយ៉ាងណា ក៏មានន័យត្រឹមតែរៀបចំឲ្យមានយុត្តិធម៌ក្នុងសង្គមជាតិ ដូចជាក្រមព្រហ្មទណ្ឌ ច្បាប់រដ្ឋប្បវេណី និងរដ្ឋធម្មនុញ្ញយើងក្នុងសម័យនេះដែរ។


www.elibraryofcambodia.org

**ខ- សេដ្ឋកិច្ច** (Economie) ការបង្កើតភោគផលក្នុងសង្គមជាតិ បានដល់ការធ្វើកសិកម្ម ពាណិជ្ជកម្ម និងឧស្សាហកម្ម។

សេដ្ឋកិច្ចរបស់បុព្វជនខ្មែរក្នុងសម័យបុរេប្រវត្តិនោះ យើងអាចដឹងបានតាមបុរាណវត្ថុដែលគេរកឃើញនៅសំរោងសែន អន្លង់ផ្ដៅ និងម្លូព្រៃ ជាដើម។ បុរាណវត្ថុទាំងនេះប្រាប់ឲ្យយើងដឹងថា កាលនោះសេដ្ឋកិច្ចខ្មែរ បានចម្រើនសមតាមកាលៈទេសៈហើយ ព្រោះខ្មែរចេះធ្វើកសិកម្ម ពាណិជ្ជកម្មនិងឧស្សាហកម្ម ដូចជាធ្វើគ្រឿងប្រដាប់ប្រើប្រាស់ ពីដីឆៅ ដីដុត ពីថ្ម ពីដែក ស្ពាន់ លង្ហិន សំរិទ្ធ ។ល។ ហើយលក់ដូរចែកគ្នាប្រើក្នុងប្រទេស និងមានធ្វើពាណិជ្ជកម្ម ក្រៅប្រទេសទៀត បានដឹកនាំផលិតផលផ្សេងៗ មាន ស្បែក ស្នែង គ្រឿងទេសភ្លុក គុជ មាស ប្រាក់ និងត្បូងជាដើម ទៅលក់ឲ្យប្រទេសជិតខាង មានប្រទេស ចម្ប៉ា-មន ។ល។ ព្រោះក្នុងសម័យបន្ទាប់មក គេរកឃើញ កំពង់ផែពានិជ្ជកម្មអន្តរជាតិមួយរបស់ខ្មែរឈ្មោះកំពង់ អូ-កែវ។ ក្នុងបរិវេណកំពង់នេះ គេបានរកឃើញបុរាណវត្ថុ មានចំណាស់តាំងពីដើមគ្រិស្តសតវត្សរ៍ទី ១ ម្ល៉េះ។ ដូច្នេះ កំពង់នេះ ពិតជាកើតមានមុន គ.ស. យូរអង្វែងហើយ។

**គ- សង្គមកិច្ច** (Action sociale) បានដល់កិច្ចការ ដែលធ្វើឡើងដើម្បីជួយឃឹតយោងសង្គមមនុស្សឲ្យបានសុខចម្រើន។ ជាពិសេស ជួយទំនុកបម្រុងមនុស្សអនាថាកំសត់ទុគ៌តជរាពិការ និងជួយសម្រួលជីវភាពគ្នាទៅវិញទៅមក ដូចជានាំគ្នាជីកអណ្ដូង ជីកស្រះលើកទំនប់ ធ្វើផ្លូវ ស្ពាន សង់សាលាសំណាក់ មន្ទីរព្យាបាលរោគ និងសាលារៀនជាដើម។

សង្គមកិច្ច របស់បុព្វជនខ្មែរ ក្នុងសម័យបុរេប្រវត្តិនោះ យើងមិនអាចដឹងបានថាមានលក្ខណៈបែបណាឡើយ គ្រាន់តែដឹងតាមហេតុផលថា ពិតជាមានបរិបូណ៌ ស្របតាមកាលៈទេសៈនោះ ទើបសង្គមជាតិខ្មែរចេះតែចម្រើនលូតលាស់ ជាលំដាប់មក។

**ឃ- នយោបាយ** (Politique) កិច្ចការគ្រប់គ្រងសង្គមជាតិ គ្រប់គ្រងរដ្ឋ គឺឧបាយក្នុងការណែនាំសង្គមជាតិទៅរកទីដៅណាមួយ ដែលពួកអ្នកដឹកនាំយល់ថាល្អ ដោយមានប្រជាជនក្នុងសង្គមជាតិស្ម័គ្រចិត្តផង។

នយោបាយរបស់បុព្វជនខ្មែរ ក្នុងសម័យបុរេប្រវត្តិនោះ ក៏យើងមិនបានដឹងច្បាស់ដែរ គ្រាន់តែបានដឹងខ្លះ តាមប្រវត្តិពង្សាវតា និងតាមឯកសារចិនថា ប្រទេសខ្មែរមានព្រះរាជិនីសោយរាជ្យ ជាទំនៀមជាប់រហូតដល់មក ព្រះរាជិនី លៀវ យី ក្នុងគ្រិស្តសតវត្សរ៍ទី ១ ការគ្រប់គ្រងប្រជាជន បានចែកជារដ្ឋតូចៗ មានទីក្រុង មានសង្កាត់ ភូមិ ស្រុក មានអ្នករាជការ មានមេទ័ព ជាអ្នកទទួលព្រះរាជបញ្ជាចាត់ការថ្វាយ។ ឯនយោបាយក្រៅប្រទេស


www.elibraryofcambodia.org

ក្នុងពេលនោះ មានការទាក់ទងជាមួយប្រទេសជិតខាង ដូចប្រទេសមន ចម្ប៉ា និងជ្វាជាដើម ដែលនៅតាមកោះ។

**២- សង្គមសម្ភារៈ** គឺការផ្គត់ផ្គង់នូវវត្ថុចាំបាច់របស់សង្គម ដូចជាប្រដាប់ប្រើប្រាស់ និងមុខរបរជាដើម មានលក្ខណៈដូចខាងក្រោមនោះ ៖

**ក- ឧបករណ៍** (Instruments) គ្រឿងប្រដាប់ប្រើប្រាស់ បរិធានសម្រាប់ប្រើក្នុងការងារ គឺអ្វីៗ សម្រាប់ប្រើឲ្យបានសម្រេចផល ដូចគ្រឿងយន្ត និងគ្រឿងឧបករណ៍ផ្សេងៗទៀត សម្រាប់ប្រើក្នុងរោងជាង និងក្នុងការដ្ឋានទាំងឡាយ មានកាំបិត ពន្លាក កឹតម្បាញ រទេះ នាវាជាដើម ដែលអាចបង្កើតផល ឲ្យកើតជាគ្រឿងឧបភោគបរិភោគ និងឱសថសម្រាប់សង្គមជាតិប្រើប្រាស់ឲ្យបានគ្រប់គ្រាន់ តាមសេចក្តីត្រូវការ។

គ្រឿងឧបករណ៍ របស់បុព្វជនខ្មែរ ក្នុងសម័យបុរេប្រវត្តិ យើងអាចដឹងបានតាមបុរាណវត្ថុថា ថាគ្រប់គ្រាន់តាមកាលៈទេសៈក្នុងសម័យនោះ ដូច កាំបិត ពូថៅ ពន្លាក ត្រល់ និងឡដុតរំលាយ ដែក ស្ពាន់ លង្ហិន សំរិទ្ធ សម្រាប់សិទ្ធធ្វើគ្រឿងប្រដាប់ប្រដាប្រើប្រាស់ និងមាន រទេះសេះដំរី នាវាសម្រាប់ដឹកនាំជាដើម ដើម្បីបំពេញនូវសេចក្តីត្រូវការរបស់សង្គមជាតិ។

**ខ. វិជ្ជាជីវៈ** (Métiers) មុខរបរ ការងារផ្សេងៗសម្រាប់មនុស្ស ក្នុងសង្គមជាតិ ធ្វើតាមសមត្ថភាពរបស់ខ្លួន ដើម្បីរស់នៅតាមលទ្ធភាពរៀងៗខ្លួន។

វិជ្ជាជីវៈរបស់បុព្វជនខ្មែរ ក្នុងសម័យបុរេប្រវត្តិ ក៏ដូចជាក្នុងសម័យបន្តបន្ទាប់មកដែរ គឺមានមុខរបរខាងស្រែចម្ការ ខាងជំនាង ខាងនេសាទ ខាងធ្វើការរាជការ ស៊ីវិល ទាហានជាដើម ព្រោះមានសង្គមវិធី និងមានលក្ខណៈវប្បធម៌សព្វគ្រប់ហើយ។

**៣ សង្គមរចនាសម្ព័ន្ធ** គឺគម្រោងការសង្គមសម្រាប់ចាត់ការសាងសង្គមជាតិ មានលក្ខណៈដូចខាងក្រោមនេះ ៖

**ក. វណ្ណវិភាគ** (Division sociale) ការចែកឋានៈមនុស្សក្នុងសង្គម តាមសមត្ថភាព ចំណេះវិជ្ជា ទ្រព្យសម្បត្តិ និងបុណ្យសក្តិ ដើម្បីឲ្យមានរបៀប ឲ្យស្គាល់ធំតូចស្គាល់មេ ស្គាល់កូន កុំឲ្យមានអនាធិបតេយ្យក្នុងសង្គមជាតិ។

ការចែកឋានៈមនុស្ស របស់បុព្វបុរសខ្មែរក្នុងសម័យបុរេប្រវត្តិ បើពិនិត្យតាមប្រវត្តិ ពង្សាវតារ ដែលមានក្នុងសម័យបន្ទាប់មកនោះ ឃើញថា សមរម្យស្របតាមសមត្ថភាព មនុស្សពេញទី គឺចែកតាមសមត្ថភាព មានក្សត្រ មាននាម៉ឺន មានរាស្ត្រ មានអ្នកចេះ អ្នកល្ងង់ អ្នកមាន អ្នកក្រ សមរម្យតាមច្បាប់ធម្មជាតិ ដែលបង្កើតមនុស្សមកមិនស្មើគ្នា។ ឯការចែក


www.elibraryofcambodia.org

វណ្ណៈជា ៤ ហើយប្រកាន់មើលងាយគ្នា តាមរបៀបឥណ្ឌាបុរាណនោះ បុព្វបុរសខ្មែរយើង ក្នុងសម័យបុរេប្រវត្តិ មិនបានប្រើទេ ព្រោះសម័យនោះ មិនទាន់មានអារ្យធម៌ឥណ្ឌាចូលមក ឡើយ។

**ខ. ស្ថាប័ន** (Institutions) ការតាំង បង្កើត ឬស្ថាបនា ជាអង្គការរួមកម្លាំងគ្នា ជាពួក ជាក្រុម ទោះមនុស្សក្នុងសង្គមនោះ មានឋានៈបែបណា ក្នុងវណ្ណវិភាគណា ក៏អាចចូលរួម គ្នាបានដោយសេរី ដើម្បីសាងវឌ្ឍនភាពក្នុងសង្គមជាតិ ដូចជាការធ្វើក្រុមហ៊ុន សមាគម សហករណ៍ សហគម គណៈ និងចលនាផ្សេងៗ របស់រដ្ឋក្តី របស់ឯកជនក្តី។

ស្ថាប័នរបស់បុព្វជន ក្នុងសម័យបុរេប្រវត្តិនោះ យើងមិនអាចដឹងថា មានឈ្មោះនាម ដូចម្តេចទេ គ្រាន់តែដឹងថា ពិតជាមាន ព្រោះមានសង្គមវិធី សង្គមសម្ភារៈ និងមានលក្ខណៈ វប្បធម៌សព្វគ្រប់ហើយ។

**គ. ប្រជាជាតិ** (Nation) សារព័ននៃមនុស្សក្នុងរដ្ឋមួយ ដែលមានដើមកំណើត វង្សត្រកូលជាមួយគ្នា មានភាសាជាមួយគ្នា មានផលប្រយោជន៍រួមគ្នាមកយូរអង្វែងហើយ។ ពាក្យថាប្រជាជាតិនេះ ជាឈ្មោះរួមរបស់សង្គមជនក្នុងវណ្ណវិភាគ ក្នុងស្ថាប័ននោះឯង ដែលមានរបៀបគ្រប់គ្រងរួមគ្នា គឺប្រជាជាតិមួយ ស្ថិតនៅក្រោមអំណាចច្បាប់តែមួយរបស់ ខ្លួន ច្បាប់នោះ ត្រូវប្រើទៅលើប្រជាជាតិទាំងមូល ទោះជាច្បាប់រក្សាការពារសិទ្ធិសេរីភាពក្តី ផ្តន្ទាទោសក្តី បង្ខិតបង្ខំក្តី។

សង្គមជនក្នុងវណ្ណវិភាគ និងក្នុងស្ថាប័នទាំងអស់ត្រូវមានសិទ្ធិសេរីភាព និងករណីកិច្ច ក្នុងប្រជាជាតិខ្លួន តាមលក្ខណៈច្បាប់ស្មើគ្នា គោរពអ្នកដឹកនាំសង្គមជាតិតែមួយរួមគ្នា មានកេតនភណ្ឌរួមគ្នា មានការថែរក្សាការពារសង្គមជាតិនិងបូរណភាពទឹកដីជាដើមរួមគ្នា មានការទទួលខុសត្រូវចំពោះសាវតារជាតិជាមួយគ្នា។

ប្រជាជាតិរបស់បុព្វជនខ្មែរ ក្នុងសម័យបុរេប្រវត្តិ ក៏មានលក្ខណៈប្រហែលគ្នា នឹងប្រជាជាតិក្នុងលោកសព្វថ្ងៃនេះដែរ គឺមានច្បាប់ មានមគ្គុទេសក៍ មានកេតនភណ្ឌ និងមានការទទួលខុសត្រូវចំពោះសាវតារជាតិរួមគ្នា គ្រាន់តែប្លែកគ្នាចំពោះលក្ខណៈខ្លះ តាមកាលៈទេសៈប៉ុណ្ណោះ។

សមត្ថភាពដែលអាចរៀបចំលក្ខណៈវប្បធម៌ និងលក្ខណៈសង្គមជាតិ ដូចអធិប្បាយ មកនេះ ជាអារ្យធម៌ប្រភេទទី ៤ ឈ្មោះសមត្ថភាពជាអារ្យធម៌បន្ទាប់បន្សំ តូចទាបជាង អារ្យធម៌ទី ១ ព្រោះថា បើទុកជា មានសមត្ថភាពចេះរៀបចំលក្ខណៈវប្បធម៌ និងសង្គមធម៌ បានល្អវិសេសយ៉ាងណាក៏ដោយ បើគ្មានការប្រតិបត្តិតាម គ្មានចរិយាមារយាទល្អ


www.elibraryofcambodia.org

តាមទ្រឹស្តីដែលខ្លួនបង្កើតនោះទេ គឺមានតែផែនការមានតែទ្រឹស្តី ហើយប្រព្រឹត្តធ្វើផ្តេសផ្តាស តាមអំពើចិត្តនោះ សុខសន្តិភាព និងសេចក្តីចម្រើនរុងរឿង ក៏មិនមានឡើយ បើកំពុងតែមាន ក៏ត្រូវវិនាសបាត់បង់ទៅវិញដែរ។

អារ្យធម៌ទាំង ៤ ក្នុងសម័យបុរេប្រវត្តិ ដូចអធិប្បាយខាងលើនេះ មកទល់ឆ្នាំ ៣០៩ មុន គ.ស. ចាត់ជាប្រភេទមនខ្មែរ ជាខេមរនិយម។ តពីឆ្នាំ ៣០៩ មុន គ.ស. នោះមកទើបមានពុទ្ធនិយម ព្រហ្មនិយម បរទេសនិយម និងមានអនុប្រភពឥណ្ឌា-ចិន ជាដើមទៀត។

(ចប់អារ្យធម៌ខ្មែរសម័យបុរេប្រវត្តិ)

៚

CAMBODIAN EDUCATION EXCELLENCE
មូលនិធិខ្មែរសម្រាប់ការសិក្សា
FOUNDATION


www.elibraryofcambodia.org

# គម្រូទអារ្យធម៌

អារ្យធម៌ទាំង ៤ ប្រភេទ ដូចអធិប្បាយតាំងពីខាងដើមមកដល់សម័យបុរេប្រវត្តិនេះ បើដកយកលក្ខណៈសំខាន់ៗ មកចងក្រងជាបាច់ចង្កោម ធ្វើជាគម្រូង ឲ្យងាយយល់ មានដូចខាងក្រោមនេះ។

- ប្រភេទនៃអារ្យធម៌
  - ១- អាចារៈ
  - ២- ទស្សនីយភាវៈ
  - ៣- លិង្គៈ
  - ៤- សមត្ថភាវៈ។
- អនុប្រភេទនៃអារ្យធម៌
  - ទី១
    - ក- ប្រព្រឹត្តល្អដោយកាយ
    - ខ- ប្រព្រឹត្តល្អដោយវាចា
    - គ- ប្រព្រឹត្តល្អដោយចិត្ត។
  - ទី ២
    - ក- ទិដ្ឋភាពនៃឥរិយាបថសមរម្យ
    - ខ- ទិដ្ឋភាពនៃទីឋានសមរម្យ។
  - ទី ៣
    - ក- ភេទសមរម្យតាមបែបបទបុរស
    - ខ- ភេទសមរម្យតាមបែបបទស្ត្រី។
  - ទី ៤
    - ក- សមត្ថភាពខាងអក្សរសាស្ត្រ
    - ខ- សមត្ថភាពខាងបច្ចេកទេស។
- មូលនៃអារ្យធម៌
  - ទី១
    - ក- មនុស្សធម៌
    - ខ- សីលធម៌
    - គ- អាចារវប្បៈ
    - ឃ- អាចារវឌ្ឍនៈ។
  - ទី ២
    - ក- សុជីវធម៌
    - ខ- ទស្សនីយភាវវប្បៈ
    - គ- ទស្សនីយភាវវឌ្ឍនៈ។
  - ទី ៣
    - ក- សុជីវធម៌
    - ខ- លិង្គវប្បៈ
    - គ- លិង្គវឌ្ឍនៈ។


www.elibraryofcambodia.org

ទី ៤ { ក- បញ្ញាវប្បៈ
ខ- បញ្ញាវន្តរៀនៈ។

CAMBODIAN • EDUCATION • EXCELLENCE
មូលនិធិខ្មែរសម្រាប់ការសិក្សា
FOUNDATION


www.elibraryofcambodia.org

នាទីនៃអារ្យធម៌
- ទី ១
  - ក- បង្កើតសាមគ្គីធម៌
  - ខ- បង្កើតសុខសន្តិភាព។
- ទី ២
  - ក- រៀបចំឥរិយាបថរូបឆោមសមរម្យ
  - ខ- រៀបចំទីឋានមានរបៀបត្រឹមត្រូវ។
- ទី ៣
  - ក- រៀបចំភេទបុរសមានបែបបទ
  - ខ- រៀបចំភេទស្ត្រីមានបែបបទ។
- ទី ៤
  - ក- រៀបចំលក្ខណៈវប្បធម៌
  - ខ- រៀបចំលក្ខណៈសង្គមធម៌។

ប្រភព-អនុប្រភពនៃអារ្យធម៌
- មន-ខ្មែរ
- ឥណ្ឌា
- ចិន
- បស្ចិមប្រទេស។

និយមន័យនៃអារ្យធម៌
- ខេមរនិយម
- ពុទ្ធនិយម
- ព្រហ្មនិយម
- បរទេសនិយម។

សម័យនៃអារ្យធម៌
- បុរេប្រវត្តិ
- បុរេអង្គរ
- អង្គរ
- បច្ឆាអង្គរ
- អាណានិគម-ឯករាជ្យសក្តិភូមិ
- ឯករាជ្យសាធារណរដ្ឋ។

FOUNDATION

- លក្ខណៈសង្គមធម៌
  - ការចេះដឹង
    - ក- ទស្សនវិជ្ជា
    - ខ- លទ្ធិ[6]
    - គ- ជំនឿ
    - ឃ- មនុស្សធម៌
    - ង- សីលធម៌
    - ច- វិទ្យាសាស្ត្រ-បច្ចេកទេស។
  - ការផ្សាយ
    - ក- ភាសា[7]
    - ខ- អក្សរសាស្ត្រ
    - គ- សិល្បៈ។
  - ការអនុវត្ត
    - ក- ទម្លាប់ទំនៀមប្រពៃណី
    - ខ- ការសិក្សាអប់រំ
    - គ- ល្បែងកីឡា។
  - សង្គមវិធី
    - ក- នីតិសាស្ត្រ
    - ខ- សេដ្ឋកិច្ច
    - គ- សង្គមកិច្ច
    - ឃ- នយោបាយ។
  - សង្គមសម្ភារៈ
    - ក- ឧបករណ៍
    - ខ- វិជ្ជាជីវៈ។
  - សង្គមរចនាសម្ពន្ធ
    - ក- វណ្ណវិភាគ
    - ខ- ស្ថាប័ន
    - គ- ប្រជាជាតិ[8]។

CAMBODIAN EDUCATION EXCELLENCE FOUNDATION

ការដាក់កម្រងអារ្យធម៌ជាប់នឹងសម័យបុរេប្រវត្តិនេះ ដើម្បីងាយពិនិត្យមើល ព្រោះមាននិយាយគ្រប់សព្វលក្ខណៈទាំងអស់ ដែលមាននិយាយក្នុងកម្រងនេះ។

---

[6] លទ្ធិ ជំនឿចំពោះវត្ថុសក្តិសិទ្ធិ-សាសនា ឬមនោគមវិជ្ជា។

7 ភាសា អក្សរសាស្ត្រមានន័យទូទៅគ្រប់ពត៌មាន និងសញ្ញាផ្សេងៗ។

8 ថា រដ្ឋ-ប្រជាជាតិក៏បាន ថាត្រឹមតែប្រជាជាតិក៏មានន័យដល់រដ្ឋដែរ។

តទៅខាងមុខអារ្យធម៌ក្នុងសម័យមួយៗ មិនបាននិយាយសព្វគ្រប់ទៀតឡើយ និយាយចំពោះតែលក្ខណៈណា ដែលប្លែកគ្នាច្រើន ពីសម័យមួយទៅសម័យមួយប៉ុណ្ណោះ។

CAMBODIAN EDUCATION EXCELLENCE
មូលនិធិខ្មែរសម្រាប់ការសិក្សា
FOUNDATION


www.elibraryofcambodia.org

# អារ្យធម៌ខ្មែរសម័យបុរេអង្គរ

## អនុប្រភេទឥណ្ឌាចិន

(ពី គ.វ. ទី ១ ដល់ គ.វ. ទី ៨)

ក្នុងរយៈកាលដ៏វែង ៨ សតវត្សរ៍ តពីសម័យបុរេប្រវត្តិនោះមក អារ្យធម៌ខ្មែរចេះតែរីកដុះដាលជាលំដាប់តាមកាលៈទេសៈ។

អារ្យធម៌សម័យបុរេអង្គរនេះ ក៏ចាប់និយាយពីត្រឹមរាជ្យបឋមក្សត្រខ្មែរ ដែលមានជាដំបូងបំផុតក្នុងពង្សាវតារ ពីគ.ស. ទី ៦៨ មកទល់ត្រឹមរាជ្យស្ដេច[9]ជ័យវរ្ម័នទី ២។

បឋមក្សត្រខ្មែរនេះ មានព្រះនាមបីយ៉ាងតាមឯកសារផ្សេងៗ ៖

- ឯកសារចិនថា ស្ដេចហ៊ុន ទៀន ព្រះនាង លៀវ យី
- សិលាចារឹកមីសឹងថា ស្ដេចកៅណ្ឌិន្យ ព្រះនាងនាគីសោមា
- ពង្សាវតារថា ព្រះថោង នាងនាគ។

ព្រះនាងលៀវ យី ឬនាគីសោមា ឬនាងនាគនេះឯងជាព្រះរាជិនីខ្មែរ សម័យនគរភ្នំ ចិនហៅនគរហ្វូណាន សិលាចារឹកខ្មែរបុរាណហៅ នគរកុរុងភ្នំ ឬវ្រះវ្នំ ពង្សាវតារហៅនគរគោកធ្លក ពាក្យសំស្រ្កឹតហៅនគរបវិតភូបាល ឬសៃលរាជ ប្រែថា នគរស្ដេចភ្នំ។

ព្រះរាជិនី លៀវ យី នេះ ក្នុងពង្សាវតារយើងគ្មាននិយាយថា មានព្រះរាជសន្តតិវង្សពីក្សត្រអង្គណាមកឡើយ ក្នុងឯកសារចិន ក៏មិនបាននិយាយច្បាស់លាស់ដែរ គ្រាន់តែនិយាយថា «នៅប្រទេសនគរភ្នំ មានព្រះរាជិនីសោយរាជ្យ ជាទំនៀមរបស់ប្រទេសនេះជាយូរអង្វែងមកហើយ។ តមកមានព្រះរាជិនីមួយអង្គ ព្រះនាម លៀវ យី មានព្រះឆោមលោមព័ណល្អស្រស់ឆើតឆាយ មានព្រះកាយពលខ្លាំងមាំមួយដូចព្រះរាជកុមារ។ សម័យមួយ មានព្រាហ្មណ៍កម្លោះម្នាក់ជាតិឥណ្ឌា ឈ្មោះ ហ៊ុន ទៀន បានធ្នូសរមួយដែលទេវតាប្រទាន ក៏ចុះសំពៅផ្សងព្រេង មកដល់ប្រទេសនគរភ្នំ ព្រះរាជិនី លៀវ យី ឃើញហើយលើកពលវេហ៍ជើងទឹកទៅច្បាំង» ។ល។

[9] តាមទម្លាប់ក្នុងសម័យរាជានិយម ខ្មែរយើងធ្លាប់ហៅឈ្មោះថា ព្រះបាទៗ ដូចព្រះបាទជ័យវរ្ម័នជាដើម ព្រោះខ្មែរសម័យនោះ រស់នៅក្រោម ល្អងធូលីព្រះបាទស្ដេច ក្នុងសម័យសាធារណរដ្ឋខ្មែរនេះ យើងឈប់រស់នៅ ក្រោមព្រះបាទស្ដេចហើយ ត្រូវហៅថាស្ដេចៗវិញ ដូចជាស្ដេចជ័យវរ្ម័ន ស្ដេចអង្គឌួង ជាដើម ឈប់ថា ព្រះបាទជ័យវរ្ម័ន ព្រះបាទអង្គឌួងតទៅទៀត។


www.elibraryofcambodia.org

មុនរជ្ជកាលព្រះរាជិនី លៀវ យី នេះ អារ្យធម៌ឥណ្ឌាបានចូលមកជាមួយពុទ្ធសាសនាជាង ៣០០ ឆ្នាំហើយ។ ប្រជាជនខ្មែរ មានសេចក្ដីជ្រះថ្លាចំពោះអមតធម៌របស់ព្រះពុទ្ធបានពង្រីកអារ្យធម៌ប្រភេទទី ១ គឺអាចារៈ ដែលប្រកបដោយសីលធម៌ និងមនុស្សធម៌ស្រាប់មកហើយនោះ ឲ្យរឹងរឹតតែមានគុណភាពប្រសើរវិសេសតាមពុទ្ធធម៌ កើតជាពុទ្ធនិយមឡើងក្នុងអារ្យធម៌ខ្មែរមុនគេបំផុត។

ឯអារ្យធម៌ប្រភេទទី ២ ទី ៣ ទី ៤ មិនទាន់មានការកែប្រែប្លែកប៉ុន្មានពីប្រភពដើម គឺប្រភពមនខ្មែរ ដែលបានចម្រើនមកហើយនោះឡើយ ព្រោះពុទ្ធសាសនាដែលចូលមកនោះ គ្មានការបង្ខិតបង្ខំ ស្រេចតែសម្បជញ្ញៈរបស់ខ្មែរ បើយល់ឃើញត្រង់ណាល្អ ស្របនឹងឧត្ដមគតិខ្លួន ក៏ទទួលយកមកប្រតិបត្តិទៅ អាស្រ័យពុទ្ធសាសនា ប្រកបដោយលទ្ធិប្រជាធិបតេយ្យបែបនេះហើយ ទើបតែចេះនៅក្នុងប្រទេសកម្ពុជារហូតដល់សព្វថ្ងៃ មិនដែលបាត់បង់ម្ដងណាឡើយ គឺពេលណាដែលមហាក្សត្រមិនគោរពកាន់ពុទ្ធសាសនា មានពួកនាម៉ឺននិងរាស្ត្រគោរពរក្សាតៗមក។

លុះដល់ព្រាហ្មណ៍ ហ៊ុន ទៀន ដែលព្រះរាជិនី លៀវ យី សព្វព្រះទ័យទទួលជាស្វាមីហើយ អភិសេកជាព្រះមហាក្សត្រ ចាត់ទុកក្នុងពង្សាវតារ ជាបឋមក្សត្រខ្មែរខាងសោមវង្សនោះ មានអំណាចគ្រប់គ្រងព្រះរាជាណាចក្រ នគរភ្នំ ហើយព្រះអង្គបាននាំលទ្ធិព្រាហ្មណ៍ គឺព្រហ្មញ្ញសាសនា ដែលមានគម្ពីត្រៃវេទជាក្បួនច្បាប់ ត្រង់គ្រាប់គោរពព្រះព្រហ្ម ព្រះឥសូរ មកផ្សាយក្នុងព្រះរាជាណាចក្រ ដឹកនាំប្រជាពលរដ្ឋនគរភ្នំឲ្យគោរពប្រតិបត្តិតាមលទ្ធិថ្មីនេះ ក្នុងនាមព្រះមហាក្សត្រ ប៉ុន្តែព្រះអង្គមិនបានបំបិទសិទ្ធិខាងជំនឿ ដែលធ្លាប់មានពីបុរាណកាល និងជំនឿខាងពុទ្ធសាសនាឡើយ។

ក្នុងសម័យនេះហើយ អារ្យធម៌ខ្មែរ ដែលមានតាំងពីសម័យបុរេប្រវត្តិមកនោះ បានរីកដុះដាលឡើង មានព្រំដែនកាន់តែធំ ដោយបានទទួលជីវជាតិពីលទ្ធិទាំងពីរមកផ្សំជាមួយផង។ ចំពោះអារ្យធម៌ប្រភេទទី ៤ គឺសមត្ថភាវៈ បានរីកដុះដាល ប្លែកពីសភាពដើមយ៉ាងច្រើន ព្រោះបានកែប្រែលក្ខណៈវប្បធម៌ និងលក្ខណៈសង្គមធម៌ អនុលោមទៅតាមលទ្ធិព្រហ្មញ្ញសាសនា ដែលព្រះមហាក្សត្រគោរពរាប់អាន កើតជាព្រហ្មនិយមឡើងមួយទៀត ក្នុងអារ្យធម៌ខ្មែរ។

**អំពីលក្ខណៈវប្បធម៌** = ខាងទស្សនវិជ្ជា (Philosophie) លទ្ធិ (Religion) និងជំនឿ (Croyance) កាលមុនក្នុងសម័យបុរេប្រវត្តិ ប្រជាជនខ្មែរ មានទស្សនៈយល់ឃើញហើយប្រកាន់ជឿ គោរពបូជាចំពោះទេវតា អារក្ស អ្នកតា ខ្មោច ដូនជីតា មាតាបិតា គ្រូបាអាចារ្យ


www.elibraryofcambodia.org

ដល់មកខាងចុងសម័យបុរេប្រវត្តិ មានទស្សនៈយល់ឃើញតាមពុទ្ធសាសនា ហើយគោរព បូជាចំពោះ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃទៀត ដល់មកដើមសម័យបុរេអង្គរ បានគោរព ប្រតិបត្តិ បូជាចំពោះ ព្រះព្រហ្ម ព្រះឥសូរជាដើម តាមលទ្ធិព្រហ្មញ្ញសាសនាថែមទៀត។

លុះដល់មកគ្រិស្តសតវត្សរ៍ទី ៨ មានលទ្ធិពុទ្ធសាសនាមហាយាន គឺសាសនាដែល ឃ្លាតឆ្ងាយពីលទ្ធិដើមរបស់ពុទ្ធសាសនា ដូចជាពុទ្ធសាសនានៅប្រទេសចិន-ជប៉ុន-យួន ជាដើម ដែលគោរពរូបព្រះពោធិសត្វ អវលោកិតេស្វរៈ បានចូលមកប្រទេសនគរភ្នំទៀត។

ឃើញថា លក្ខណៈវប្បធម៌ខ្មែរ ផ្នែកទស្សនវិជ្ជា លទ្ធិជំនឿនេះ មានព្រំដែនកាន់តែ ធំទូលាយ ព្រោះបានជ្រើសរើស ដកស្រង់យកត្រង់ចំណុចសំខាន់ៗ ពីលទ្ធិទាំងនោះ មកកែសម្រួលបញ្ចូលមកក្នុងអារ្យធម៌ខ្មែរ។

ផ្នែកខាងសីលធម៌ (Moralité) មនុស្សធម៌ (Humanité) សុជីវធម៌ (Savoir-vive) ល្បែងកីឡា (Jeux-sport) និងទម្លាប់ទំនៀម (Moeurs et coutumes) ក៏មានទិន្នាការបែរទៅ តាមលទ្ធិ ជំនឿ ខាងព្រហ្មនិយមយ៉ាងច្រើនជាងពុទ្ធនិយមក្នុងសម័យនោះ ដោយអំណាច ព្រះមហាក្សត្រជាជាតិព្រាហ្មណ៍ បានយកលទ្ធិនេះមកកែសម្រួល បញ្ចូលក្នុងទម្លាប់ទំនៀម ខ្មែរប្រើជាផ្លូវការ មានប្រើក្នុងព្រះរាជពិធីជាដើម។

តាមឯកសារចិនថា[10] ប្រទេសចិនក៏មានការទាក់ទងក្រៅផ្លូវការជាមួយប្រទេសនគរភ្នំ ជាច្រើនរយឆ្នាំមុនគ.ស.មកហើយដែរ។ លុះដល់មកខាងដើមគ្រិស្តសតវត្សរ៍ទី ៣ សម័យ សាន់-គូ-ចេ ទើបព្រះចៅក្រុងចិន នាម វូ បានបញ្ជូនរាជទូត ២ រូប គឺលោក កាំង ថៃ និង ជូ យីង ឲ្យគាល់ព្រះមហាក្សត្រខ្មែរ។ ពេលនោះ រាជទូតចិន បានជួបគ្នានឹងរាជទូតឥណ្ឌា ឈ្មោះ ចិន សុង ដែលមកគាល់ព្រះមហាក្សត្រខ្មែរដែរ។

ឯលក្ខណៈវប្បធម៌ចិនក្នុងសម័យនោះ នៅខ្សោយជាងខ្មែរឆ្ងាយណាស់ ស្មើនឹងខ្មែរតែ លក្ខណៈសង្គមធម៌ ផ្នែកសេដ្ឋកិច្ច ធ្វើជំនួញដូរប៉ុណ្ណោះ ទើបក្នុងអារ្យធម៌ខ្មែរសម័យនោះ គ្មានវប្បធម៌ចិនឡើយ មានតែវប្បធម៌ខ្មែរ ចូលទៅជួយអារ្យធម៌ចិនវិញ គឺក្នុងគ្រិស្តសតវត្សរ៍ ទី ៥ ចិនបានពឹងពាក់ សុំអ្នកប្រាជ្ញខ្មែរឲ្យទៅជួយបកប្រែភាសាឲ្យ ព្រះចៅក្រុងចិន បានឲ្យសង់ការិយាល័យមួយ សម្រាប់អ្នកប្រាជ្ញខ្មែរធ្វើការ ឈ្មោះ «ហ្វូណន ក្វាង» ប្រែថា ការិយាល័យប្រទេសនគរភ្នំ នៅជាប់ឈ្មោះរហូតដល់សព្វថ្ងៃ។ អ្នកប្រាជ្ញខ្មែរបានទៅជួយ បកប្រែពាក្យវប្បធម៌ឲ្យចិនចំនួន ១៦ ឆ្នាំ ទើបត្រលប់មកវិញ។

[10] សុង ស៊ីវ ឃើញក្នុងឯកសារព្រះភិក្ខុ ប៉ាង-ខាត់។


www.elibraryofcambodia.org

ផ្នែកវិទ្យាសាស្ត្របច្ចេកទេស (Sciences-techniques) និងសិល្បៈ (Arts) ក៏បានចម្រើនលូតលាស់ មានការរីកកាន់តែមានគុណភាពខ្ពស់ឡើងៗជាដរាប។ ដូចខាងសិល្បៈស្ថាបត្យកម្ម និងចម្លាក់ក្បាច់ភ្ញី លម្អវិមាន ប្រាសាទ ក្នុងសម័យនោះប្រវត្តិវិទូបច្ចុប្បន្នបានចែកជា ៤ រចនាបថ (Style) គឺ ៖

១- ពីសតវត្សរ៍ទី ១ ដល់ទី ៦ ហៅថា រចនាបថភ្នំដា ដោយយកប្រាសាទភ្នំដា នៅអង្គរបុរី ក្នុងខេត្តតាកែវធ្វើជាគោល។

បុព្វបុរសខ្មែរ បានចោះភ្នំធ្វើប្រាសាទ និងធ្វើប្រាសាទតូចៗ ដាច់ៗពីគ្នា ក្រៅពីស្ថាបត្យកម្ម (Architecture) គេបានរកឃើញ គ្រឿងឧបករណ៍ និងអលង្ការជាច្រើនបែបដែលខ្មែរសម័យបុរេអង្គរបានធ្វើ វត្ថុទាំងអស់នេះ គេបានរកឃើញនៅមណ្ឌល អូ-កែវ កម្ពុជាក្រោម។

ឯរូបបដិមា ជាព្រះពុទ្ធរូប ទេវតា និងរូបបុរសស្ត្រី ដែលខ្មែរសម័យនោះបានធ្វើមានរាងមាំ សមល្អត្រឹមត្រូវតាមខ្នាត សុទ្ធតែមានទ្រនាប់ទម្រ និងទំនប់ទប់រូបនោះផង មានរាងកាច់ចង្កេះ ស្លៀកពាក់បែបឥណ្ឌា។

រចនាបថភ្នំដា ផ្នែកបដិមារូបនេះ មានច្រើនបែបគឺ បែបអមរាវតី គុប្ត គន្ធារៈ មថុរា ឬអជន្តា មានកេរ្តិ៍ឈ្មោះល្បីល្បាញណាស់ ផ្សាយទូទៅពេញផ្ទៃនគរភ្នំ ទិសខាងកើតទៅដល់ខាងត្បូងនៃវៀតណាមកណ្ដាលសព្វថ្ងៃ។ ខាងលិចទៅដល់ប្រទេសសៀមសព្វថ្ងៃ។ នៅមឿងជយា ក្នុងប្រទេសសៀម មានរូបបដិមា អវលោកិតេស្វរៈ បែបរចនាបថភ្នំដា ព្រះពុទ្ធរូបនៅនគររាជសីមា ក៏ជារចនាបថភ្នំដាដែរ។ ព្រះពុទ្ធរូបថ្មនៅវត្តរំលក ខេត្តតាកែវ ព្រះពុទ្ធរូបថ្មនៅត្រឹងទៀង ខេត្តលង់ហោ និងព្រះពុទ្ធរូបឈើនៅទឹកខ្មៅ ខេត្តព្រែកឫស្សីកម្ពុជាក្រោម ព្រះពុទ្ធរូបស់សំរិទ្ធិនៅវត្តបាណន់ ខេត្តបាត់ដំបង ព្រះពុទ្ធរូប ៣ អង្គទៀតដែលមានចារឹកពុទ្ធភាសិតភ្ជាប់ថា «យេ ធម៌ា» គឺ ១ អង្គនៅវត្តឈ្នះ ខេត្ត តាកែវ ១ អង្គនៅទួលព្រះធាតុ ខេត្តកំពង់ស្ពឺ និង ១ អង្គ ទៀតនៅត្រពាំងវែង ខេត្តព្រះត្រពាំង ។ល។ ព្រះពុទ្ធរូបទាំងអស់នេះ សុទ្ធតែរចនាបថភ្នំដា ផ្សាយចេញពីមជ្ឈមណ្ឌល បដិមារូបភ្នំដា នៅអង្គរបុរី។

២- ក្នុងសតវត្សរ៍ ទី ៧ ពី គ.ស. ៦១៦ ដល់ ៦៣៥ ក្នុងរជ្ជកាលស្ដេច ឦសានវរ្ម័នទី ១ ដែលមានរាជធានីឈ្មោះ ឦសានបុរៈ ក្នុងខេត្តកំពង់ធំសព្វថ្ងៃ។ សិល្បកម្មក្នុងសម័យនេះហៅថា រចនាបថសម្បូណ៌ ដោយយកប្រាសាទនៅសម្បូណ៌ព្រៃគុកជាគោល។


www.elibraryofcambodia.org

ក្នុងរចនាបថនេះ ច្រើនធ្វើប្រាសាទមានរាងតូចៗ ធ្វើពីឥដ្ឋ បូកកំបោរលាយស្អិត។ ឯផ្តែរ និងជើងទៀនធ្វើពីថ្មភក់។ ក្បាច់ផ្តែរ កណ្តាលមានដងធ្នូ លើដងធ្នូមានក្បាច់ផ្កាចន្ទន៍ បីទ្រូវរូបមនុស្ស គឺនៅកណ្តាល ១ និងនៅឆ្វេងស្តាំ ២ ខាងចុងឆ្វេងស្តាំ មានរូបមករហារមាត់ខាំដងធ្នូ ខាងក្រោមដងធ្នូ មានក្បាច់រំយោល ក្បាច់កម្រងជាងទង នៅចន្លោះក្បាច់ទាំង ២ នេះ មានរូបស្លឹកឈើតូចៗប្រកបផង។ ផ្តែរខ្លះមានរូបមនុស្ស នៅក្រោមដងធ្នូថែមទៀត។ ជើងទៀនរាងមូល ធ្វើពីថ្មភក់។ ហោជាងមានរាងក្រចកសេះ។ ផ្ទៃជញ្ជាំង លម្អដោយប្រាសាទតូចៗ។

ផ្នែករូបបដិមាក្នុងសម័យនោះ គេប្រទះឃើញរូបស្រ្តីមានរាងតូចៗ ត្រគាកធំសាយ ពាក់មកុដរាងមូល ភេទប្រុសមានរាងធំមាំ រូបទាំងនេះ មានទ្រនាប់ទម្រ ដូចក្នុងរចនាបថភ្នំដាដែរ។

៣- ក្នុងសតវត្សរ៍ទី ៧ ដដែល ពី គ.ស. ៦៥៥ ដល់ ៦៨១ ក្នុងរជ្ជកាលស្តេចជយវរ្ម័នទី ១ ដែលមានរាជធានីនៅអង្គរបុរី។ សិល្បកម្មក្នុងសម័យនេះ ហៅថា រចនាបថព្រៃក្មេង ដោយយកប្រាសាទព្រៃក្មេងជាគោល។

លក្ខណៈស្ថាបត្យកម្មក្នុងរចនាបថនេះ ប្រហែលគ្នាក្នុងរចនាបថសម្បូណ៌ដែរ ឃើញប្លែកត្រង់លើផ្តែរ ច្រើនប្រើក្បាច់ភ្ញីទេស គឺត្រង់ក្បាច់ផ្កាចន្ទន៍ ក្លាយជាក្បាច់ផ្កាឈូកបន្ទំ ឯសត្វមករនៅចុងធ្នូ ជាក្បាច់ខ្សែងហៀនជំនួសវិញ ជើងទៀនមានលម្អជាងរចនាបថសម្បូណ៌ ប៉ុន្តែនៅមានរាងមូលដដែលក្បាច់ជញ្ជាំងនៅដដែល។

ផ្នែករូបបដិមា ក្នុងរចនាបថព្រៃក្មេងនេះ ឃើញមានបច្ចេកទេសខ្ពង់ខ្ពស់ជាងសម័យមុន ដូចរូបបដិមាហរិហរៈ (ព្រះឥសូរ) នៅប្រាសាទអណ្តែត គេទុកជាស្នាដៃឯកបំផុតព្រោះចេះធ្វើមានរាងរៅសមល្អក្រៃលែង។

៤- ក្នុងសតវត្សរ៍ទី ៨ នៅសម័យចេនឡា បែកបាក់គ្នាជាពីរពួក។ សិល្បករក្នុងសម័យចេនឡា បែកបាក់គ្នាជាពីរពួក។ សិល្បករក្នុងសម័យនេះ ហៅថា រចនាបថកំពង់ព្រះ ដោយយកប្រាសាទកំពង់ព្រះជាគោល។

លក្ខណៈស្ថាបត្យកម្ម ក្នុងរចនាបថនេះ ឃើញប្លែកត្រង់ចេះធ្វើច្រើនជាន់ មានថ្នាក់ៗ រាងដូចចេតិយ មានប្រាសាទអកយំជាគំរូ ឯជើងទៀនខ្លះមានរាង ៨ ជ្រុង មានក្បាច់ស្លឹកឈើនៅលើជើងទៀនផង។

ផ្នែករូបបដិមា ឃើញប្លែកត្រង់បំបាត់ទ្រនាប់ទម្រ និងទំនប់ទប់រូបដូចមុនៗចោល ហើយ មានការវិវត្តវិសេសជាងមុន។


www.elibraryofcambodia.org

វិទ្យាសាស្ត្រ បច្ចេសទេស និងសិល្បៈ ក្នុងសម័យបុរេអង្គរនេះ ឃើញថា ចេះតែចម្រើនឡើងជាលំដាប់ តាមលក្ខណៈខ្មែរ ទោះបីបានដកស្រង់ខ្លះយកពីវប្បធម៌ឥណ្ឌា ក៏គ្រាន់តែយកជាគោលគំនិតប៉ុណ្ណោះ បុព្វបុរសខ្មែរ មិនចេះធ្វើសេកសាលិកា ថាគ្រាប់ធ្វើគ្រាប់ តាមនរណាឡើយ អាស្រ័យ ហេតុនេះហើយ ទើបអ្វីៗដែលជារបស់ខ្មែរ សុទ្ធតែជាវត្ថុប្លែកអស្ចារ្យទាំងអស់ តួយ៉ាងដូចប្រាសាទខ្មែរ និងប្រាសាទឥណ្ឌាឃើញខុសគ្នាឆ្ងាយណាស់ ខុសទាំងក្បាច់ ខុសទាំងរាង ខុសទាំងលម្អ ។ល។

នេះជាជំនូន្មានប្រសើរបំផុតកាត់ថ្លៃមិនបាន សម្រាប់ជាតិខ្មែរ ដែលបុព្វបុរសខ្មែរ បានប្រដៅទុកឲ្យខ្មែរជំនាន់ក្រោយធ្វើតាមលោក កុំឲ្យមានការវង្វេងងុបងុល ទៅតាមអារ្យធម៌បរទេស ត្រូវតែមានសម្បជញ្ញជាតិ (Conscience nationale) ជានិច្ចគ្រប់ករណីយកិច្ចខ្មែរ។

ផ្នែកភាសា ភាសាខ្មែរក្នុងសម័យបុរេអង្គរនេះ មានភាសាល្បាយ ដែលក្លាយមកពីភាសាសំស្ក្រឹតចូលមកក្នុងនិឃន្តសាស្ត្រ ខ្មែរ គឺអត្ថរបស់វាក្យសព្ទ (Vocabulaire) កាន់តែច្រើន ហើយដោយសារអនុប្រភពឥណ្ឌា ដែលចូលមកតាមពុទ្ធសាសនា តាមព្រហ្មញ្ញសាសនា និងតាមនយោបាយរដ្ឋក្នុងសម័យនោះ។

ត្រង់ចំណុចនេះ ពិតជាមានអ្នកអានខ្លះឆ្ងល់ថា បើមានពុទ្ធសាសនាថេរវាទចូលមកច្រើនរយឆ្នាំមុន គ.ស. ហើយម៉េចក៏មិនមានភាសាបាលីផង?

ចម្ងល់នេះ មានអាថ៌កំបាំងកប់ជ្រៅបន្តិច មកពីយើងធ្លាប់ដឹងថា ពុទ្ធសាសនាថេរវាទសុទ្ធតែប្រើភាសាបាលី តាមពិតមិនមែនដូច្នោះទេ ក្នុងឯកសារ និងសិលាចារឹកផ្សេងៗប្រាប់ថា ពុទ្ធសាសនាថេរវាទក្នុងកាលនោះ និយមប្រើភាសាសំស្ក្រឹតដែរ ព្រោះភាសាសំស្ក្រឹតនិងបាលីនេះ មិនមែនប្លែកគ្នាឆ្ងាយ ដូចភាសាដទៃៗឡើយ។ ក្នុងគ្រិស្តសតវត្សរ៍ទី ៣ មានពុទ្ធសាសនាថេរវាទមួយឈ្មោះនិកាយ «មូលសព្វាស្តិវាទិន» បានចូលមកប្រទេសខ្មែរទៀត ក៏ប្រើភាសាសំស្ក្រឹតដែរ[11]។ លុះដល់មកខាងដើមសម័យអង្គរហើយ ក៏នៅតែមានពុទ្ធសាសនាថេរវាទ ប្រើភាសាសំស្ក្រឹតទៀត ព្រោះនៅប្រទេសឥណ្ឌា សម័យគតិយសង្គាយនា ព្រះបាទធម្មាសោកទង់ប្រើភាសាប្រាក្រឹតមាគធីជាគ្រាមភាសា។ ឯភាសាបាលីព្រះត្រៃបិដក និងអដ្ឋកថាដូចសព្វថ្ងៃនេះ កើតឡើងក្នុងសម័យព្រះពុទ្ធឃោសាមុន គ.ស. ២៤ ឆ្នាំ ឃើញថា ទើបនឹងកើតក្រោយពេលសមណទូត ដែលព្រះបាទធម្មាសោក

[11] G. Gcedè, Histoire ancienne d'Etas hindouisés d'Extrême orient R.74


www.elibraryofcambodia.org

បញ្ជូនមកក្រោយពេលសមណទូត ដែលព្រះបាទធម្មាសោក បញ្ជូនមកសុវណ្ណភូមិយើង កាលពី ៣០៩ ឆ្នាំ មុន គ.ស. នោះឆ្ងាយណាស់។

អាស្រ័យហេតុនេះហើយ ទើបក្នុងភាសាខ្មែរចាប់ពីសម័យបុរេអង្គរមក មានភាសាល្បាយ ដែលក្លាយជាសំស្ក្រឹតច្រើនណាស់ផ្នែកនិយន្តសាស្ត្រ។ ប៉ុន្តែគួរឲ្យកោតសរសើរយ៉ាងក្រៃលែង ចំពោះសម្បជញ្ញជាតិ និងការប៉ិនប្រសប់របស់បុព្វបុរសខ្មែរ លោកបានយកពាក្យសំស្ក្រឹតមកជប់បង្កើតជាពាក្យខ្មែរ ធ្វើឲ្យអ្នកចេះសំស្ក្រឹតស្ដាប់លែងដឹងថា សំស្ក្រឹតគឺយកពាក្យសំស្ក្រឹតមកឈូស កោស លុបជ្រុង ឆ្នៃបញ្ចូលក្នុងពុម្ពនិយន្តសាស្ត្រខ្មែរ ពង្រីកវិសាលភាពពាក្យខ្មែរ ឲ្យមានព្រំដែនធំទូលាយ សម្រាប់អារ្យជនប្រើ ដូចនាំភស្តុតាងមកបន្តិចខាងក្រោមនេះ ៖...

(បាត់ ២ ទំព័រ)

CAMBODIAN • EDUCATION • EXCELLENCE
មូលនិធិខ្មែរសម្រាប់ការសិក្សា
FOUNDATION



www.elibraryofcambodia.org

...គ្រប់ភាសាទាំងអស់ដែលមានក្នុងលោក ផ្ទុយទៅវិញ មានភាសារបស់ជនជាតិជាច្រើនក្នុងលោក ដែលខំបញ្ចេញសំឡេងថាតាមភាសាខ្មែរមិនកើត ជាពិសេស ចំពោះពាក្យខ្មែរដែលមានសំឡេង រ និង ល ដូចជា «អំបិល អំពិល» ខំថាតាមខ្មែរ បានត្រឹមតែ «អំបិន អំពិន» «ស្លឹកគ្រៃ ជាស្លឹកគ្រៃ រលំ ជាលលំ ឆ្នាំង ជា ស្នាំង ផ្លូវ ជាផ្លូវលូវ ស្រួល ជាស៊ហួរ តិះដៀល ជាទិតៀន ជំនាញ ជា ចាំណាន កលជាកុន» ។ល។

ផ្នែករូបសាស្ត្រខ្មែរ = រឹតតែមានឥទ្ធិពលណាស់ទៅទៀត មានរូបរស់រវើក មិនតាំងស្លាប់នៅមួយកន្លែង ដូចភាសារបស់ជនជាតិភាគច្រើនក្នុងលោកឡើយ ជាភាសាមានមន្តសិល្ប៍ ចេះជបប្រែកាឡាបង្កើនពាក្យពេចន៍បាន តាមបបូមាត់ខ្មែរ ដូចឧទាហរណ៍ខ្លះខាងក្រោមនេះ ៖

ចំពោះពាក្យជាកិរិយាស័ព្ទ ឬគុណសព្ទ អាចប្រែកាឡាទៅនាមសព្ទ ជាករណនាម ជាការកនាម មានន័យមានសំឡេងផ្សេងៗ និងកិរិយាស័ព្ទជាកត្តុវាចកៈ ប្រែកាឡាទៅជាហេតុកត្តុវាចកៈ បានភ្លាមៗឆាប់រហ័ស ស្មើនឹងសន្ទុះចិត្តខ្មែរដូចជា ៖

កល់ > កំណល់ > ខ្នល់ កាន់ > កំណាន់ > ខ្នាន់ កើត > កំណើត > ខ្នើត ធំ > ទំហំ តូច > តំណូច ទាប > ទំនាប អាច > អំណាច ខ្វាត់ > កម្វាត់ ខ្វាយ > កម្វាយ ស្រោច > សម្រោច ។ល។

ផ្នែកអក្សរសាស្ត្រ (Littérature) ក្នុងសម័យបុរេអង្គរនេះ អក្សរសាស្ត្រខ្មែរបានចម្រើនជាងសម័យបុរេប្រវត្តិយ៉ាងច្រើន ព្រោះបានចេះដឹងនូវចំណេះវិជ្ជា និងគោលមតិទូទៅយ៉ាងច្រើន ហើយផ្សាយតាមការនិទាន តាមការសម្តែងកាយវិការ តាមអក្សរក្បួនច្បាប់ និងតាមការបង្ហាត់បង្ហាញផ្ទាល់មាត់ ពលរដ្ឋក្នុងសម័យនោះ មានការចេះដឹងច្រើនដរាបដល់មហាប្រទេសចិន ក៏បានពឹងពាក់ខ្មែរខាងអក្សរសាស្ត្រនេះដែរ។

ខាងវណ្ណៈអក្សរ (Ecriture) ក្នុងសម័យបុរេអង្គរដូចបាននិយាយក្នុងសម័យបុរេប្រវត្តិច្រើនពាន់ឆ្នាំមុន គ.ស. នោះ ថា ប្រហែលជាខ្មែរមានវណ្ណៈអក្សរប្រើហើយ ទើបខ្មែរចេះគូរយ័ន សាក់លើខ្លួនមនុស្សបាន ប៉ុន្តែគ្មានភស្តុតាងជាឯកសារ ឬសិលាចារឹកនៅសល់សោះ ព្រោះច្រើនពាន់ឆ្នាំណាស់មកហើយ ប្រហែលបុព្វបុរសខ្មែរសម័យនោះ ប្រើសក្តិលេខ (Hierographie) គឺប្រើរូបផ្សេងៗជាអក្សរដូចបុព្វជនអេហ្ស៊ីបដែរ។

លុះដល់មកសម័យបុរេអង្គរនេះ ទើបមានភស្តុតាងគឺសិលាចារឹក វ៉ូ-កាញ់ ក្នុងខេត្តញ៉ាត្រាង ប្រទេសវៀតណាមដែលជាទឹកដីខ្មែរជាដើម។ សិលាចារឹកនេះក៏គ្មានកាលបរិច្ឆេទទៀត រលុបបាត់អស់ទៅ មិនដឹងជាបុព្វបុរសខ្មែរឆ្លាក់ពី គ.ស. ទីប៉ុន្មាន


www.elibraryofcambodia.org

គ្រាន់តែដឹងថា ក្នុងរាជ្យស្តេច ស្រី មារ គឺស្តេច ហ្វាន់-ម៉ន ប្រហែលខាងចុងគ្រិស្តសតវត្សរ៍ទី ២។

អក្សរសិលាចារឹក វ៉ូ-កាញ់ នេះ ទុកជាអក្សរដំបូងបំផុត ក្នុងប្រវត្តិសាស្ត្រខ្មែរ គិតមកដល់សព្វថ្ងៃនេះមានអាយុ ១៨០០ ឆ្នាំហើយ។ អក្សរនោះមានទម្រង់ដូចអក្សរឥណ្ឌាខាងទក្ខិណាបថ របស់ស្តេចរុទ្រទាម័ន។

អាស្រ័យហេតុនេះ ទើបអ្នកប្រាជ្ញខាងអក្សរ សន្មតថា ដើមកំណើតអក្សរខ្មែរបែបសព្វថ្ងៃ ចេញមកពីប្រទេសឥណ្ឌា ខាងទក្ខិណាបថ ព្រោះក្នុងគ្រិស្តសតវត្សរ៍ ទី ១ ទី ២ ខ្មែរមានការទាក់ទងគ្នាយ៉ាងជិតស្និទ្ធ នឹងប្រទេសឥណ្ឌាខាងទក្ខិណាបថនេះឯង បានទទួលអក្សរគ្រប់បែប គឺអក្សរសម័យរាជវង្សបល្លវៈ និងចាលុក្យៈ យកមករចនាធ្វើជាអក្សរខ្មែរតាមទេពកោសល្យរបស់ខ្មែរ។

ជាពិសេស អក្សរក្នុងសម័យរាជវង្សទាំង ២ នេះឯងជាដើមកំណើតអក្សរនៅទ្វីបអាស៊ីភាគអាគ្នេយ៍ បានដល់ដើមកំណើតអក្សរលង្កា ឥណ្ឌូនេស៊ី មន គឺភូមាសព្វថ្ងៃ ខ្មែរនិងចាម។ អក្សរខ្មែរបានបង្កើតនូវអក្សរសៀមនិងលាវទៀត។

ក្នុងសម័យបុរេអង្គរ ចាប់ពីគ្រិស្តសតវត្សរ៍ទី ១ ដល់ទី ៨ ឃើញមានអក្សរសិលាចារឹកជាច្រើនកន្លែង ជាភាសាសំស្ក្រឹតក៏មាន ជាភាសាខ្មែរក៏មាន ដូចដក់ស្រង់មកខ្លះខាងក្រោមនេះ ៖

សិលាចារឹក វ៉ូកាញ់ (ខេត្តញ៉ាត្រាង) គ.វ. ទី ២ ភាសាសំស្ក្រឹត

,, អ្នកតាដំបងដែក (ខេត្តតាកែវ) ,, ៥ ,, សំស្ក្រឹត

,, ប្រាសាទ ៥ ល្វែង (ខេត្តព្រៃកប្បាស្ស៊ី) ,, ៥ ,, សំស្ក្រឹត

,, ភ្នំហាន់ជ័យ (ខេត្តកំពង់ចាម) ,, ៦ ,, សំស្ក្រឹត

,, ប្រាសាទតាព្រហ្ម (ទន្លេបាទី តាកែវ) ,, ៦ ,, សំស្ក្រឹត

,, វត្តប្រាសាទ (ខេត្តព្រៃវែង) ,, ៦ ,, ខ្មែរ

,, វត្តគំនូរ (អង្គរបុរី តាកែវ) ,, ៧ ,, ខ្មែរ

,, សម្បូណ៌ព្រៃគុក (ខេត្តកំពង់ធំ) ,, ៧ ,, ខ្មែរ-សំស្ក្រឹត

សិលាចារឹក វ៉ូកាញ់ (ខេត្តញ៉ាត្រាង) គ.វ. ទី ២ ភាសាសំស្ក្រឹត

,, ខាវណ្ណាយ (អរញ្ញប្រទេសថៃ) ,, ៧ ,, ខ្មែរ-សំស្ក្រឹត

,, ខាវរាំង (អរញ្ញប្រទេសថៃ) ,, ៧ ,, ខ្មែរ-សំស្ក្រឹត

,, វត្តព្រៃវៀរ (ខេត្តព្រៃវែង) ,, ៧ ,, ខ្មែរ-សំស្ក្រឹត


www.elibraryofcambodia.org

,, ប្រាសាទតាកៀម (ខេត្តសៀមរាប) ,, ៨ ,, ខ្មែរ-សំស្ក្រឹត

នៅមានសិលាចារឹកជាច្រើនទៀត ដែលកើតមានក្នុងសម័យនេះ។

ចំនួនសិលាចារឹកប៉ុណ្ណោះជាដើម បញ្ជាក់ឲ្យឃើញថា អារ្យធម៌ខ្មែរសម័យបុរេអង្គរ បានចម្រើនលូតលាស់គ្រប់វិស័យមានភាសាអក្សរសម្រាប់ប្រើ មិនចាញ់អារ្យធម៌បរទេសធំៗក្នុងលោកឡើយ។

ផ្នែកការសិក្សា-អប់រំ (Enseignement-Education) តាមឯកសារ និងសិលាចារឹកនានា មានឯកសារចិនជាដើម បានប្រាប់ឲ្យដឹងថា ការសិក្សាអប់រំក្នុងសម័យបុរេអង្គរនេះ មានកម្រិតវិជ្ជាខ្ពង់ខ្ពស់ ហើយមានសាស្ត្រាចារ្យមានគ្រូខ្មែរ ឥណ្ឌា ដែលមានចំណេះវិជ្ជាខ្ពង់ខ្ពស់ ជាអ្នកបង្ហាត់បង្រៀនយុវជនខ្មែរ។

ក្នុងសិលាចារឹកមួយនៅសម្បូណ៌ព្រៃគុក ខេត្តកំពង់ធំ ប្រាប់ថា មានព្រាហ្មណ៍ម្នាក់ឈ្មោះ បាសុបតៈ ងារជាវិទ្យាវិសេសៈជាអ្នកប្រាជ្ញធំ មានវិជ្ជាខ្ពង់ខ្ពស់ ដែលស្តេចភវវរ្ម័នទី ១ សព្វព្រះទ័យយកធ្វើជាគ្រូ និងឲ្យបង្រៀនវិជ្ជាផ្សេងៗដល់ពលរដ្ឋខ្មែរក្នុងសម័យនោះ។

ចំពោះការសិក្សា-អប់រំខាងវិជ្ជាបច្ចេកទេស មានបច្ចេកទេសខាងសិល្បៈចម្លាក់ប៉ាន់រូបជាដើម ក្នុងសម័យនោះមានដល់ទៅមហាវិទ្យាល័យ សម្រាប់បង្រៀនផង។ លោក ឱយ-ប៉ុង បានរកឃើញថា នៅភ្នំដា ត្រង់អង្គរបុរី ខេត្តតាកែវ គឺជាមជ្ឈមណ្ឌលនៃមហាវិទ្យាល័យខាងរូបបដិមាផ្សេងៗ ដែលមានល្បីឈ្មោះយ៉ាងសម្បើម។ ឯបច្ចេកទេសខាងរ៉ែ ក៏ខ្មែរចេះរក ចេះជីកយក មាស-ស្ពាន់-សំណ-ដែក-ពេជ្រ-និលចិន្តា ។ល។ បានដោយខ្លួនឯង។

ចំពោះការសិក្សា-អប់រំខាងវិជ្ជាយុទ្ធសាស្ត្រ ក្នុងសម័យបុរេអង្គរ បានឡើងដល់ថ្នាក់កំពូល ប្រទេសជិតខាងខ្លបខ្លាច សេនានុភាពកងទ័ពខ្មែរណាស់ មិនហ៊ានប្រឆាំងតបតឡើយ។ ខាងកងទ័ពជើងគោក មានទ័ពសេះ ទ័ពដំរី ទ័ពរថ ទ័ពថ្មើរជើងយ៉ាងច្រើន សុទ្ធតែបានសិក្សា អប់រំដោយវិជ្ជាយុទ្ធសាស្ត្រស្ទាត់ជំនាញ។ ខាងជើងទឹក បានសាងនាវាចម្បាំងធំៗ មាននាវិកសុទ្ធតែស្ទាត់ជំនាញ ក្នុងយុទ្ធវិធីខាងជលមាគ៌ា។

ក្នុងឯកសារចិនប្រាប់ថា ស្តេច ហ៊ុន-ទៀន ព្រះនាង លៀវ-យី មានព្រះរាជបុត្រតែមួយព្រះអង្គ មានប្រទេសចំណុះ ៧ ប្រទេស បានចាត់ព្រះរាជបុត្រឲ្យទៅត្រួសត្រាប្រទេសទាំង ៧ នោះ។


www.elibraryofcambodia.org

តមក ស្តេច ហ្វូន-ប៊ុន-ហ្វូង ជាតំណាងព្រះរាជវង្សបានចាត់ព្រះរាជបុត្រ ព្រះរាជនត្តា ឲ្យទៅត្រួតត្រាយ ប្រទេសចំណុះទាំង ៨ នោះតៗមកទៀត។ ក្នុងគ្រិស្តសតវត្សរ៍ទី ២ ព្រះរាជបុត្រទី ២ របស់ ស្តេច ហ្វូន-ប៊ុន-ហ្វូង ព្រះនាម ប៊ុន-ប៊ុន បានឡើងសោយរាជ្យ បានតាំងនាយទាហានម្នាក់ឈ្មោះ ហ្វាន់-ម៉ុន ឲ្យឡើងជាឧត្តមសេនីយ ត្រួតត្រាទ័ពថ្វាយ។ លុះព្រះអង្គទីវង្គតទៅ ឧត្តមសេនីយនេះបានឡើងសោយរាជ្យ មាននាមថា ស្តេច ហ្វាន់-ម៉ុន ឬស្រីមារ ដែលមានព្រះនាមក្នុងសិលាចារឹក វ៉ូ-កាញ់ នោះឯង។

ព្រះរាជាអង្គនេះ មានការសិក្សា-អប់រំខាងវិជ្ជាយុទ្ធសាស្ត្រខ្ពង់ខ្ពស់បំផុត ជាព្រះរាជាក្លាហានឈ្លាសវៃណាស់ បានឡើងឋានៈជាមហារាជាធិរាជនៃប្រទេសនគរភ្នំ ទ្រង់បញ្ជាឲ្យសាងរាជនាវាចម្បាំងធំៗសម្បើម លើកសេនាន្យនុភាពឆ្លងមហាសាគរទៅយកប្រទេសនានា មកធ្វើចំណុះបាន ១០ ប្រទេសទៀត រួមជា ១៧ ប្រទេស ឲ្យស្ថិតនៅក្រោមការត្រួតត្រារបស់ប្រទេសខ្មែរក្នុងសម័យនោះ។

**អំពីលក្ខណៈសង្គមធម៌** = ខាងសេដ្ឋកិច្ច (Economie) ក៏បានចម្រើនណាស់ដែរ ក្នុងឯកសារចិនថា ខ្មែរ ហ្វូណន ប៉ិនប្រសប់រកស៊ីណាស់ មានចិត្តទៀងត្រង់ មិនចេះរបិញរបុញបោកបញ្ឆោត មិនចេះលួចកេងកិប ចេះស្គាល់ កន្លែងជីកយកមាស ប្រាក់ ពេជ្រ និងត្បូងផ្សេងៗ ចេះស្ល កែវធ្វើប្រដាប់ប្រើប្រាស់ ចេះធ្វើសំពៅធំៗមានក្បាលកន្សៃ ខ្ពស់ងផុតពីទឹក និងប៉ិនប្រសប់ធ្វើកសិកម្មណាស់ ក្នុង ១ ឆ្នាំ ព្រោះស្រូវតែម្តង ច្រូតកាត់បាន ៣ រដូវ ព្វកែធ្វើនយោបាយទឹក មានជីកព្រែកខ្វាត់ខ្វែង ត្រង់ខេត្តក្រមូនស បាសាក់ ព្រះត្រពាំង ស្វាយទង ទ្រាំង នៅមានដល់សព្វថ្ងៃ។ ផ្នែកពាណិជ្ជកម្មក្រៅប្រទេសបានចម្រើនជាងសម័យបុរេប្រវត្តិ បានរៀបចំកំពង់ផែ អូកែវ ក្នុងខេត្តកក្រមូនសសព្វថ្ងៃ ជាកំពង់ផែពាណិជ្ជកម្មអន្តរជាតិ មានសំពៅធំៗចេញចូល មានពាណិជ្ជករ ឥណ្ឌា-ចិន នាំទំនិញមកលក់ដូរនៅប្រទេសនគរភ្នំ ហើយបានទិញផលិតផលខ្មែរ ដូចគ្រឿងទេស មាស ប្រាក់ ភ្លុកជាដើម យកទៅលក់ដូរប្រទេសខ្លួនវិញ។ ពាណិជ្ជករខ្មែរបាននាំទំនិញទៅលក់នៅប្រទេសចំណុះទាំង ១៧ និងទៅលក់ដល់ប្រទេសឥណ្ឌា ចិន ដល់ក្រុងកង់តុង ហើយដឹកនាំយកទំនិញបរទេសមកលក់ក្នុងប្រទេសខ្លួនវិញ។

ខាងសង្គមកិច្ច ក៏បានរៀបចំប្រសើរណាស់ដែរ ព្រោះជាប្រទេសមានភោគទ្រព្យច្រើន ដោយពួកប្រទេសចំណុះ បាននាំសួយអាករ មកផ្តល់ឲ្យជាច្រើនក្នុងមួយឆ្នាំៗ។ នៅក្នុងក្រុងមួយៗ មានផ្លូវគមនាគមន៍ មានស្ពាន មានសាលារៀន ផ្ទះពេទ្យ និងសាលាសំណាក់ជាដើម។ ឯកសារចិនថា ខ្មែរហ្វូណន ចូលចិត្តសង់ផ្ទះខ្ពស់ៗពីដី


www.elibraryofcambodia.org

ប្រក់ស្លឹកឈើម្យ៉ាង ដែលក្រងជាកណ្ដាបយ៉ាងល្អ នៅខាងមុខផ្ទះច្រើនមានឆ្លាក់ក្បាច់ជាលម្អផង ក្នុងភូមិមួយៗ មានផ្ទះប្រហែល ៥០ ឬ ៦០ ខ្នង សង់នៅជិតៗគ្នា មានជីកស្រះ ត្រពាំង អណ្ដូងទឹកគ្រប់ភូមិ សម្រាប់ប្រើរួមគ្នា។

ផ្នែកសង្គមរចនាសម្ពន្ធ= ខាងវណ្ណវិភាគ (Division sociale) ការចែកឋានៈមនុស្សក្នុងសង្គមជាតិ សង្គមខ្មែរយើងក្នុងសម័យបុរេប្រវត្តិ និងក្នុងរាជស្ដេច ហ៊ុន-ទៀន ព្រះនាងលៀវ-យី គ្រាន់តែចែកឋានៈមនុស្ស ទៅតាមសមត្ថភាពចំពោះវិជ្ជា ជាដើមប៉ុណ្ណោះ ដល់មករជ្ជកាលស្ដេចសីមារ (ហ្វាន់ ម៉ុន) ក្នុងគ្រិស្តសតវត្សរ៍ ទី ២ ទើបមានការចែកឋានៈមនុស្ស ក្នុងសង្គមខ្មែរជា ៤ វណ្ណៈតាមឥណ្ឌាគឺ ៖

១- ខត្តិយៈ ជាត្រកូលអ្នកចម្បាំងនិងសាងនគរ

២- ព្រហ្មណៈ ជាត្រកូលអ្នកធ្វើគ្រូបង្រៀនស្ដេចនិងរាស្ត្រ

៣- វេស្សៈ ជាត្រកូលអ្នកជំនួញ អ្នកធ្វើស្រែ

៤- សូទ្រៈ ជាត្រកូលអ្នកស៊ីឈ្នួលបម្រើគេ។

ត្រកូលទាំង ៤ នេះ មានឋានៈខ្ពស់ទាបឆ្ងាយណាស់ចូលរួមភាជនៈបាយទឹក យកគ្នាជាប្ដីប្រពន្ធខុសវណ្ណៈគ្នាមិនបាន។ ត្រឹមរាជ្យនេះឯង សម័យសក្តិភូមិដ៏អាក្រក់ មនុស្សជិះជាន់មនុស្សក៏ចាប់កើតឡើងក្នុងសង្គមខ្មែរ ដែលធ្លាប់មានលទ្ធិប្រជាធិបតេយ្យ សមភាព សេរីភាព តាំងពីសម័យបុរេប្រវត្តិមក។

លក្ខណៈសង្គមធម៌ និងលក្ខណៈវប្បធម៌ក្នុងសម័យបុរេអង្គរនេះ បានចម្រើនលូតលាស់ប្រហាក់ប្រហែលនឹងសម័យអង្គរដែរ ដូចពង្សាវតារសង្ខេប ដែលព្រះភិក្ខុ ប៉ាង ខាត់ បានដកស្រង់ពីសិលាចារឹក ពី ឯកសារផ្សេងៗមករៀបរាប់ថា ៖

ព្រះរាជាណាចក្រនគរភ្នំ តាំងនៅនឹងឆ្នេរសមុទ្រមួយធំ មានក្រុងច្រើន សុទ្ធសឹងព័ទ្ធជុំវិញដោយកំពែង មានប្រសាទរាជដ្ឋានល្អប្រកបដោយជាន់ មានគេហដ្ឋានច្រើន។ លើដីមានព្រៃព្រឹក្សា គ្រឿងទេស មានសត្វទឹក សត្វគោក ដូចបក្សី ក្ងោក ចរចាទ សេក ៥ ពណ៌ ក្នុងដីមាន មាស ស្ពាន់ សំណ ដែក មិនមានអ្វីខ្វះឡើយ មានសម្បត្តិប្រទេសដែលរកបានដោយកម្រ ដូច មាស ពេជ្រ និលចិន្ដា គុជ ជាដើម មានដើមអំពៅ ក្រទឹម ក្រូចពោធិ៍សាត់ ដើមស្លា ដូង។ ប្រជាជនសម្បុរខ្មៅស្រអែម សក់រួញ ប្រជុំភូមិមួយមានអណ្ដូងទឹក ១ រកស៊ីធ្វើស្រែចម្ការ ត្បាញ រវៃ អម្បោះ សូត្រ ចេះសិល្បៈឆ្លាក់ក្បាច់រចនាធ្វើចិញ្ចៀន កងកណ្ដៃ ខ្សែកណ្ដៃ ខ្សែដៃ កងជើង មានចានប្រាក់សម្រាប់ប្រើប្រាស់ យក មាស


www.elibraryofcambodia.org

ប្រាក់ គុជ គ្រឿងក្រអូប បង់ពន្ធដារ មានក្បួនតម្រា មានមន្ទីរឯកសារ សរសេរអក្សរវាង
បែបឥណ្ឌា ។ល។

(ចប់អារ្យធម៌ខ្មែរសម័យបុរេអង្គរ)

**១០៨**


www.elibraryofcambodia.org

# អារ្យធម៌ខ្មែរសម័យអង្គរ
## អនុប្រភពឥណ្ឌា-ចិន
(ពី គ.វ. ទី ៩ ដល់ផុត គ.វ. ទី ១៥)

ក្នុងរយៈកាលដ៏វែង ជាង ៦ សតវត្សរ៍ តពីសម័យបុរេអង្គរនោះមក អារ្យធម៌ខ្មែររឹតតែចម្រើនលូតលាស់ជាលំដាប់ ដរាបដល់ថ្នាក់កំពូល ប្រទេសខ្មែរ កើតជាប្រទេសមហាអំណាចមួយ ក្នុងទ្វីបអាស៊ីភាគអាគ្នេយ៍។

អារ្យធម៌ក្នុងសម័យនេះ ចាប់និយាយពីរាជ្យស្តេច ជ័យវរ្ម័នទី ២ រហូតផុតវង្សវរ្ម័ន។

ស្តេចជ័យវរ្ម័នទី ២ សោយរាជ្យក្នុង គ.ស. ៨០២ ទ្រង់សព្វព្រះទ័យរៀបពិធីតាំងព្រះរាជធានីថ្មី នៅលើភ្នំគូលែន ទ្រង់ឲ្យរៀបហោមពិធីប្រកាសឯករាជ្យប្រទេសខ្មែរ ធ្វើព្រះរាជាឲ្យជាព្រះរាជចក្រវិតិន (ស្តេចចក្រពត្តិ) ប្រសិទ្ធិទេពតាហរិហារៈ ដែលជាទេពតារក្សារាជ្យ ឲ្យមានកិត្តិយស ជាកម្រតេង ជគិត តរាជា (ទេវរាជ)។

ព្រះរាជាអង្គនេះឯង ដែលបានតាំងខ្លួនជាព្រះអាទិទេពរបស់ប្រជាជនខ្មែរមុនដំបូងបំផុត ស្តេចយាងទៅទីណាៗបានឲ្យគេយកទេវរូបទៅតាមជាមួយផង ដើម្បីឲ្យប្រជាជនជឿគោរពថាព្រះអង្គ គឺជាទេវរាជមួយអង្គ អ្នកដទៃល្មើសមិនបាន។

ប៉ុន្តែព្រះរាជាអង្គនេះ បរិបូណ៌ដោយសម្បជញ្ញជាតិណាស់ ទើបប្រទេសខ្មែរចេះតែចម្រើនឡើងជាលំដាប់។

ចាប់ពីរាជ្យព្រះអង្គមក អារ្យធម៌ខ្មែរទាំង ៤ ប្រភេទ ចេះតែចម្រើនឡើងតាមលំនាំមុនជាលំដាប់ ដែលប្លែកគួរឲ្យនាំយកមកនិយាយនោះ គឺអារ្យធម៌ប្រភេទទី ៣ និងទី ៤ ត្រង់របៀបលម្អភេទបុរសស្ត្រី និងលក្ខណៈវប្បធម៌ខ្លះ លក្ខណៈសង្គមធម៌ខ្លះ ដូចខាងក្រោមនេះ។

អារ្យធម៌ប្រភេទទី ៣ គឺលិង្គៈ ភេទសមរម្យតាមបែបបទបុរសស្ត្រី ក្នុងសម័យអង្គរ បុព្វបុរសខ្មែរ បានរចនាភេទទាំងពីរនេះ ប្រកបដោយវឌ្ឍនភាពខ្ពង់ខ្ពស់ ជឿនលឿនបំផុតដល់ថ្នាក់កំពូលក្នុងលោក សូម្បីតែក្នុងសម័យឋាន ព្រះចន្ទនេះ ដែលមានអារ្យប្រទេសខ្លះខំនាំគ្នាស្រាតនននលតកនោះ ក៏តាមមិនទាន់ដែរ។

បុព្វបុរសខ្មែរសម័យអង្គរ លោកមិនស្រាតនននលតកឡើយ លោកបានរចនាភេទបុរសស្ត្រី តាមសិល្បៈមួយហៅថា សម្ផស្សសិល្បៈ (Art charnel) គឺសិល្បៈបញ្ចេញសម្ផស្សរូបរាង សាច់មនុស្សជាលម្អ នាំឲ្យមានសម្រើបចិត្ត។


www.elibraryofcambodia.org

លម្អខាងភេទស្ត្រី មានរូបទេពអប្សរ ដែលលោកបានឆ្លាក់ភ្ជាប់នៅជញ្ជាំងប្រាសាទអង្គរជាច្រើនពាន់រូប ប្លែកពីគ្នាជាច្រើនបែប ទុកជាភស្តុតាងឲ្យយើងស្គាល់អារ្យធម៌ប្រភេទទី ៣ សម័យអង្គរ គឺស្ត្រីច្រើនស្លៀកសំពត់ផ្កាស្តើងៗ គ្មានផ្នត់មានទម្លាក់ជាយទាំងពីរចុះក្រោម ម្ខាងធំ ម្ខាងតូច របៀបស្លៀកខិតចុះក្រោម បញ្ចេញផ្ចិត បញ្ចេញក្បាលពោះឲ្យមើលឃើញលក្ខណៈលម្អរបស់ស្ត្រីជាក់ច្បាស់នឹងភ្នែក។ ផ្នែកខាងលើមនិពាក់អាវឡើយ គ្រាន់តែមានគ្រឿងអលង្ការពាក់សំយុងមកក្នុងទីជិតដោះ ដើម្បីបញ្ចេញសាច់ខ្នង សាច់កញ្ចឹងក និងសាច់ដោះឲ្យឃើញច្បាស់ក៏មាន ខ្លះទៀតមានប្រដាប់បិទតែត្រង់ដោះទាំងគូរ ឲ្យឡើងរាងក្បំដូចផ្លែទម្លាប់ នៅប្រដាប់បិទដោះមានរចនាជាក្បាច់ផ្សេងៗផង។ ផ្នែកខាងសក់មានពីរបែប ខ្លះពាក់មកុដកំពូលបី សក់ក្រងសំយុងចុះមកក្បែរដោះក៏មាន ខ្លះសក់ខ្លីគ្រាន់តែចេញជើងសក់ក្រោមមកុដក៏មាន ខ្លះទៀតមិនពាក់មកុដទេ ក្រងសក់ជាក្បាច់ភ្ញួងមាលាច្រើនបែប ខ្លះក្រងជាភ្ញួងផ្កាម្លិះ ផ្កាកូឡាប ខ្លះក្រងដូចជាសត្វមេអំបៅ។ នៅកនិងដៃជើងមានពាក់គ្រឿងអលង្ការស្អេកស្អះ ជាគ្រឿងលម្អភេទស្ត្រីខ្មែរសម័យអង្គរ។

លម្អខាងភេទបុរស ក៏មានលំនាំដូចស្ត្រីដែរ ស្លៀកខោ ឬសំពត់ខិតចុះក្រោម បញ្ចេញក្បាលពោះ បញ្ចេញផ្ចិត នៅកណ្តាលវាល ឲ្យឃើញថាមពលស្វាហាប់របស់បុរស ផ្នែកខាងលើ មិនពាក់អាវឡើយ គ្រាន់តែលម្អដោយគ្រឿងអលង្ការ ឬកន្សែងមានជាយវែង បញ្ចេញសាច់ទ្រូង សាច់ដុំគ្រប់អន្លើ ដែលជាលម្អរបស់បុរស ឲ្យមើលឃើញភាពសង្ហាស្វាហាប់ជាក់ច្បាស់ ។ល។

ផ្នែកលក្ខណៈវប្បធម៌ អំពីសិល្បៈផ្សេងៗ មានសិល្បៈរបាំ តូរ្យតន្ត្រីជាដើម សុទ្ធតែចម្រើនលូតលាស់ទាំងអស់ ខាងសិល្បៈរបាំតូរ្យតន្ត្រីក្នុងរជ្ជកាលស្តេចជ័យវរ្ម័នទី ៧ គ្រាន់តែរបាំព្រះរាជទ្រព្យ មាននាដការិនី នាដករ រាប់ពាន់នាក់ និងភ្លេងពិណពាទ្យរាប់រយវង់ សម្រាប់រាំ ប្រគំថ្វាយ ទេវរូបក្នុងប្រាសាទតាព្រហ្ម និងប្រាសាទព្រះខ័នតែពីរប៉ុណ្ណោះ នៅមានរបាំតូរ្យតន្ត្រី សម្រាប់ព្រះមហាក្សត្រ សម្រាប់ស្តេចត្រាញ់និងរបាំតូរ្យតន្ត្រីផ្សេងៗ មានរបាំប្រជាប្រិយជាដើមតាមខេត្ត ស្រុក ភូមិទៀត។

ឯសិល្បៈដែលចម្រើនលូតលាស់ដល់ថ្នាក់កំពូលនោះ គឺសិល្បៈស្ថាបត្យកម្ម (Architecture) សិល្បៈនេះ ក្នុងសម័យអង្គរ គេចែកជា ៩ រចនាបថ (Style) គឺ ៖ រចនាបថគូលែន ព្រះគោ បាខែង កោះកែ បន្ទាយស្រី ឃ្លាំង បាពួន អង្គរវត្ត និងរចនាបថបាយ័ន។


www.elibraryofcambodia.org

ក្នុងទីនេះ និយាយតែអំពីរចនាបថអង្គរវត្តមួយ ដោយសង្ខេបខ្លីៗ។ ដែលហៅថា រចនាបថអង្គរវត្ត គឺយកប្រាសាទអង្គរវត្តជាគោល។

ប្រាសាទនេះកើតឡើងនៅដើម គ.វ. ទី ១២ ក្នុងរជ្ជកាលស្តេចសុរិយាវរ្ម័នទី ២ ដែលមានរាជធានីនៅអង្គរ ពី គ.ស. ១១១៣ ដល់ ១១៤៥។

ឯប្រាសាទដែលរាប់បញ្ចូលក្នុងរចនាបថនេះមាន ១១ គឺ ៖

- ប្រាសាទបឹងមាលា
- ប្រាសាទព្រះបាលិលេយ្យ
- ប្រាង្គណនៅលើប្រាសាទបាគង
- ប្រាសាទពិម៉ាយ
- ប្រាសាទព្រះពិធូរ
- ប្រាសាទចៅសាយទេវតា
- ប្រាសាទធម្មានន្ទ
- ប្រាសាទបន្ទាយសំរែ
- ប្រាសាទអង្គរវត្ត
- ប្រាសាទវត្តធ្លា
- ប្រាសាទព្រះខ័ននៅកំពង់ស្វាយ។

ក្នុងរចនាបថនេះ គេសង្កេតឃើញស្ថាបត្យកម្មខ្មែរបានឡើងដល់ថ្នាក់កំពូលហើយ ដូចប្រាសទអង្គរវត្ត ជាសំណង់ធំណាស់ ហៅថា ប្រាសាទភ្នំ មានថែវធំហើយវែង តួប្រាសាទទាំងមូល ធ្វើពីថ្មភក់ទាំងអស់ មានរាង និងកម្ពស់សមល្អក្រៃលែង ទោះបីមើលពីយន្តហោះ ក៏ដូចជាមើលពីគ្រប់ទិសទាំង ៨ ដែរ សោភណភាពនេះហើយ ដែលធ្វើឲ្យសិល្បៈខ្មែរមានកម្រិតជាសិល្បៈសាកល។

សិល្បៈខ្មែរគ្រប់បែបបានចម្រើនយ៉ាងខ្លាំង តាំងតែពីសម័យបុរេអង្គរមកម្ល៉េះ។ សូម្បីតែរូបសត្វនានា ដូចរាជសី នាគ គ្រុឌ ហង្ស កិន្នរ យក្សជាដើម ដែលមានក្នុងសិល្បៈខ្មែរ សុទ្ធតែមានគុណភាពខ្ពស់ ស្ទើរតែមើលមិនស្គាល់ជាសត្វអ្វី ព្រោះបានរចនាបញ្ចូលសិល្បៈខ្មែរ ទៅក្នុងរូបឆោមសត្វទាំងនោះសព្វសព៌ាង្គកាយ ដូចជានាគ សិល្បករខ្មែរបានរចនាតាក់តែងខ្លួន បំពាក់មកុដ សង្វារ កងកណ្ឋ ឲ្យវាតាំងពីក្បាលដល់ចុងកន្ទុយ មើលទៅឃើញប្លែកអស្ចារ្យ ខ្លះមានរចនាជាក្បាល ៧ បើពពារ ឲ្យឈ្មោះថា នាគសត្តសីស៍ មាននាគខ្លះ ខាំនាគត្រង់ករបញ្ចេញក្បាលនាគមួយពីមាត់មកទៀត ។ល។


www.elibraryofcambodia.org

តើក្នុងពិភពលោកនេះ មានរូបនាគប្រទេសណា ទ្រង់គ្រឿងដូចនាគខ្មែរឬទេ? មិនមានទាល់តែសោះ! មានតែនាគរបស់ប្រទេសជិតខាងខ្លះ ដែលរៀនចម្លងពីខ្មែរទៅ ប៉ុណ្ណោះ ឃើញស្រដៀងគ្នាខ្លះ។

ឯជនជាតិជិតខាងនេះ ជាជនបញ្ចើក្អែក ទើបនឹងចូលមកនៅក្នុងអាស៊ីភាគអាគ្នេយ៍នេះ ក្រោយគេ គ្មានអារ្យធម៌ផ្ទាល់ខ្លួនឡើយ អ្វីៗទាំងអស់ រាប់តាំងពី ទម្លាប់ទំនៀម ភ្លេង របាំ សិល្បៈ អក្សរ ចំណីអាហារ បង្អែមចម្អាប សុទ្ធតែរៀនធ្វើ រៀនច្រៀងរាំ រៀនសរសេរ រៀនស៊ីតាមខ្មែរទាំងអស់។

ចំណែកជនជាតិយួន ដែលមានវប្បធម៌ អារ្យធម៌ ទម្លាប់ទំនៀមជាដើម ខុសឆ្ងាយពីខ្មែរនោះ ព្រោះជាប់ធ្វើខ្ញុំចិនជាងមួយពាន់ឆ្នាំ ចាប់ពីឆ្នាំ ១១១ មុន គ.ស. រហូតដល់មក គ.ស. ៩៣៩ គឺក្នុងគ្រិស្តសតវត្សរ៍ទី ១០ ទើបបានរួចខ្លួនជាអ្នកជា មកជណ្តើមយកទឹកដីចាម និងខ្មែរខ្លះ ទើបមានទម្លាប់ទំនៀមទាំងអស់ដូចទៅខាងចិន។

ឯជនជាតិសៀម ហៅ ថៃឡង់នោះ តាមសៀវភៅប្រវត្តិសាស្ត្រ របស់លោក ម៉ាក់ដូណាលដ៍ (A. W. Macdonald) ថា ខាងដើមនៃ គ.វ. ទី ៨ នៅណានចៅ ត្រង់ចន្លោះទិសបស្ចិម និងពាយ័ព្យនៃតំបន់យូណាន គេឃើញមានពួកសៀម រស់នៅជាសង្គមតូចៗរាត់រាយ លុះដល់មក គ.ស. ១២៣៨ គ.វ. ទី ១៣ ទើបកើតជាប្រជាជាតិមួយឡើង មានព្រះចៅរាមកំហែង ជាបឋមក្សត្រសោយរាជ្យ។ ឃើញថាប្រជាជាតិសៀម កើតក្រោយពេលដែលយួនបានរួចពីខ្ញុំចិនជាង ២ សតវត្សរ៍ កើតក្រោយខ្មែរជាងម្ភៃសតវត្សរ៍ បានចូលមករស់នៅជិតខ្មែរ ក្នុងពេលដែលប្រទេសខ្មែរ កំពុងចម្រើនដល់ថ្នាក់កំពូល ទើបជនជាតិសៀមដែលទើបនឹងកើតថ្មីនោះស្រឡាញ់អារ្យធម៌ខ្មែរណាស់ ខំរៀនធ្វើគ្រាប់តាមខ្មែរ គ្រប់បែបយ៉ាងទាំងអស់ តាំងពីសម្តី ភាសា ចំណីអាហារ សម្លៀកបំពាក់ភ្លេងតូ្យតន្ត្រីជាដើម។

ខាងភាសា = ភាសាខ្មែរក្នុងសម័យអង្គរនេះ មានភាសាល្បាយថ្មីមួយទៀត ដែលក្លាយពីបាលី ចូលមកក្នុងនិយន្តសាស្ត្រខ្មែរ។ ភាសាបាលីនេះ ខ្មែរនិយមប្រើនៅចុងរជ្ជកាលស្តេចជ័យវរ្ម័នទី ៧ គឺចុងគ្រិស្តសតវត្សរ៍ទី ១២ ដែលព្រះអង្គបានបញ្ជូនព្រះរាជបុត្រព្រះនាម តាមលិន្ទ ឲ្យទៅសិក្សាវិជ្ជាពុទ្ធសាសនានៅលង្កាទ្វីប។ កាលដែលព្រះរាជបុត្រអង្គនេះ បានបួស បានសិក្សាវិជ្ជាពុទ្ធសាសនា នៅក្នុងប្រទេសគេបានចេះដឹងហើយ នាំយកលទ្ធិពុទ្ធសាសនា ថេរវាទ ខាងលង្កាវង្ស ដែលនិយមប្រើភាសាបាលី ចូលមកប្រទេសកម្ពុជា ប្រហែលបាននាំគម្ពីរដីកា ធម៌អាថ៌ ជាភាសាបាលី និងក្បួនវេយ្យាករណ៍


www.elibraryofcambodia.org

បាលីមកផងដែរ ទើបខ្មែរចេះប្រើភាសាបាលី ប្រើភាសាបាលីតៗមករហូតសព្វថ្ងៃ ព្រោះពុទ្ធសាសនាថេរវាទ ដែលចូលមកក្នុងប្រទេសខ្មែរ តាំងពីឆ្នាំ ៣០៩ មុន គ.ស. នោះ ឃើញប្រើតែភាសាសំស្ក្រឹត។

ក្នុងសម័យអង្គរនេះ ខ្មែរចេះភាសាសំស្ក្រឹត ចេះត្រៃវេទស្ទាត់ជំនាញណាស់ មានភូមិវិជ្ជា នៅប្រទេសឥណ្ឌាក្នុងសម័យនោះ ទើបខ្មែរអាចសិក្សាភាសាបាលីបានចេះដឹងឆាប់រហ័សបំផុត ព្រោះភាសាបាលីនិងសំស្ក្រឹតដូចភាសាតែមួយ គ្រាន់តែមានវេយ្យាករណ៍និងសម្លេងអាចប្លែកគ្នាដោយអន្លើៗប៉ុណ្ណោះ។

ខាងអក្សរសាស្ត្រ = ក្នុងសម័យអង្គរនេះ អក្សរសាស្ត្រខ្មែរបានចម្រើនដល់ថ្នាក់កំពូលដូចខាងសិល្បៈដែរ មានការចេះដឹងនូវចំណេះវិជ្ជាខាងផ្លូវលោក ផ្លូវធម៌ និងគោលមតិទូទៅយ៉ាងច្រើន ហើយផ្សព្វផ្សាយតាមការនិទាន តាមការសម្តែងកាយវិការ តាមអក្សរសាស្ត្រ ក្បួនខ្នាត និងតាមការបង្ហាត់បង្ហាញផ្ទាល់មាត់។

ក្នុងរាជ្យស្តេចជ័យវរ្ម័នទី ៧ មានសាកលវិទ្យាល័យ មហាវិទ្យាល័យ សម្រាប់បង្រៀនវិជ្ជាខ្ពង់ខ្ពស់ ខាងអក្សរសាស្ត្រ និងបច្ចេកទេសចំពោះពលរដ្ឋខ្មែរ។ ព្រះឥន្ទ្រទេវី ជាអគ្គជាយាព្រះអង្គជាសាកលវិទ្យាធិការិនី នៃសាកលវិទ្យាល័យជ័យស្រី ក្នុងមណ្ឌលប្រាសាទព្រះខ័ន មានអ្នកបួសថ្នាក់បណ្ឌិត ១៨ អង្គ និងថ្នាក់សាស្ត្រាចារ្យ ២៧៤០ អង្គ បង្រៀននូវមហាវិទ្យាល័យរាជវិហារ ក្នុងមណ្ឌលប្រាសាទតាព្រហ្ម។

ចំពោះវណ្ណៈអក្សរ ក្នុងសម័យអង្គរនេះ បានចម្រើនរុងរឿងណាស់ មានសិលាចារឹកសន្ធឹកសន្ធាប់ ជាភាសាសំស្ក្រឹតក៏មាន ជាភាសាខ្មែរក៏មាន ជាភាសាបាលីក៏មាន។

ឯសិលាចារឹកជាភាសាបាលីនោះ កើតមានដំបូងបំផុតក្នុងរាជ្យស្តេច ស្រីន្ទ្រវរ្ម័នខាងចុង គ.វ. ទី ១៣ គ.ស. ១២៩៦ សិលាចារឹកនេះ នៅក្នុងស្រុកពួក ខេត្តសៀមរាបសព្វថ្ងៃ។

ឯរាងតួអក្សរ ចាប់ពី គ.វ. ទី ៩ មក កាន់តែធ្វើដំណើរមករករាងតួអក្សរយើងសព្វថ្ងៃនេះហើយ ដូចសិលាចារឹកនៅប្រាសាទព្រះខ័ន (កំពង់ស្វាយ) ក្នុងរជ្ជកាលស្តេចជ័យវរ្ម័នទី ២ ខាងដើម គ.វ. ទី ៩ ឃើញតួអក្សរច្បាស់ជា ក ខ គ ឃ ង ដូចរាងតួអក្សរសព្វថ្ងៃ និងសិលាចារឹករបស់អ្នកនិពន្ធឯក ឈ្មោះ សិវ-សោម ខាងចុង គ.វ. ទី ៩ ក្នុងរជ្ជកាលស្តេចឥន្ទ្រវរ្ម័នទី ១ នៅប្រាសាទកណ្តាលដើម ត្រង់ទិសខាងលិច ជិតប្រាសាទព្រះគោ ក្នុងស្រុកសូទ្រនិគម ខេត្តសៀមរាប ក៏មានតួអក្សរច្បាស់ដូចតួអក្សរសព្វថ្ងៃដែរ។


www.elibraryofcambodia.org

ក្នុងរជ្ជកាលស្តេចឥន្ទ្រវរ្ម័នទី ១ នេះហើយ គេឃើញសិលាចារឹកមួយ នៅប្រាសាទព្រះគោ ក្នុង គ.ស. ៨៧៩ មានប្រើពាក្យថា «កម្ពុទេស ឬកម្ពុជទេស» មុនដំបូងបំផុតក្នុងប្រវត្តិសាស្ត្រខ្មែរ ទើបតមក យើងហៅប្រទេសយើងថា កម្ពុជា ឬកម្ពុជរដ្ឋ។

ផ្នែកលក្ខណ:សង្គមធម៌ = ក្នុងសម័យអង្គរនេះ ក៏មានការចម្រើន តាមលំនាំសម័យមុន កាន់តែប្រសើរឡើងៗ ដែលប្លែកខ្លះនោះ ឃើញត្រង់សេដ្ឋកិច្ច (Economie) វណ្ណវិភាគ (Division sociale) និងប្រជាជាតិ (Nation)។

ខាងសេដ្ឋកិច្ច ក្នុងសម័យអង្គរ បានចម្រើនទាំងកសិកម្ម ពាណិជ្ជកម្ម និងឧស្សាហកម្ម ព្រោះមានជីក ព្រែក ស្ទឹង បឹង ត្រពាំង ស្រះ អណ្តូង បន្ថែមលើ ព្រែក ស្ទឹងជាដើម ដែលមានក្នុងសម័យបុរេអង្គរ និងបានបង្កើតប្រភពទឹកធំៗដូចបារាយណ៍ និងគូជុំវិញប្រាសាទអង្គរជាដើម ខាងនេសាទ និងខាងឧស្សាហកម្ម ដុតរំលាយ ដែក ស្ពាន់ លង្ហិន សំរិទ្ធិ មាស ប្រាក់ ធ្វើគ្រឿងប្រដាប់ប្រើប្រាស់គ្រប់យ៉ាង និងការឆ្នៃត្បូង ពេជ្រ និល ជាដើម ធ្វើគ្រឿងអលង្ការផ្សេងៗ ក៏បានចម្រើនណាស់ដែរ។ ផលិតផលទាំងអស់នេះ សម្រាប់មហាជនប្រើប្រាស់ក្នុងប្រទេសផង ដឹកនាំទៅលក់ឯបរទេសផង ព្រោះមានមធ្យោបាយដឹកនាំទាំងខាងជើងទឹក និងជើងគោក។ ខាងជើងគោកមានផ្លូវធំវែង ចាប់ពីមហានគរទៅក្រុងពិម៉ាយ ប្រទេសសៀមសព្វថ្ងៃ។ នៅតាមផ្លូវមានស្ថានីយ សម្រាប់ឈប់សម្រាកចំនួន ១២១ កន្លែង គឺសង់ជារបៀបសាលាសំណាក់ មានភ្លើងអុជនៅវេលាយប់ មានបុគ្គលិកនៅថែរក្សាគ្រប់សាលាទាំងអស់ ពីមហានគរទៅដល់ប្រទេសចម្ប៉ាមាន ៥៧ សាលា ពីមហានគរទៅក្រុងពិម៉ាយមាន ១៧ សាលា តាមផ្លូវបត់បែនចូលទៅកាន់ទីប្រជុំជនធំៗ ចំនួន ៤៦ សាលា និងសាលាមួយទៀតនៅភ្នំជីសូរ។

ផ្លូវនេះឯង សម្រាប់ដឹកនាំផលិតផលផ្សេងៗ ដូចស្រូវ អង្ករ ត្រី សាច់ ស្បែក ស្នែង ភ្លុក គ្រឿងទេស និង ឈើជាដើម ដោយរទេះសេះ ដំរី ទៅលក់នៅបរទេស។ ខាងជើងទឹកមានកំពង់ផែអន្តរជាតិជាច្រើនកន្លែង មានកំពង់ អូ-កែវ ជាដើម សម្រាប់ដឹកនាំផលិតផលផ្សេងៗ ដោយទូកសំពៅធំៗឆ្លង ទន្លេ សមុទ្ទ ទៅលក់ដូរក្នុងប្រទេសដែលនៅតាមកោះនានា និងប្រទេសឥណ្ឌា-ចិន រហូតដល់ប្រទេសអ៊ីរ៉ង់ ដល់សមុទ្ទមេឌីតែរ៉ាណេទៀតផង។

ខាងវណ្ណវិភាគ ការចែកវណ្ណ:មនុស្សជា ៤ ដែលធ្លាប់មានពីមុនមកនោះ ក៏មានវិវត្តន៍ប្លែកពីសម័យមុនខ្លះដែរគឺខត្តិយវណ្ណ: នៅដដែល ព្រាហ្មវណ្ណ: បានយកជាតិព្រាហ្មណ៍សុទ្ធខ្លះ យកបារគូបុរោហិត មិនមែនជាតិព្រាហ្មណ៍ខ្លះសន្មតថាជាព្រាហ្មណ៍ វេស្ស:


www.elibraryofcambodia.org

ពួកអ្នកធ្វើជំនួញ ធ្វើស្រែចម្ការហៅថា ពួជព្រៃងារ សូទ្រ: ពួកអ្នកស៊ីឈ្នួលបម្រើគេ ហៅថា ពួជអ្នកងារ ឬពួជពល មានចែកជាច្រើនផ្នែក គឺ ពលព្រះសម្រាប់បម្រើវត្តអារាម ពលដំរី សម្រាប់ថែរក្សាដំរី ព្រះរាជទ្រព្យ ពលអង្គរក្ស សម្រាប់រក្សាអង្គព្រះមហាក្សត្រ ហៅអង្គ្រ័ក្ស ពលថែវ សម្រាប់រក្សាថែវព្រះទីន័ងនាវា និងពលគុនសម្រាប់គុនដាល់ថ្វាយព្រះរាជទត ក្នុងពិធីបុណ្យផ្សេងៗ។

ពលទាំងអស់នេះ គេនិយមហៅដោយសរុបថា «ពល អង្គ្រ័ក្ស ទ្រមាក់ ថែវ គុន»។

ក្នុងរជ្ជកាលស្តេចជ័យវរ្ម័នទី ៧ ដែលជាស្តេចប្រកបដោយទសពិធរាជធម៌យ៉ាងច្រើន នោះ មិនសូវមានការប្រកាន់...

(បាត់ ២ ទំព័រ)

CAMBODIAN • EDUCATION • EXCELLENCE
មូលនិធិខ្មែរសម្រាប់ការសិក្សា
FOUNDATION


www.elibraryofcambodia.org

...រងនិងបុគ្គលិកប្រុសស្រី សម្រាប់ធ្វើការគ្រប់យ៉ាង មានចំនួន ៩ ម៉ឺន ៧ ពាន់ ៨ រយ ៤០ នាក់ (៩៧.៨៤០)។

អត្ថបទក្នុងសិលាចារឹកទាំងពីរនេះ ប្រាប់ឲ្យដឹងថាប្រជាជាតិខ្មែរសម័យអង្គរ ជាប្រជាជាតិមហាអំណាចមួយ គ្រាន់តែសេដ្ឋី គហបតី អ្នកមានទ្រព្យ ដែលមានសទ្ធាជ្រះថ្លា ទំនុកបម្រុងប្រាសាទទាំងពីរ មានចំនួន ៨.៤៦៤ នាក់ ដែលនៅក្នុងស្រុកចំនួន ៨.៤៦៤ ស្រុក។ ឯបុគ្គលិក ដែលធ្វើការក្នុងប្រាសទទាំងពីរនេះ មានចំនួន ១៧ ម៉ឺន ៧ ពាន់ ១ រយ ៥ នាក់ (១៧៧.១០៥)។ នេះគ្រាន់តែចំនួនអ្នកមានទ្រព្យក្នុងស្រុកមួយៗ ដែលមានសទ្ធា និងចំនួនបុគ្គលិក ដែលធ្វើការក្នុងប្រាសាទទាំងពីរប៉ុណ្ណោះ នៅមានប្រាសាទរាជ្យស្រី គឺប្រាសាទនាគព័ន្ធ ប្រាសាទបាយ័ន ជាដើមទៀត និងនៅមានបុគ្គលិខាងសិក្សាធិការប្រចាំស្រុក ខេត្ត បុគ្គលិកខាងសុខាភិបាល ខាងកងទ័ព ខាងមន្ត្រីរដ្ឋបាលប្រចាំស្រុក ខេត្ត ទាំង ១០២ ខេត្ត និងប្រចាំប្រទេសចំណុះទៀត ឃើញថា គ្រាន់តែបុគ្គលិកធ្វើការរាជការ មានចំនួនរាប់លានទៅហើយ ជាពិសេសក្នុងសម័យនោះ ជាសម័យដែលមានមនុស្សតិច ក្នុងពិភពលោកផង។

ដោយហេតុប្រជាជាតិខ្មែរ ជាប្រជាជាតិធំយ៉ាងនេះហើយ ទើបក្នុងពង្សាវតារខ្មែរ ប្រាប់ថា ក្នុងរជ្ជកាលព្រះមហាក្សត្រសម័យអង្គរ ជាពិសេស រជ្ជកាលស្ដេចយសោវរ្ម័ន ស្ដេចឥន្ទ្រវរ្ម័ន និងស្ដេចជ័យវរ្ម័នទី ៧ ដែលសុទ្ធជាស្ដេចប្រកបដោសម្បជញ្ញជាតិនោះ ប្រទេសខ្មែរមានវិសាលភាពទឹកដីធំទូលាយណាស់ ខាងកើតទល់នឹងប្រទេសចាម ខាងត្បូង ទល់នឹងសមុទ្ទ ខាងលិចទល់នឹងប្រទេសភូមា ខាងជើងទល់នឹងប្រទេសចិន។ មហាប្រទេសខ្មែរក្នុសម័យនោះ មានប្រទេសចំណុះចំនួន ៦០ ប្រទេស។ ឃើញថា អារ្យធម៌ខ្មែរទាំង ៤ ប្រភេទក្នុងសម័យអង្គរ បានចម្រើនដល់ថ្នាក់កំពូល។

(ចប់អារ្យធម៌ខ្មែរសម័យអង្គរ)


www.elibraryofcambodia.org

# អារ្យធម៌ខ្មែរសម័យបច្ឆាអង្គរ
## អនុប្រភព ឥណ្ឌាចិនបស្ចិមប្រទេស
(ពី គ.វ. ទី ១៥ ដល់ គ.វ. ទី ១៩)

អារ្យធម៌សម័យនេះ ចាប់និយាយពីត្រឹមរាជ្យស្តេចពញាយ៉ាត ដែលចាកចេញរាជធានីអង្គរ ដល់រាជ្យស្តេចអង្គឌួង មានរាជធានីនៅឧត្តុង។

ចាប់តាំងពីចុងវង្សក្សត្រវរ្ម័ន គឺក្រោយរាជ្យស្តេចជ័យវរ្ម័នទី ៧ មក អារ្យធម៌ខ្មែរទាំង ៥ ប្រភេទ ចេះតែចុះថយឥទ្ធិពលបន្តិចម្តងៗ ដូចព្រះចន្ទខាងរនោច មកអំពីអ្នកដឹកនាំប្រទេសជាតិ គឺស្តេចខ្វះសម្បជញ្ញជាតិ ដែលស្តេចមុនៗធ្លាប់មាន និងខ្វះសមត្ថភាព មិនអាចគ្រប់គ្រង មហាប្រទេសខ្មែរបាន ដូចជាមនុស្សមានកម្លាំងខ្សោយ មិនអាចលើវត្ថុធំមានទម្ងន់ច្រើនបាន។

អាស្រ័យហេតុនេះ ទើបជនជាតិជិតខាង ដែលជាជនបញ្ញើក្អែកនៃទ្វីបអាស៊ីភាគអាគ្នេយ៍ បាននាំគ្នាចូលមកកក្កូរក្នុងផ្ទៃប្រទេសខ្មែរ ធ្វើវិច្ឆេទកម្ម កាប់សម្លាប់ ចាក់រុក បំបែក...

CAMBODIAN EDUCATION EXCELLENCE
មូលនិធិខ្មែរសម្រាប់ការសិក្សា
FOUNDATION


www.elibraryofcambodia.org

វាយបញ្ចូលជា eBook ដោយសុ ផារៈវង្ស និង ជាតិ មរកត

ក្រោមការឧបត្ថម្ភពីសំណាក់ **ខ្មៅឃុន សំរ៉ែ**

ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

ខែ កញ្ញា ឆ្នាំ ២០១៣

**មូលនិធិខ្មែរសម្រាប់ការសិក្សា**

www.elibraryofcambodia.org